លេខ១៧
២០២៥

# ព្រឹត្តបត្រគយ

## ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី៣

កក្កដា-កញ្ញា ២០២៥

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា













# អារម្ភកថា



ឈរលើសមិទ្ធផលដែលសម្រេចបានកន្លងមក ប្រមុខរាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា បានបន្តខិតខំប្រឹងប្រែងឥតស្រាកស្រាន្ត ដោយដាក់ចេញនិងអនុវត្តយ៉ាងសកម្មនូវគោលនយោបាយត្រឹមត្រូវ មុតស្រួច ចំទិសដៅ និងទាន់ពេលនានាជាបន្តបន្ទាប់ ដែលអាចឱ្យកម្ពុជាអាចសម្រេចបាននូវសមិទ្ធផលដ៏ធំធេងជាច្រើន និងរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ឆ្ពោះទៅសម្រេចបានមហិច្ឆតារបស់ខ្លួនគឺ កម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។ ឈរលើមូលដ្ឋាននេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានបន្តអនុវត្តបេសកកម្មរបស់ខ្លួនយ៉ាងសកម្មលើការងារគ្រប់គ្រងប្រមូលចំណូលលើទំនិញនាំចេញ-នាំចូល ការលើកកម្ពស់បរិយាកាសធុរកិច្ច និងការបន្តកែទម្រង់រដ្ឋបាលរបស់ខ្លួនឥតឈប់ឈរ ស្របតាមការវិវត្តយ៉ាងឆាប់រហ័សនៃស្ថានភាពសង្គម-សេដ្ឋកិច្ចតំបន់ និងសកលលោក សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការពង្រឹងសមត្ថភាពប្រកួតប្រជែងនៅកម្ពុជា។

ជាក់ស្តែង ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ នេះ **អគរ** សម្រេចបាននូវសមិទ្ធផលជាច្រើនដែលមានរៀបរាប់ជូនលម្អិតក្នុងព្រឹត្តិបត្រគយលេខ១៧ នេះ រួមមាន៖ លទ្ធផលនៃការប្រមូលចំណូល ការធ្វើសាមញ្ញកម្មនិងស្វ័យប្រវត្តិកម្មនីតិវិធីគយ ការកសាងនិងគ្រប់គ្រងធនធានមនុស្ស និងការចូលរួមព្រឹត្តិការណ៍សង្គមផ្សេងទៀត ដូចជា ការងារមនុស្សធម៌ ការចូលរួមប្រកួតកីឡា និងសម្តែងសិល្បៈជាដើម។ សមិទ្ធផលនិងស្នាដៃទាំងឡាយដែល **អគរ** សម្រេចបាន គឺដោយសារមានការខិតខំអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីគយនិងរដ្ឋាករនៅទូទាំងប្រទេស ដែលបានបំពេញការងារប្រកបដោយស្មារតីបុរេសកម្មនិងទទួលខុសត្រូវខ្ពស់។ ខ្ញុំសូមយកឱកាសនេះ លើកទឹកចិត្តឱ្យថ្នាក់ដឹកនាំនិងមន្ត្រីគយគ្រប់ជាន់ថ្នាក់ បន្តខិតខំអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាពប្រកបដោយជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌និងកិរិយាមារយាទល្អក្នុងការផ្តល់សេវាសាធារណៈ សំដៅធានាបានប្រសិទ្ធភាពក្នុងការប្រមូលចំណូល និងធានាបាននូវបរិយាកាសធុរកិច្ចឱ្យកាន់តែល្អប្រសើរ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ព្រឹត្តិបត្រគយនេះនឹងបន្តផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់សាធារណជន ក៏ដូចជាសិស្សនិស្សិត អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធនានា ដើម្បីទទួលបាននូវចំណេះដឹងកាន់តែទូលំទូលាយលើវិស័យគយ និងសមិទ្ធផលការងារដែលសម្រេចបានរបស់ **អគរ** ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការនៃ **អគរ** និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវគារវកិច្ចភក្តីភាពដ៏ស្មោះស្ម័គ្របំផុតចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលតែងតែផ្តល់ការគាំទ្រ ណែនាំ និងយកចិត្តទុកដាក់ខ្ពស់ចំពោះ **អគរ** ដែលធ្វើឱ្យរដ្ឋបាលគយកម្ពុជា អាចសម្រេចបានសមិទ្ធផលនិងស្នាដៃជាប្រវត្តិសាស្ត្រថ្មីៗជាច្រើននាពេលកន្លងមកនេះ។

ជាទីបញ្ចប់ក្នុងនាមជាថ្នាក់ដឹកនាំ **អគរ** ខ្ញុំសូមស្វាគមន៍នូវរាល់មតិយោបល់រិះគន់ស្ថាបនាពីបណ្តាប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ដើម្បីបន្តកែលម្អព្រឹត្តិបត្រគយលេខក្រោយៗទៀតឱ្យកាន់តែល្អប្រសើរឡើង។ ខ្ញុំសូមប្រសិទ្ធពរជ័យសិរីមង្គលគ្រប់យ៉ាង ជូនដល់ប្រិយមិត្តអ្នកអានទាំងអស់ទទួលបាននូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃព្រហស្បតិ៍ ២កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

បណ្ឌិត គុណ ញឹម



ក្រុមការងារចងក្រង
ព្រឹត្តិបត្រគយ

ឯកឧត្តមបណ្ឌិត **គុណ ញឹម**
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

| | |
|---|---|
| លោក | ផា អេងផឹង |
| លោក | សែ សុឃុន |
| លោក | ចាន់ សុទ្ធាព |
| លោកបណ្ឌិត | ឈុន វឿន |
| លោក | រ៉ូ វណ្ណា |
| លោកបណ្ឌិត | សង់ ស៊ីណារិទ្ធ |
| លោក | ទូច លីដែល |
| លោក | នួ ស៊ីថា |
| លោក | ប៊ុន ជីវ |
| លោក | អន ស៊ីនួន |
| លោក | ហ៊ីវ ពុទ្ធិរិទ្ធ |
| លោក | ក្លូវ ណុច |
| លោក | សុខ សុដារ៉ា |
| លោកបណ្ឌិត | ហ៊ុល ប៊ុនថា |
| លោក | នង សុខុម |
| លោក | អ៊ុំ ច័ន្ទរតនា |
| លោក | សំ សុវណ្ណារិទ្ធិ |
| លោក | សំ កុសល |
| លោក | យូ ហេង |
| លោក | លី ប៊ុនសុង |
| លោក | មួង ដារ៉ា |
| លោក | ចាន់ សំបូរ |
| លោក | ហេង សំបូរ |
| លោក | ប្រាក់ ចាន់ធី |
| លោក | ឈួន ហៃ |
| លោក | លី សារឿន |
| លោក | ជាប សៅ |
| លោក | ថេង ម៉ុងហាក់ |
| លោក | អ៊ួន សុវណ្ណារ៉ា |
| លោក | ឃឹម វណ្ណៈ |
| លោក | ឈួន សោភា |
| លោក | លាង ហ៊ាន់ |
| លោក | ឡាង ថាវរៈ |
| លោក | លាង រតនា |
| លោក | គឹម វណ្ណាត |
| លោក | ប៊ូ គង់ឡេង |

# មាតិកា
# Contents

ទំព័រ


**ផ្នែកទី១ ព្រឹត្តិការណ៍សំខាន់ៗ ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥** ..... ៤
- កិច្ចប្រជុំបូកសរុបការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ..... ៤
- ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងសមាគមកស្តុភារកម្មកម្ពុជា ..... ៧
- កិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហាឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តអត្រាពន្ធគយលើទំនិញនាំចូលពីសហរដ្ឋអាមេរិក ..... ១០
- កិច្ចពិភាក្សាការងាររវាង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងគណៈកម្មការទី២ នៃព្រឹទ្ធសភា ..... ១២
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាលនិងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករកំពង់ផែក្រសាំង ..... ១៤
- កិច្ចប្រជុំលើកទី២ ស្តីពីការតភ្ជាប់គយនៃផ្លូវបៀងពាណិជ្ជកម្មអន្តរជាតិតាមផ្លូវគោកនិងផ្លូវទឹកថ្មី ..... ១៦
- កិច្ចសន្ទនារវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងសមាគមធុរកិច្ចជប៉ុននៅកម្ពុជា ..... ១៩

**ផ្នែកទី២ ការយល់ដឹងអំពីនីតិវិធីគយ** ..... ២១
- ការលើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសគយ ..... ២២
- វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ ..... ២៤
- សិក្ខាសាលាស្តីពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធគយ ..... ២៦
- សិក្ខាសាលាស្តីពីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ..... ២៨
- សិក្ខាសាលាសមាគមសភាពាណិជ្ជកម្មឥណ្ឌានៅកម្ពុជាស្តីពីរដ្ឋបាលគយកម្ពុជាឆ្នាំ២០២៥ "Breakfast Talk on Cambodia Customs 2025" ..... ៣១
- វគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធ" សម្រាប់មន្ត្រីគយនិងរដ្ឋាករ ..... ៣៣
- សិក្ខាសាលាស្តីពី "នីតិវិធីនៃការប្រមូលទិន្នន័យនិងចងក្រងស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ" សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ..... ៣៥

**ផ្នែកទី៣ លទ្ធផលការងារសម្រេចបានមួយចំនួនរបស់បណ្តានាយកដ្ឋាន និងអង្គភាពមូលដ្ឋាន** ..... ៣៧
- ការងារគ្រប់គ្រងហិរញ្ញវត្ថុនិងបុគ្គលិក ..... ៣៨
- ការងារផែនការនិងបច្ចេកទេស ..... ៤៣
- ការងាររបបគយ ..... ៤៥
- ការងារគ្រប់គ្រងតំបន់រួចពន្ធ ..... ៤៩
- ការងាររដ្ឋាករ ..... ៥០
- ការងារគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ..... ៥៣
- ការងារគយនិងរដ្ឋាករផៃស្ងួត ..... ៥៧
- ការងារបង្ការនិងបង្ក្រាបបទល្មើស ..... ៦០
- សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ..... ៦៣
- សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង ..... ៦៥
- សាខាគយនិងរដ្ឋាករខេត្តកណ្តាល ..... ៦៧
- សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង ..... ៦៩
- សាខាគយនិងរដ្ឋាករខេត្តក្រចេះ ..... ៧១
- សាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ ..... ៧២
- សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ ..... ៧៤
- សាខាគយនិងរដ្ឋាករខេត្តព្រៃវែង ..... ៧៥
- សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម ..... ៧៧
- សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ ..... ៧៨
- សាខាគយនិងរដ្ឋាករខេត្តកំពង់ធំ ..... ៨០
- សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់ ..... ៨១
- ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ១ ..... ៨៣
- ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់៤ ..... ៨៥

**ផ្នែកទី៤ ការងារសង្គម កីឡា និងសិល្បៈ** ..... ៨៦

# ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី៣ ឆ្នាំ២០២៥

# ផ្នែកទី១
## ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី៣ ឆ្នាំ២០២៥

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានចូលរួមនិងរៀបចំដូចខាងក្រោម៖**

- កិច្ចប្រជុំបូកសរុបការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានិងសមាគមកសិករកម្ពុជា
- កិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តអត្រាពន្ធគយលើទំនិញនាំចូលពីសហរដ្ឋអាមេរិក
- កិច្ចពិភាក្សាការងាររវាង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងគណៈកម្មការទី២ នៃព្រឹទ្ធសភា
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាលនិងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករកំពង់ក្រសាំង
- កិច្ចប្រជុំលើកទី២ ស្តីពីការតភ្ជាប់គយនៃផ្លូវរបៀងពាណិជ្ជកម្មអន្តរជាតិតាមផ្លូវគោកនិងផ្លូវទឹកថ្មី
- កិច្ចសន្ទនារវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងសមាគមធុរកិច្ចជប៉ុននៅកម្ពុជា

# កិច្ចប្រជុំបូកសរុបការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នាព្រឹកថ្ងៃសុក្រ ១រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ វេលាម៉ោង ០៨:៣០នាទី នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) ដោយមានសមាសភាព ចូលរួមពីលោក-លោកស្រីអគ្គនាយករង និងលោក លោកស្រីប្រធាន និងអនុប្រធានអង្គភាពគយនិងរដ្ឋាករមួយចំនួន អមដោយមន្ត្រីជំនាញ និងបានប្រព្រឹត្តទៅតាមរបៀបវារៈដូចបានគ្រោងទុក។

លទ្ធផលនៃការប្រមូលពន្ធនិងអាករក្នុងខែមិថុនា ឆ្នាំ២០២៥ទទួលបាន ១ ០២៣,៧ ប៊ីលានរៀល (ស្មើនឹងប្រមាណ២៥២,៨លានដុល្លារអាមេរិក) ថយចុះប្រមាណ ៧,១% ប្រៀបធៀបនឹងចំណូលខែឧសភា ឆ្នាំ២០២៥ និងកើនឡើង ១៤,៤% បើប្រៀបធៀបនឹងខែមិថុនា ឆ្នាំ២០២៤។ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥ ការប្រមូលពន្ធនិងអាករ សម្រេចបាន ៦ ០០៩ ប៊ីលានរៀល (ស្មើនឹងប្រមាណ ១ ៤៧៨,២ ដុល្លារអាមេរិក) មានកំណើនចំនួន ១០៤២,១ប៊ីលានរៀលឬត្រូវជាប្រមាណ២១%ប្រៀបធៀបនឹងចំណូលក្នុងឆមាសទី១ ឆ្នាំ២០២៤។ ចំណូលដែលសម្រេចបាននេះត្រូវជាប្រមាណ ៥៨,៦% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។

បើគិតជាសមាសភាគចំណូលតាមប្រភេទពន្ធនិងអាករធៀបនឹងចំណូលសរុប អាករលើតម្លៃបន្ថែមមានប្រមាណ ៤០,៧%, អាករពិសេសមានប្រមាណ ៣៥,១%, ពន្ធគយមានប្រមាណ ១៥,៨%, អាករបន្ថែមលើផលិតផលប្រេងកាតមានប្រមាណ ៣,៩% និងអាករនាំចេញនិងកម្រៃផ្សេងៗមានប្រមាណ ៤,៤%។ ចំពោះសមាសភាគនៃចំណូលតាមក្រុមទំនិញធៀបនឹងចំណូលសរុប យានយន្តនិងគ្រឿងចក្រមានប្រមាណ៣៦,២%, ក្រុមទំនិញចម្រុះមានប្រមាណ ៣២,២%, ប្រេងឥន្ធនៈនិងថាមពលមានប្រមាណ ២៣,៧%, និងសម្ភារសំណង់និងកម្រៃផ្សេងៗមានប្រមាណ ៧,៩%។

ទំហំពាណិជ្ជកម្មនាំចូលមានចំនួន ១៦ ២៧៨,៩ លានដុល្លារអាមេរិក កើនឡើងប្រមាណ ១៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤ ដែលក្នុងនោះទំនិញនាំចូលសំខាន់ៗមានជាអាទិ៍ ផលិតផលវាយនភណ្ឌជាវត្ថុធាតុដើមនិងគ្រឿងម៉ាស៊ីនបម្រើដល់គម្រោងវិនិយោគ, ផលិតផលតេលសិលា, គ្រឿងសំណង់, យានយន្តនិងគ្រឿងចក្រ, គ្រឿងឧបភោគបរិភោគ និងទំនិញចម្រុះផ្សេងទៀត។

ទំហំពាណិជ្ជកម្មនាំចេញមានចំនួន ១៤ ៤១៨,៨ លានដុល្លារអាមេរិក កើនឡើងប្រមាណ ១៦,១% ធៀបនឹងឆមាសទី១ឆ្នាំ២០២៤ដែលក្នុងនោះផលិតផលវិនិយោគកាត់ដេរមានកំណើន២២,១%, ផលិតផលវិនិយោគមិនមែនកាត់ដេរ (មានជាអាទិ៍ សំបកកង់រថយន្ត, គ្រឿងបំណែកអេឡិចត្រូនិកនិងបង្គុំខ្សែភ្លើង, ផលិតផលពីឈើ, កង់, អំពូល, ផលិតផលប្លាស្ទិក, និងផលិតផលឧស្សាហកម្មផ្សេងទៀត) មានកំណើន ១១,២%, និងកសិផល (មានជាអាទិ៍ ស្រូវ, អង្ករ, ដំឡូង, កៅស៊ូ, ចេក, គ្រាប់ស្វាយចន្ទី និងកសិផលផ្សេងៗទៀត) មានកំណើន ៤,៤%។

បន្ថែមពីលើការងារប្រមូលចំណូល **អគរ** ក៏សម្រេចបាននូវវឌ្ឍនភាពល្អប្រសើរលើការងារសំខាន់ៗផ្សេងទៀត ដូចជា ការកែលម្អនិងធ្វើឌីជីថលភាវូបនីយកម្មនីតិវិធី, ការងារស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ, ការងារសវនកម្ម និងការគ្រប់គ្រងហានិភ័យ, កិច្ចសហការជាមួយផ្នែកឯកជន, កិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារគយ, និងការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន។

សម្រាប់ឆមាសទី២ ឆ្នាំ២០២៥, ឯកឧត្តមរដ្ឋមន្ត្រី

ប្រតិភូអមនាយករដ្ឋមន្ត្រី បានដាក់ចេញនូវទិសដៅការងារសម្រាប់អនុវត្តមួយចំនួនមានជាអាទិ៍ ការបន្តអនុវត្តផែនការសកម្មភាពឆ្នាំ២០២៥ របស់ **អគរ** ឱ្យបានជោគជ័យ, ការបន្តពង្រឹង និងកែលម្អប្រព័ន្ធបច្ចេកវិទ្យាគាំទ្រដល់កិច្ចប្រតិបត្តិការគយ, ការសហការជាមួយផ្នែកឯកជនដើម្បីដោះស្រាយបញ្ហា និងជំរុញលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម, ការពង្រឹងការបង្ការនិងបង្ក្រាបបទល្មើសរត់គេចពន្ធគ្រប់មុខសញ្ញា, ការកសាងនិងអភិវឌ្ឍស្ថាប័ន, និងការចូលរួមអនុវត្តឯកសារយុទ្ធសាស្ត្រ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាលឱ្យបានខ្ជាប់ខ្ជួននិងពេញលេញ។








# ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានិងសមាគមភស្តុភារកម្មកម្ពុជា

នារសៀល ថ្ងៃសុក្រ ១៥រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មាន រៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង សមាគមភស្តុភារកម្មកម្ពុជា ស្តីពីកិច្ចសហការលើការផ្លាស់ប្តូរព័ត៌មានលើទំនិញនាំចេញ-នាំចូល, ឆ្លងកាត់ និង ផ្ទេរមធ្យោបាយដឹកជញ្ជូន ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង លោក **ហាក់ លាងហ៊ី** ប្រធានសមាគមភស្តុភារកម្មកម្ពុជា។ ពិធីនេះក៏មានការចូលរួម ពីតំណាងសភាពាណិជ្ជកម្មកម្ពុជា, សមាគមធុរកិច្ចនានា, អង្គការអន្តរជាតិព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករមួយចំនួន ផងដែរ។

លោក **ហាក់ លាងហ៊ី** បានសំដែងនូវអំណរគុណ ចំពោះអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែលបាន ផ្តល់ការគាំទ្រដល់វិស័យឯកជន ក៏ដូចជាដែលបានធ្វើ ទំនើបកម្ម និងសាមញ្ញកម្មនីតិវិធីគយជាបន្តបន្ទាប់ និង បានប្តេជ្ញាចូលរួមជាមួយរាជរដ្ឋាភិបាល ជាពិសេសអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការធ្វើឱ្យប្រសើរ ឡើងវិស័យឡូជីស្ទីកនៅកម្ពុជាតាមរយៈការលើកកម្ពស់ ស្តង់ដារវិជ្ជាជីវៈ, សុចរិតភាព, និងគុណភាពសេវា។ លោកប្រធានសមាគម ក៏បានបន្ថែមទៀតថា ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងសមាគមភស្តុភារកម្មកម្ពុជានេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមក្នុងការធ្វើកំណែទម្រង់ ភាពជាដៃគូ និងការកសាងប្រព័ន្ធអេកូឡូជីស្ទីក ឱ្យកាន់តែមានភាពប្រកួតប្រជែង ស្របតាមស្ថានភាពនៃ សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពាណិជ្ជកម្ម ពិភពលោក។

ថ្លែងក្នុងអង្គពិធី ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានជម្រាបជូនអំពីសមិទ្ធិផលសំខាន់ៗ របស់ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នាពេលកន្លងមក លើការធ្វើទំនើបកម្មស្ថាប័ននិងកិច្ចសម្រួលពាណិជ្ជកម្ម មានជាអាទិ៍ ការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window), ការធ្វើស្វ័យប្រវត្តិកម្ម ពេញលេញនូវនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ, ការដាក់ឱ្យអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបាន ទទួលការអនុញ្ញាត (AEO), ការអនុវត្តនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing), និងការពង្រីកវិសាលភាពការប្រើប្រាស់ e-Payment ជាដើម។ ទន្ទឹមនេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ ក៏បានគូសបញ្ជាក់ថា ការចុះ MOU នាឱកាសនេះ គឺជាវឌ្ឍនភាពថ្មីមួយទៀតក្នុងការពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់កិច្ចសម្រួល ពាណិជ្ជកម្ម, ពង្រឹងអនុលោមភាពច្បាប់, កែលម្អបរិយាកាស ធុរកិច្ចនិងវិនិយោគនៅកម្ពុជា, ក៏ដូចជាការចូលរួមចំណែក ជាមួយរាជរដ្ឋាភិបាល ក្រោមការដឹកនាំ របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវវិស័យភស្តុភារកម្ម។

គួរបញ្ជាក់ផងដែរថាកន្លងមកអគ្គនាយកដ្ឋានគយនិង រដ្ឋាករកម្ពុជា ធ្លាប់បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយស្ថាប័នឬក្រុមហ៊ុនមួយចំនួន ដូចជា សមាគម អេឡិចត្រូនិចនិងបច្ចេកវិទ្យាកម្ពុជា (CETA), ក្រុមហ៊ុន Chipmong Insee Cement Corporation, ក្រុមហ៊ុន DHL EXPRESS (CAMBODIA) និងជាពិសេសគឺ MOU ជាមួយប្រៃសណីយ៍កម្ពុជាលើកិច្ចសហការផ្លាស់ប្តូរព័ត៌មាន កញ្ចប់បញ្ញើប្រៃសណីយ៍ សំដៅផ្តល់កិច្ចសម្រួលបន្ថែមទៀត ក៏ដូចជាលើកកម្ពស់អនុលោមភាពនៃការបំពេញបែបបទ បញ្ចេញទំនិញពីគយ៕


















ចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នារវាង
អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងសមាគមភស្តុភារកម្មកម្ពុជា
ថ្ងៃសុក្រ ១៥រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥





# កិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តអត្រាពន្ធគយលើទំនិញនាំចូលពីសហរដ្ឋអាមេរិក

នារសៀល ថ្ងៃសុក្រ ១៤កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តអត្រាពន្ធគយលើទំនិញនាំចូលពីសហរដ្ឋអាមេរិក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយមានការចូលរួមពីតំណាងសភាពាណិជ្ជកម្មកម្ពុជា សមាគមធុរកិច្ច តំណាងក្រុមហ៊ុននាំចេញ-នាំចូល ដើងសាគយព្រមទាំងភាគីពាក់ព័ន្ធនានា សរុបប្រមាណ ២០០ រូប។

កិច្ចប្រជុំផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងពាក់ព័ន្ធនឹងការអនុវត្តអត្រាពន្ធគយ ០%ចំពោះមុខទំនិញដែលមានដើមកំណើតនៅសហរដ្ឋអាមេរិក និងនាំចូលមកព្រះរាជាណាចក្រកម្ពុជា ពីសហរដ្ឋអាមេរិក។

នៅក្នុងកិច្ចប្រជុំនោះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានបញ្ជាក់ជូនអ្នកចូលរួមនូវខ្លឹមសារសំខាន់ៗ នៃអនុក្រឹត្យ និងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តអត្រាពន្ធគយលើទំនិញនាំចូលពីសហរដ្ឋអាមេរិក រួមមាន៖

- ទំនិញដែលអាចទទួលបានអត្រាពន្ធគយ ០% នេះ គឺជាទំនិញផលិតនៅសហរដ្ឋអាមេរិក ហើយត្រូវបាននាំចូលមកព្រះរាជាណាចក្រកម្ពុជា ពីសហរដ្ឋអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ ទំនិញប្រើរួចពុំស្ថិតក្នុងវិសាលភាពនៃការអនុវត្តអត្រាពន្ធគយ ០% នេះឡើយ ហើយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានឹងកំណត់និយមន័យសម្រាប់ទំនិញប្រើរួច។
- យានយន្តផលិតនៅសហរដ្ឋអាមេរិកនិងនាំចូលពីសហរដ្ឋអាមេរិក ដែលអាចទទួលបាននូវអត្រាពន្ធគយ ០% គឺសំដៅលើយានយន្តដែលប្រើប្រាស់មិនលើសពី៥០០០គីឡូម៉ែត្រនិងមានឆ្នាំម៉ូដែលមិនលើសពី ១ឆ្នាំ មុនឆ្នាំចរន្ត។
- ទំនិញដែលអាចទទួលបានអត្រាពន្ធគយ ០% នេះ ជាទំនិញនាំចូលមកព្រះរាជាណាចក្រកម្ពុជា ដែលបានផ្ទុកចូលក្នុងមធ្យោបាយដឹកជញ្ជូននៅសហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ តទៅ។
- ការអនុវត្តអត្រាពន្ធគយ ០% នេះពុំតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ដើមកំណើតពីសហរដ្ឋអាមេរិកឡើយ ដោយគ្រាន់តែតម្រូវឱ្យអ្នកនាំចូលធ្វើការប្រកាសដើមកំណើតទំនិញតាមទម្រង់ និងនីតិវិធីដែលកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានឹងផ្សព្វផ្សាយសេចក្តីណែនាំស្តីពីនីតិវិធីលម្អិតដើម្បីអនុវត្តតាមខ្លឹមសារអនុក្រឹត្យនិងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចខាងលើ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ខាងមុខនេះ។

កិច្ចប្រជុំផ្សព្វផ្សាយនេះ បានបញ្ចប់នៅវេលាម៉ោង ៥:០០ នាទី រសៀល ថ្ងៃដដែល។




កិច្ចប្រជុំផ្សព្វផ្សាយ
ខ្លឹមសារនៃអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥







# កិច្ចពិភាក្សាការងាររវាង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងគណៈកម្មការទី២ នៃព្រឹទ្ធសភា

នាព្រឹក ថ្ងៃសុក្រ ១៣រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២) នៃព្រឹទ្ធសភា ដឹកនាំដោយ ឯកឧត្តម **យស ផានីត្ថា**។

ក្នុងជំនួបនេះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានជម្រាបជូន គណៈប្រតិភូគណៈកម្មការទី២ នៃព្រឹទ្ធសភា អំពីរចនាសម្ព័ន្ធ និងរបៀបការងាររបស់ **អគរ**, លទ្ធផលការងារប្រមូលចំណូលពន្ធគយប្រចាំឆមាសទី១ ឆ្នាំ២០២៥, ទិសដៅការងារប្រមូលចំណូលពន្ធគយ ឆមាសទី២ ឆ្នាំ២០២៥, ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA), ឥទ្ធពលនៃអត្រាពន្ធគយបដិការបស់សហរដ្ឋអាម៉េរិកមកលើលទ្ធភាពប្រមូលចំណូលពន្ធគយរបស់កម្ពុជា, កត្តាអំណោយផល ចំណុចប្រឈម និងឱកាសក្នុងការបំពេញការងារ របស់ **អគរ** និងទិសដៅអភិវឌ្ឍន៍ **អគរ** រយៈពេលមធ្យមនិងរយៈពេលវែង។

ក្នុងឱកាសនេះ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ និងសមាជិក នៃគណៈកម្មការទី២ នៃព្រឹទ្ធសភា បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃការអនុវត្តការងាររបស់ **អគរ** ជាពិសេសលើការងារប្រមូលចំណូលជូនជាតិ និងការបកស្រាយយ៉ាងលម្អិតលើប្រធានបទនីមួយៗខាងលើ ដែលបានបង្ហាញនូវទិដ្ឋភាពជារួមនៃការអនុវត្តការងារគយនិងរដ្ឋាករ ដល់គណៈប្រតិភូ គណៈកម្មការទី២។
















# ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករ កំពង់ក្រសាំង

នាព្រឹកថ្ងៃសុក្រ ៨រោចខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាលនិងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករកំពង់ក្រសាំង ស្ថិតនៅក្នុងភូមិកំពង់ក្រសាំង ឃុំកំពង់ក្រសាំង ស្រុកបូរីជលសារ ខេត្តតាកែវ។

អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករកំពង់ក្រសាំងនេះ ត្រូវបានចាប់ផ្តើមសាងសង់នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ក្នុងនោះមាន អគាររដ្ឋបាល ទំហំ ២០ម៉ែត្រ x ១២ម៉ែត្រ កម្ពស់ ១ជាន់, អគារស្នាក់នៅនិងអាហារដ្ឋានសម្រាប់មន្ត្រីគយនិងរដ្ឋាករ ទំហំ ១៨ម៉ែត្រ x ៦.៤ម៉ែត្រ និងហេដ្ឋារចនាសម្ព័ន្ធនានា មានជាអាទិ៍ ប៉ុស្តិ៍សន្តិសុខ ទំហំ ៣.៥ម៉ែត្រ x ៣.៥ម៉ែត្រ, ជងទង់ជាតិកម្ពស់ ៧.៦ម៉ែត្រ, បង្គោលភ្លើងនិងអំពូលសូឡា, ផ្លូវបេតុង, បណ្តាញទឹកស្អាត, បណ្តាញអគ្គិសនី, ប្រព័ន្ធលូ, របងកម្ពស់ ២,៥ម៉ែត្រ ព្រមទាំងមានលម្អដោយសួនច្បារ។

សមិទ្ធផលនេះ បង្ហាញឱ្យឃើញពីការគិតគូរខ្ពស់ពីសំណាក់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការបន្តអភិវឌ្ឍសមត្ថភាពស្ថាប័នតាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងបំពាក់មធ្យោបាយបំពេញការងារឱ្យបានសមស្របដើម្បីពង្រឹងសមត្ថភាពស្ថាប័នក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារ និងការផ្តល់សេវាសាធារណៈឱ្យបានកាន់តែល្អប្រសើរ និងស្របតាមការអនុវត្តគោលដៅយុទ្ធសាស្ត្រទី៦ "សមត្ថភាពស្ថាប័ន" នៃយុទ្ធសាស្ត្រកែទម្រង់និងទំនើបកម្មគយ ឆ្នាំ២០២៤-២០២៨។

ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានណែនាំដល់ថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករប្រចាំការនៅ ការិយាល័យគយនិងរដ្ឋាករកំពង់ក្រសាំងទាំងអស់ ត្រូវខិតខំអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ ជាពិសេស ការងារគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធអាករ និងកម្រៃផ្សេងៗ លើទំនិញនាំចេញ នាំចូល ឬឆ្លងកាត់ស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីគយ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត និងត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាសោភ័ណភាពអគារនិងហេដ្ឋារចនាសម្ព័ន្ធនានាឱ្យបានល្អ ព្រមទាំងប្រើប្រាស់ធនធានទឹក-ភ្លើងប្រកបដោយភាពសន្សំសំចៃ។













# កិច្ចប្រជុំលើកទី២ ស្តីពីការតភ្ជាប់គយ នៃផ្លូវរបៀងពាណិជ្ជកម្មអន្តរជាតិតាមផ្លូវគោកនិងផ្លូវទឹកថ្មី

ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥ គណៈប្រតិភូ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដឹកនាំដោយលោក **ចាន់ សុភាព** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចូលរួមកិច្ចប្រជុំលើកទី២ស្តីពី "ការតភ្ជាប់គយនៃផ្លូវរបៀងពាណិជ្ជកម្មអន្តរជាតិតាមផ្លូវគោក និងផ្លូវទឹកថ្មី" និងកិច្ចពិភាក្សាតុមូលស្តីពី "ការជំរុញកិច្ចសម្រួលការបញ្ចេញទំនិញពីគយ" ដែលបានប្រព្រឹត្តទៅនៅទីក្រុងឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន។ កិច្ចប្រជុំនេះ មានការចូលរួមពីថ្នាក់ដឹកនាំរដ្ឋបាលគយមកពីបណ្តាប្រទេសមួយចំនួនរួមមាន៖ កម្ពុជា ព្រុយណេ ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា សិង្ហបុរី ថៃ វៀតណាម កាហ្សាក់ស្ថាន និងរដ្ឋបាលគយចិន នៃខេត្ត-ក្រុងឆុងឈីង ចាន់ជាំង ណាននីន គុនមីន ស៊ីអាន និងក្រុងអ៊ូលូមូឈី សរុបប្រមាណ ៥០រូប។

មុននឹងឈានដល់ការបើកកិច្ចប្រជុំជាផ្លូវការ លោក **ចាន់ សុភាព** និងប្រធានគណៈប្រតិភូរដ្ឋបាលគយផ្សេងទៀត បានជួបប្រជុំពិភាក្សាដោយឡែក ជាមួយថ្នាក់ដឹកនាំនៃទីក្រុងឆុងឈីង និងថ្នាក់ដឹកនាំរដ្ឋបាលគយចិន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ក្នុងតំបន់ ជាពិសេសការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ក្រោមក្របខ័ណ្ឌគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយ។

ថ្លែងក្នុងពិធីបើកកិច្ចប្រជុំ លោក **Zheng Xiangdong** អភិបាលរងទីក្រុងឆុងឈីង នៃសាធារណរដ្ឋប្រជាមានិតចិន បានស្វាគមន៍ចំពោះវត្តមានរបស់គណៈប្រតិភូទាំងអស់ និងបានគូសបញ្ជាក់ថា កិច្ចប្រជុំនេះជាវេទិកាដ៏សំខាន់សម្រាប់រដ្ឋបាលគយអាស៊ាន ចិន និងកាហ្សាក់ស្ថានចែករំលែកព័ត៌មាន កសាងទំនុកចិត្ត និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់កាន់តែស៊ីជម្រៅបន្ថែមទៀតក្នុងបរិការណ៍ដែលពិភពលោកកំពុងជួបប្រទះភាពមិនប្រាកដប្រជា។ លោក Zhang Baofeng អគ្គនាយកការិយាល័យទូទៅ នៃរដ្ឋបាលគយចិន និងជាប្រធានការិយាល័យជាតិនៃរដ្ឋបាលកំពង់ផែ បានមានប្រសាសន៍ថាកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន កាន់តែមានភាពប្រសើរឡើង ដែលក្នុងនោះចិនជាដៃគូពាណិជ្ជកម្មធំបំផុតរបស់អាស៊ានក្នុងរយៈពេល ១៥ឆ្នាំជាប់គ្នា ហើយអាស៊ានក៏ជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតរបស់ចិនក្នុងរយៈពេល ៥ឆ្នាំជាប់គ្នាផងដែរ។ លោកជឿជាក់ថា តាមរយៈកិច្ចប្រតិបត្តិការអាស៊ាន-ចិន និងការដំឡើងកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០ នឹងបន្តជំរុញកំណើនទំហំពាណិជ្ជកម្មនិងវិនិយោគរវាងភាគីទាំងពីរបន្ថែមទៀត។

អង្គប្រជុំបានពិភាក្សានិងចែករំលែកឧត្តមានុវត្តក្រោមប្រធានបទសំខាន់ៗរួមមាន៖ ការពង្រឹងនិងដំឡើងកម្រិតកិច្ចសហប្រតិបត្តិការគយអាស៊ាន-ចិន កិច្ចសម្រួលការបញ្ចេញទំនិញពីគយតាមមធ្យោបាយដឹកជញ្ជូនផ្លូវដែក និងកិច្ចពិភាក្សាតុមូលស្តីពី "ការជំរុញកិច្ចសម្រួលនីតិវិធីបញ្ចេញទំនិញពីគយរវាងចិន (ក្រុងឆុងឈីង) និងអាស៊ាន" ហើយក្នុងនោះតំណាងរដ្ឋបាលគយទាំងអស់បានចូលរួមធ្វើបទបង្ហាញក្រោមប្រធានបទទាំងបីផងដែរ។

លោកបណ្ឌិត **ជា សំណាង** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ បានធ្វើបទបង្ហាញស្តីពី "កិច្ចសហប្រតិបត្តិការលើកិច្ចសម្រួលពាណិជ្ជកម្មរវាងអាស៊ាន-ចិន ដោយផ្តោតលើករណីកម្ពុជា"។ លោកបានគូសបង្ហាញពី៖ (១).វឌ្ឍនភាពពាណិជ្ជកម្មនិងសេដ្ឋកិច្ចកម្ពុជា (២).ភាពចាំបាច់នៃសហប្រតិបត្តិការអាស៊ាន-ចិនដើម្បីពង្រឹងការតភ្ជាប់ និង (៣). វឌ្ឍនភាព និងការបញ្ចប់ជាស្ថាពរ នៃការអនុវត្តកិច្ចព្រមព្រៀងស្តីពី "កិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក" ព្រមទាំងវឌ្ឍនភាព នៃហេដ្ឋារចនាសម្ព័ន្ធនៃការតភ្ជាប់សំខាន់ៗដែលបានផ្លាស់ប្តូរមុខមាត់កម្ពុជាក្នុងការតភ្ជាប់ទៅកាន់តំបន់ និងពិភពលោក។ លោកស្រី **Guo Xueyan**

អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិចិន និងជាប្រធានដឹកនាំកិច្ចប្រជុំ បានចូលរួមអបអរសាទរកម្ពុជាចំពោះសមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធថ្មីៗរួមទាំងអាកាសយានដ្ឋានអន្តរជាតិតេជោ ដែលទើបបានដាក់ឱ្យដំណើរការ និងការអនុវត្តបានពេញលេញរបស់កម្ពុជានូវកិច្ចព្រមព្រៀងស្តីពី "កិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក"។

ជាលទ្ធផល នៃកិច្ចប្រជុំបណ្តារដ្ឋបាលគយ ដែលបានចូលរួមទាំងអស់បានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងធ្វើសាមញ្ញកម្មនីតិវិធីគយដើម្បីជំរុញកិច្ចសម្រួលពាណិជ្ជកម្ម បន្តពិភាក្សាលើនីតិវិធីគយសម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់ ជានាការអនុវត្តកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់ នៃមហាអនុតំបន់ទន្លេមេគង្គ សម្រួលនីតិវិធីគយលើទំនិញដឹកជញ្ជូនឆ្លងកាត់តាមផ្លូវដែក និងបានផ្លាស់ប្តូរមន្ត្រីទំនាក់ទំនងទៅវិញទៅមកដើម្បីតាមដាន និងបន្តកិច្ចសហប្រតិបត្តិការផ្លូវរបៀងពាណិជ្ជកម្មអន្តរជាតិតាមផ្លូវគោក និងផ្លូវទឹកថ្មីនេះ។

ទន្ទឹមនឹងនេះ បន្ទាប់ពីកិច្ចប្រជុំខាងលើ គណៈប្រតិភូទាំងអស់ត្រូវបានអញ្ជើញចូលរួមដំណើរទស្សនកិច្ចនៅមជ្ឈមណ្ឌលសួនឧស្សាហកម្មកំពង់ផែឆុងឈីង មជ្ឈមណ្ឌលឡូជីស្ទីកអយស្ម័យយានសាវណាន់យ៉ា និងក្រុមហ៊ុនផលិតម៉ាស៊ីនកសិកម្ម WEIMA ដើម្បីស្វែងយល់ពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ជាក់ស្តែង និងខ្សែច្រវាក់ផ្គត់ផ្គង់របស់ចិនជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីនិងអឺរ៉ុបផងដែរ។

គួរបញ្ជាក់ថា ផ្លូវរបៀងអន្តរជាតិតាមផ្លូវគោក និងផ្លូវទឹកថ្មីនេះ គឺជាគម្រោងផ្លូវអន្តរជាតិដ៏សំខាន់ របស់រដ្ឋបាលឆុងឈីង ដែលបង្កើតជាមជ្ឈមណ្ឌលប្រតិបត្តិការនិងឡូជីស្ទីករួមជាមួយខេត្តនិងក្រុង១២ទៀត ក្រោមក្របខ័ណ្ឌគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយ និងមានការគាំទ្រពីបណ្តាប្រទេសក្នុងតំបន់ រួមទាំងអាស៊ានផងដែរ។











中国—东盟海关深化国际陆海贸易新通道互联互通第二次会议暨
促进中国（重庆）—东盟通关便利化圆桌会议
The Second Meeting on Customs Connectivity of the New International Land-Sea Trade Corridor (ILSTC)
and the Roundtable on Promoting Customs Clearance Facilitation Between China (Chongqing) and ASEAN






Chan Sopheap
陈索普


Framework for ASEAN-China Cooperation: Trade Facilitation
ASEAN and China: Combined market of approximately 2 billion people
uld become the world's fourth-largest
AN's largest trading partner: Trade Volume between
reached almost USD1 trillion in 2024
oft connectivity through OBOR serves as a cornerstone for
nomic integration and growth
will propel China-ASEAN collaborat
heights





# កិច្ចសន្ទនារវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងសមាគមធុរកិច្ចជប៉ុននៅកម្ពុជា

នារសៀលថ្ងៃពុធ ១៤កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានរៀបចំកិច្ចសន្ទនារវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) និងសមាគមធុរកិច្ចជប៉ុននៅកម្ពុជា (JBAC) ពាក់ព័ន្ធនឹងការផ្តល់កិច្ចសម្រួលពាណិជ្ជកម្ម និងការធ្វើសាមញ្ញកម្មនីតិវិធីគយ។

កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីលោក **ផា អេងវ៉េង** អគ្គនាយករងនៃ **អគរ** តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃ **អគរ** និង លោក YAMAMURA Shinya ប្រធាន JBAC ជាសហប្រធាន ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករ តំណាងស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) សមាជិក JBAC។

ជាកិច្ចចាប់ផ្តើម លោក **ផា អេងវ៉េង** បានសម្តែងកិច្ចស្វាគមន៍ចំពោះសមាគមធុរកិច្ចជប៉ុនដែលបានចូលរួមកិច្ចសន្ទនានេះ និងបានថ្លែងអំណរគុណចំពោះសមាគមធុរកិច្ចជប៉ុន ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំកិច្ចសន្ទនា ក្នុងគោលបំណងឆ្លើយតបសំណូមពរផ្សេងៗ ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីគយ។

លោក YAMAMURA Shinya បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **អគរ** ដែលបានដាក់ចេញនូវវិធានការនានាជាបន្តបន្ទាប់ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់កិច្ចសម្រួលពាណិជ្ជកម្មដល់ធុរជនជប៉ុន។

កិច្ចសន្ទនានេះបានពិនិត្យលើសំណូមពរមួយចំនួនរួមមាន ការនាំចូលទំនិញស្របគ្នា (Parallel Import) ការនាំចូលទំនិញរំលោភកម្មសិទ្ធិបញ្ញា ការនាំចូលគ្រឿងបន្លាស់រថយន្តនិងបារីក្លែងក្លាយ ការត្រៀមដាក់ឱ្យអនុវត្តកិច្ចដំណើរការការងារគយនៅអាកាសយានដ្ឋានអន្តរជាតិតេជោ ការបង់កម្រៃសេវាអាជ្ញាបណ្ណជើងសាគយ ការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត និងការធ្វើទំនើបកម្មនិងសាមញ្ញកម្មនីតិវិធីគយ។ ជាមួយគ្នានេះ រាល់សំណូមពរដែលបានលើកឡើងត្រូវបាន **អគរ** ឆ្លើយតប និងទទួលយកដោយ JBAC។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាគមធុរកិច្ចជប៉ុននៅកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាចិត្តបន្តពង្រឹងកិច្ចសហការជាមួយគ្នា ឱ្យកាន់តែជិតស្និទ្ធថែមទៀត ក្នុងគោលដៅសម្រួលពាណិជ្ជកម្ម កែលម្អបរិយាកាសធុរកិច្ច ដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។
















# ផ្នែកទី២

## ការយល់ដឹងអំពីនីតិវិធីគយ

- ការលើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសគយ
- វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ
- សិក្ខាសាលាស្តីពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធគយ
- សិក្ខាសាលាស្តីពីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត
- សិក្ខាសាលាសមាគមសភាពាណិជ្ជកម្មឥណ្ឌានៅកម្ពុជាស្តីពីរដ្ឋបាលគយកម្ពុជាឆ្នាំ២០២៥ "Breakfast Talk on Cambodia Customs 2025"
- វគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធ" សម្រាប់មន្ត្រីគយនិងរដ្ឋាករ
- សិក្ខាសាលាស្តីពី "នីតិវិធីនៃការប្រមូលទិន្នន័យនិងចងក្រងស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ" សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

# ការលើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសគយ

ការអភិវឌ្ឍធនធានមនុស្ស ជាទិសដៅរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) ក្នុងការពង្រឹងនិងបង្កើនសមត្ថភាពជំនាញបច្ចេកទេស និងបទពិសោធការងារជូនដល់មន្ត្រីគយនិងរដ្ឋាករគ្រប់លំដាប់ថ្នាក់ សំដៅធានាការបំពេញតួនាទីនិងភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងសុចរិតភាពខ្ពស់ និងអាចជួយឱ្យ **អគរ** សម្រេចបាននូវលទ្ធផលការងារ ទាំងការកសាងសមត្ថភាពស្ថាប័នស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ "ការអភិវឌ្ឍមូលធនមនុស្ស" របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភាក្រោមការដឹកនាំដ៏ឈ្លៀសវៃប្រកបដោយគតិបណ្ឌិតរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងន័យនេះ សាលាជាតិគយបានបន្តកសាងនិងអនុវត្តនូវផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសគយ និងជំនាញពាក់ព័ន្ធផ្សេងទៀតស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ស្របតាមការវិវត្តថ្មីរបស់កម្ពុជា ក៏ដូចជាបរិការណ៍ថ្មីក្នុងតំបន់ និងសកលលោក។ ទន្ទឹមនេះ សាលាជាតិគយបានគិតគូរនិងយកចិត្តទុកដាក់លើការបន្តពង្រឹងសមត្ថភាពជំនាញបច្ចេកទេសគយដល់បុគ្គលផ្សេងទៀត ដែលជាប់ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មអន្តរជាតិ ដើម្បីជំរុញឱ្យប្រសើរឡើងនូវការបំពេញកាតព្វកិច្ចសារពើពន្ធ និងការចូលរួមលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ។

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ នេះ សាលាជាតិគយបានអនុវត្តផែនការបណ្តុះបណ្តាលរបស់ខ្លួន និងសហការជាមួយនាយកដ្ឋានបុគ្គលិកនិងហិរញ្ញវត្ថុ និងបណ្តានាយកដ្ឋានជំនាញចំណុះ **អគរ** ព្រមទាំងដៃគូអភិវឌ្ឍនានា ដោយបានរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាសរុបចំនួន ១៣ ដង ជូនដល់ មន្ត្រីគយនិងរដ្ឋាករចំនួន ៦៩០នាក់ មន្ត្រីជាប់កិច្ចសន្យាចំនួន ៤នាក់ និងវិស័យឯកជនចំនួន ៦៣៤នាក់។ ទន្ទឹមនេះ មន្ត្រីគយនិងរដ្ឋាករចំនួន ១០១នាក់ និងមន្ត្រីជាប់កិច្ចសន្យាចំនួន ២នាក់ ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលនៅតាមបណ្តាក្រសួង-ស្ថាប័នផ្សេងទៀត។ ជាមួយគ្នានេះ មន្ត្រីគយនិងរដ្ឋាករចំនួន ១៤នាក់ ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលានៅក្រៅប្រទេសចំនួន ៧ ដង ផងដែរ។
















សកម្មភាពបណ្តុះបណ្តាលរបស់សាលាជាតិគយ

# វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យចាប់ពីថ្ងៃទី១៤ដល់ថ្ងៃទី១៥ខែកក្កដា ឆ្នាំ២០២៥ នៅសាលាជាតិគយ ជូនដល់មន្ត្រីគយនិងរដ្ឋាករជួរមុខចំនួន ៦០រូប ដែលជាសមាជិកក្រុមការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅតាមនាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករមួយចំនួន។ វគ្គបណ្តុះបណ្តាលនេះជាកម្មវិធីវគ្គទី១ ប្រចាំឆ្នាំ២០២៥ ដែលប្រព្រឹត្តទៅក្នុងគោលបំណងធ្វើការរំឭក និងលើកកម្ពស់បន្ថែមនូវចំណេះដឹងរបស់មន្ត្រីគយនិងរដ្ឋាករអំពីច្បាប់ គោលការណ៍ យន្តការ និងវិធីសាស្ត្រស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ ដើម្បី មានសមត្ថភាពកាន់តែល្អប្រសើរក្នុងការចូលរួមការពារប្រព័ន្ធហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយដ្ឋានគយនិងរដ្ឋាករកម្ពុជា លោកអគ្គនាយករង **សែ សុឃន** និងជាប្រធានក្រុមការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញ-ប្បទានភេរវកម្មប្រចាំ **អគរ** បានបញ្ជាក់ថា ទោះបីព្រះរាជាណាចក្រកម្ពុជា បានចេញពីបញ្ជីប្រផេះពិតមែន ក៏គ្រប់ក្រសួង-ស្ថាប័នជាតិពាក់ព័ន្ធ រួមទាំង **អគរ** នៅតែបន្តផ្តល់ការងារអាទិភាព និងប្រកាន់ខ្ជាប់ឆន្ទៈខ្ពស់ អនុវត្តការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ ប្រកបដោយ និរន្តរភាព។ ជាក់ស្តែង **អគរ** បានដាក់បញ្ចូលសកម្មភាពការងារនេះក្នុងឯកសារយុទ្ធសាស្ត្រកែទម្រង់និងទំនើបកម្មគយ ២០២៤-២០២៨ និងផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំ។ ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្លាយជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗសម្រាប់ប្រទេសនានានៅទូទាំងពិភពលោក ដោយសារផលវិបាកនៃឧក្រិដ្ឋកម្មនេះ មិនត្រឹមតែបង្កហានិភ័យលើប្រព័ន្ធហិរញ្ញវត្ថុនិងសេដ្ឋកិច្ចរបស់ប្រទេសមួយទេ ប៉ុន្តែថែមទាំងអាចបង្កហានិភ័យលើសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ប្រសិនបើគោលដៅនៃការសម្អាតប្រាក់ជាការគាំទ្រដល់សកម្មភាពរបស់ក្រុមភេរវករ។ ម្យ៉ាងទៀត ក្នុងសម័យសាកលភាវូបនីយកម្ម និងបច្ចេកវិទ្យាជឿនលឿននេះ ក្រុមឧក្រិដ្ឋជនក៏បានប្រើវិធីសាស្ត្រថ្មីៗ និងមានឱកាសច្រើនក្នុងការសម្អាតប្រាក់ និងធ្វើប្រតិបត្តិការខុសច្បាប់កាន់តែស្មុគស្មាញ។ ហេតុដូចនេះ ការបន្តកិច្ចខិតខំលើកកម្ពស់សមត្ថភាពនិងជំនាញដល់មន្ត្រីគយនិងរដ្ឋាករដែលបម្រើការងារនៅជួរមុខតាមមាត់ច្រកព្រំដែន គឺជាកត្តាចាំបាច់បំផុតសម្រាប់រដ្ឋបាលគយ ដើម្បីអាចចូលរួមទប់ស្កាត់ និងប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មនេះ។

វគ្គបណ្តុះបណ្តាលបានដំណើរការទៅតាមកម្មវិធី ប្រកបដោយភាពជោគជ័យ និងការយកចិត្តទុកដាក់ខ្ពស់ តាមរយៈការចូលរួមកិច្ចពិភាក្សា និងផ្លាស់ប្តូរយោបល់ក្នុងក្រុម និងជាមួយគ្រូឧទ្ទេសនាម នៅតាមប្រធានបទនីមួយៗ យ៉ាងផុសផុល៕









ANTI
MONEY



# សិក្ខាសាលាស្ដីពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធគយ

នាថ្ងៃទី២១ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥ នៅសាលាជាតិគយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានរៀបចំសិក្ខាសាលាស្ដីពី "ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធគយ" ជូនដល់មន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធចំនួន ៥២រូប មកពីនាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករក្រោមឱវាទ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងស្របតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ នៃយុទ្ធសាស្ត្រនិងកម្មវិធីកំណែទម្រង់និងទំនើបកម្មរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រោមក្របខ័ណ្ឌផែនការថវិកាឆ្នាំ២០២៥ ដើម្បីអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ថ្លែងក្នុងពិធីបើកសិក្ខាសាលានេះ លោកអគ្គនាយករង **ចាន់ សុភាព** តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានបញ្ជាក់ពីគោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីធ្វើការផ្សព្វផ្សាយ និងចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងសមត្ថភាពរបស់មន្ត្រីគយនិងរដ្ឋាករកម្ពុជា តាមរយៈបទបង្ហាញរបស់មន្ត្រីជំនាញពីនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ និងនាយកដ្ឋានពាក់ព័ន្ធ ស្ដីពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធគយ កិច្ចសហប្រតិបត្តិការគយក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់មេគង្គ អង្គការគយពិភពលោក និងអង្គការពាណិជ្ជកម្មពិភពលោក។ គួរកត់សម្គាល់ថាការធ្វើសមាហរណកម្មយ៉ាងសកម្មរបស់កម្ពុជាទៅក្នុងតំបន់ និងពិភពលោកតាមរយៈការចូលជាសមាជិកអាស៊ាន អង្គការគយពិភពលោក អង្គការពាណិជ្ជកម្មពិភពលោក និងជាភាគីនៃកិច្ចព្រមព្រៀង និងអនុសញ្ញាជាច្រើនក្រោមក្របខ័ណ្ឌតំបន់និងពិភពលោក ដូចជា៖ កិច្ចព្រមព្រៀងអាស៊ានស្ដីពីគយ, កិច្ចព្រមព្រៀងស្ដីពីកិច្ចសម្រួលពាណិជ្ជកម្ម, អនុសញ្ញាអន្តរជាតិស្ដីពីសាមញ្ញកម្មនិងសុខដុមនីយកម្មនីតិវិធីគយ ជាដើម បានគាំទ្រដល់ការងារកែទម្រង់និងទំនើបកម្មគយ ជាពិសេសលើការងារសាមញ្ញកម្មនិងទំនើបកម្មនីតិវិធីគយ សំដៅពង្រឹងការអនុវត្តតួនាទីគន្លឹះរបស់រដ្ឋបាលគយរួមមាន៖ ការប្រមូលចំណូល, កិច្ចសម្រួលពាណិជ្ជកម្ម, និងការពារសន្តិសុខសុវត្ថិភាពសង្គម។

លោកអគ្គនាយករង ក៏បានលើកឡើងពីសារៈសំខាន់ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មី និងការទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលមានស្រាប់ ក្នុងការជំរុញការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្នភាពធន់និងចីរភាព។ បច្ចុប្បន្នកម្ពុជា បាននិងកំពុងអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី និងទ្វេភាគី ចំនួន ១១ រួមមាន៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA), អាស៊ាន-ចិន, អាស៊ាន-កូរ៉េ, អាស៊ាន-ឥណ្ឌា, អាស៊ាន-ជប៉ុន, អាស៊ាន-អូស្ត្រាលី/នូវែលសេឡង់, អាស៊ាន-ហុងកុង កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ (RCEP), កម្ពុជា-ចិន, កម្ពុជា-កូរ៉េខាងត្បូង, និងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម។ ចំណូលពន្ធគយដែលបាត់បង់ប្រចាំឆ្នាំពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបានកើនឡើងជាលំដាប់ ជាក់ស្ដែងនៅឆ្នាំ២០២៣ ចំណូលពន្ធគយបានបាត់បង់ប្រមាណ ៣៨៤,៥៩ លានដុល្លារអាម៉េរិក និងក្នុងឆ្នាំ២០២៤ ការបាត់បង់ចំណូលពន្ធគយបានកើនដល់ ៤១៥,៨២ លានដុល្លារអាម៉េរិក។ កំណើននេះបញ្ជាក់ឱ្យឃើញថា ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅកម្ពុជាកាន់តែមានភាពទូលំទូលាយ ដោយសារការយល់ដឹងពីផលចំណេញពីការនាំចូលក្រោមរបបអនុគ្រោះជាច្រើន។

ជាចុងបញ្ចប់ លោកអគ្គនាយករងបានផ្ដាំផ្ញើ និងលើកទឹកចិត្តឱ្យសិក្ខាកាមទាំងអស់ ចូលរួមសកម្មក្នុងការសិក្សាស្វែងយល់ ពិភាក្សា និងចែករំលែកនូវបទពិសោធន៍ទៅវិញទៅមកក្នុងគោលបំណងដើម្បីទទួលបាននូវលទ្ធផលផ្លែផ្កាដ៏ល្អពីវគ្គសិក្ខាសាលានេះ។












# សិក្ខាសាលាស្តីពីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត

នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥ នៅសាលាជាតិគយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានរៀបចំសិក្ខាសាលាស្តីពីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត(AEO) ដើម្បីផ្សព្វផ្សាយ ក៏ដូចជាលើកកម្ពស់ការយល់ដឹងអំពីកម្មវិធី AEO និងពន្យល់ពីអត្ថប្រយោជន៍នៃការទទួលបានសិទ្ធិជា AEO ដែលនឹងចូលរួមដល់ការពង្រឹងអនុលោមភាព កិច្ចសម្រួលពាណិជ្ជកម្ម ក៏ដូចជាការពង្រឹងសន្តិសុខខ្សែប្រវាក់ផ្គត់ផ្គង់កម្ពុជា និងពិភពលោកផងដែរ។ ជាក់ស្តែងកម្មវិធី AEO គឺជាកម្មវិធីស្ម័គ្រចិត្តដែលផ្តល់អត្ថប្រយោជន៍ជាច្រើនដល់វិស័យសាធារណៈផង និងវិស័យឯកជនផង ជាពិសេស សម្រួលដល់ការបំពេញបែបបទគយសម្រាប់ធុរជនដែលមានអនុលោមភាពល្អ។ កម្មវិធីបើកសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (AEO Program) បានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់លោក **ផា អេងម៉េង** អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អមដោយលោកនាយកសាលាជាតិគយ លោក-លោកស្រីអនុប្រធាននាយកដ្ឋានតំណាងឱ្យនាយកដ្ឋាននៃអង្គភាព **អគរ** ពាក់ព័ន្ធ និងមានការអញ្ជើញចូលរួមពីតំណាង JICA Expert, តំណាងសភាពាណិជ្ជកម្មកម្ពុជា តំណាងសមាគមភស្តុភារកម្មកម្ពុជា តំណាងសមាគមពាណិជ្ជករដឹកជញ្ជូននិងខ្សែប្រវាក់ផ្គត់ផ្គង់នៅកម្ពុជា ក្រុមហ៊ុន AEO ក្រុមហ៊ុនដែលកំពុងស្នើសុំ AEO ក្រុមហ៊ុនជាសមាជិកក្រុមធុរជនល្អបំផុត (Best Traders Group Membership) ក្រុមហ៊ុនដើងសាគយ និងធុរជនពាក់ព័ន្ធនានាផ្សេងទៀតដែលមានចំនួនសរុបប្រមាណ ៧០ រូប។

ថ្លែងក្នុងពិធីបើក លោកអគ្គនាយករង បានលើកឡើងអំពីសាវតាមួយចំនួនស្តីពីការបង្កើតកម្មវិធី AEO នៅកម្ពុជាដោយសង្ខេបដូចតទៅ៖

- **ឆ្នាំ២០០៥៖** ប្រទេសកម្ពុជា រួមជាមួយនឹងសមាជិក WCO ផ្សេងទៀត បានចុះហត្ថលេខាលើលិខិតបញ្ជាក់បំណងមួយ (Letter of Intent) ដើម្បីអនុវត្តក្របខ័ណ្ឌស្តង់ដា ធានាសុវត្ថិភាព និងសម្រួលដល់ពាណិជ្ជកម្មសកលរបស់អង្គការគយពិភពលោក។ សសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបីនៃក្របខ័ណ្ឌនេះ គឺការបង្កើតភាពជាដៃគូរវាងរដ្ឋបាលគយ និងវិស័យឯកជន។
- **ឆ្នាំ២០០៩៖** ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការយល់ដឹងរវាងរដ្ឋបាលគយ និងវិស័យឯកជន **អគរ** បានបង្កើតយន្តការភាពជាដៃគូផ្នែកគយ-ឯកជន (CPPM)។
- **ឆ្នាំ២០១៣៖** ផ្អែកលើ CPPM អគរ បានបង្កើតយន្តការលើកទឹកចិត្តធុរជនល្អបំផុត (BTIM) ដោយផ្តល់នូវការលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាព ជាគំរូសម្រាប់អាជីវកម្មផ្សេងទៀតដើម្បីកែលម្អ វប្បធម៌ និង ក្រមសីលធម៌សារពើពន្ធ។ គំនិតផ្តួចផ្តើមទាំងនេះ បានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតឱ្យមានលក្ខណៈពេញលេញស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិ។
- **ឆ្នាំ២០១៦៖** កម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងសម្របសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO-TFA)។ ក្នុងនាមជាប្រទេសហត្ថលេខី កម្ពុជាមានកាតព្វកិច្ចគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង រួមទាំងការបង្កើតប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។
- **ឆ្នាំ២០២៣៖ អគរ** បានបង្កើតកម្មវិធី AEO តាមរយៈ

ប្រកាសលេខ ២០៩ សហវ.ប្រក.អគរ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ស្តីពីកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។ ទន្ទឹមនឹងនេះ អង្គភាពAEO ក៏ត្រូវបានបង្កើតឡើងផងដែរដើម្បីអនុវត្តយុទ្ធសាស្ត្រស្តីពីAEO។

- បច្ចុប្បន្ន ក្រុមហ៊ុនចំនួន៧ ត្រូវបានទទួលស្គាល់ជាAEOរួមមាន៖ ១. MINEBEA (CAMBODIA) CO., LTD ២. HUAWEI TECHNOLOGIES CAMBODIA CO., LTD ៣. GGEAR GROUP CO., LTD ៤. DENSO (CAMBODIA) CO., LTD ៥. ZUELLIG PHARMA LTD ៦. CART TIRE CO., LTD និង ៧. COFFEE CONCEPTS (CAMBODIA) CO., LTD។

លោកអគ្គនាយករង បានគូសបញ្ជាក់ថែមទៀតថា បច្ចុប្បន្ន កម្មវិធីនេះកំពុងទទួលបានការចាប់អារម្មណ៍ខ្លាំង ហើយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានទទួលពាក្យស្នើសុំពីក្រុមហ៊ុនវិស័យឯកជនជាច្រើនដើម្បីចូលជាសមាជិកប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ដែលធ្វើឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា យកចិត្តទុកដាក់លើការអនុវត្តកម្មវិធីនេះ និងមានភាពជឿទុកចិត្តថា អត្ថប្រយោជន៍នានាដែលមានចែងក្នុងកម្មវិធី AEO គឺពិតជាដំណោះស្រាយដ៏មានប្រសិទ្ធភាព ឆ្លើយតបទៅនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក៏ដូចជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងកិច្ចសម្រួលពាណិជ្ជកម្ម និងការលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពល្អ។ លោកអគ្គនាយករង បានស្នើឱ្យបណ្តាក្រុមហ៊ុនវិស័យជន ខិតខំរៀបចំកែលម្អប្រតិបត្តិការធុរកិច្ចរបស់ខ្លួនស្របតាមបទប្បញ្ញត្តិនិងនីតិវិធីសម្រាប់ការអនុវត្តកម្មវិធីនេះ ជាពិសេសបទដ្ឋានសុវត្ថិភាពអន្តរជាតិ WCO SAFE Framework of Standards (FoS) ដើម្បីចូលរួមពង្រឹងអនុលោមភាព បង្កើនកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ ទទួលបានកិច្ចសម្រួលពាណិជ្ជកម្ម និងពង្រឹងសន្តិសុខខ្សែច្រវាក់ផ្គត់ផ្គង់ពិភពលោកផង ដើម្បីសម្រេចបានបេសកកម្មរួម គឺភាពប្រកួតប្រជែងរបស់កម្ពុជា ការប្រមូលចំណូល សុខសុវត្ថិភាពសង្គម និងលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព។





















ANNEX IV : AEO CONDITIONS, REQUIREMENTS AND BENEFITS





# សិក្ខាសាលាសមាគមសភាពាណិជ្ជកម្មឥណ្ឌានៅកម្ពុជាស្ដីពីរដ្ឋបាលគយកម្ពុជាឆ្នាំ២០២៥ "Breakfast Talk on Cambodia Customs 2025"

នៅព្រឹក ថ្ងៃអង្គារ ២រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ នៅអគារ GIA Tower, លោក **ផា អេងថេង** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាស្ដីពីរដ្ឋបាលគយកម្ពុជាឆ្នាំ២០២៥ "Breakfast Talk on Cambodia Customs 2025" រៀបចំដោយសមាគមសភាពាណិជ្ជកម្មឥណ្ឌានៅកម្ពុជា សហការជាមួយក្រុមហ៊ុន DFDL Cambodia។ កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីជម្រាបអំពីវឌ្ឍនភាពថ្មីៗនៃការអនុវត្តនីតិវិធីគយ និងមានការចូលរួមពីលោក Ricchpal Singh លេខាទីមួយនៃស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជា, លោក **Diberjohn Balinas** ដៃគូនៃក្រុមហ៊ុន DFDL Cambodia និងធុរជនប្រកបអាជីវកម្មនៅកម្ពុជាសរុបប្រមាណ ៦០ រូប។

ថ្លែងក្នុងមតិចំណាប់អារម្មណ៍ លោកអគ្គនាយករង បានថ្លែងអំណរគុណដល់សមាគមសភាពាណិជ្ជកម្មឥណ្ឌានៅកម្ពុជាដែលបានផ្ដួចផ្ដើមរៀបចំសិក្ខាសាលា និងបានគូសរំលេចពីសារៈសំខាន់នៃសិក្ខាសាលានេះក្នុងការលើកកម្ពស់ការយល់ដឹងរបស់ធុរជន ដែលស្របគ្នាទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**)។ លោកអគ្គនាយករង បានរំលឹកអំពីយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាប្រឈមនានារបស់ផ្នែកឯកជន ក៏ដូចជា ការចូលរួមរបស់ **អគរ** ក្នុងសិក្ខាសាលា និងវេទិកាពិភាក្សានានា ដើម្បីដោះដូរព័ត៌មាន និង លើកកម្ពស់ការយល់ដឹងរបស់ផ្នែកឯកជន ក្នុងន័យកែលម្អបរិយាកាសធុរកិច្ចនៅកម្ពុជា និងលើកកម្ពស់អនុលោមភាពច្បាប់។

លោកអគ្គនាយករង បានធ្វើបទបង្ហាញដល់អង្គពិធីអំពីព័ត៌មានទូទៅរបស់រដ្ឋបាលគយកម្ពុជា, ការងារទំនើបកម្ម និងស្វ័យប្រវត្តិកម្មនីតិវិធីគយ, ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគាំទ្រដល់កិច្ចប្រតិបត្តិការរបស់គយ, និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលកម្ពុជាជាសមាជិក។ បន្ថែមពីនោះ លោកអគ្គនាយករង ក៏បានជម្រាបអំពីវឌ្ឍនភាពក្នុងការធ្វើវិសោធនកម្មច្បាប់ស្ដីពីគយ,ការអនុវត្តវិធានការដើម្បីពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងអនុលោមភាពលើការនាំចូលធាតុចូលផលិតកម្មសម្រាប់បម្រើឱ្យខ្សែច្រវាក់ផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាពិសេសលើគម្រោងផលិតនាំចេញទៅសហរដ្ឋអាម៉េរិក, ការអនុវត្តពន្ធបដិការរបស់សហរដ្ឋអាម៉េរិកលើកម្ពុជា, និងការអនុវត្តពន្ធ 0% សម្រាប់ទំនិញមានដើមកំណើត និងនាំចូលពីសហរដ្ឋអាម៉េរិក។

បន្ទាប់ពីបទបង្ហាញរបស់លោក **Diberjohn Balinas** ស្ដីពីវឌ្ឍនភាពថ្មីៗនៃការអនុវត្តនីតិវិធីគយ មានវេទិកាសំណួរ-ចម្លើយ ដែលក្នុងនោះមានការលើកជាសំណួរដល់វាគ្មិនទាំងពីររូប ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (AEO) និងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ (PCA)។


Q&A Session
Q
&
A








Q&A Session
Q
&
A

Q&A Session
Q
&
A

# វគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធ" សម្រាប់មន្ត្រីគយនិងរដ្ឋាករ

ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃចន្ទ ៨រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យប្រតិវេទន៍គយនិងឯកសារពាក់ព័ន្ធ"សម្រាប់មន្ត្រីគយនិងរដ្ឋាករដែលមានរយៈពេល១ថ្ងៃពេញនៅសាលាជាតិគយ ដោយប្រកាសបើកក្រោមអធិបតីភាព លោក **ផា អេងវ៉េង** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានការចូលពីមន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធសរុបប្រមាណ ៦០រូប។ គោលបំណងសំខាន់នៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីពង្រឹងសមត្ថភាពមន្ត្រីគយនិងរដ្ឋាករក្នុងការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យប្រតិវេទន៍គយនិងឯកសារពាក់ព័ន្ធ សំដៅលើកកម្ពស់គុណភាពទិន្នន័យសម្រាប់ការផលិតស្ថិតិ និងការវិភាគផ្សេងៗទៀត។

ថ្លែងក្នុងពីធីបើកវគ្គបណ្តុះបណ្តាលនេះ លោកអគ្គនាយករង **ផា អេងវ៉េង** បានគូសបញ្ជាក់ថា ក្នុងយុគសម័យឌីជីថល ទិន្នន័យបានក្លាយជាទ្រព្យយុទ្ធសាស្ត្រដ៏មានតម្លៃ និងមានសក្តានុពលដ៏សម្បើម ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ទៅលើគុណភាព។ កន្លងមកទិន្នន័យនិងស្ថិតិដែលកត់ត្រា និងផលិតដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានដើរតួយ៉ាងសំខាន់ និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ សម្រាប់ជាមូលដ្ឋានក្នុងការសម្រេចចិត្តសំខាន់ៗដូចជា ការវិភាគនិន្នាការពាណិជ្ជកម្ម ការវាយតម្លៃអំពីផលប៉ះពាល់នៃគោលនយោបាយពន្ធ និងការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិជាដើម។

តាមរយៈវគ្គបណ្តុះបណ្តាលនេះ លោកអគ្គនាយករងបានលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ ឱ្យយកចិត្តទុកដាក់ត្រងត្រាប់ស្តាប់ ស្វែងយល់ ក៏ដូចជាចូលរួមឱ្យបានផុលផុសក្នុងការពិភាក្សា និងចែករំលែកបទពិសោធន៍ល្អៗ ដោយជឿជាក់ថាវគ្គបណ្តុះបណ្តាលនេះនឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់គុណភាពទិន្នន័យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឱ្យកាន់តែល្អប្រសើរ។














# សិក្ខាសាលាស្តីពី "នីតិវិធីនៃការប្រមូលទិន្នន័យនិងចងក្រងស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ" សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃអង្គារ ៩រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានរៀបចំសិក្ខាសាលាស្តីពី "នីតិវិធីនៃការប្រមូលទិន្នន័យនិងចងក្រងស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ" សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមានរយៈពេល ១ថ្ងៃពេញ នៅសាលាជាតិគយ ដោយប្រកាសបើកក្រោមអធិបតីភាព លោកបណ្ឌិត **ឈន ឡឿន** នាយកសាលាជាតិគយ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយកដ្ឋានមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានការចូលពីមន្ត្រីជំនាញសរុបប្រមាណ ៣៥រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ១៣។ គោលបំណងសំខាន់នៃសិក្ខាសាលានេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីនៃការរៀបចំ ការផ្ទៀងផ្ទាត់ទិន្នន័យ ស្តង់ដាចំណាត់ថ្នាក់នានា និងវិធីសាស្ត្រក្នុងការផលិតស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ និងស្ថិតិពាក់ព័ន្ធ ដើម្បីធានាថាទិន្នន័យស្ថិតិត្រូវបានប្រើប្រាស់ចំគោលដៅ ប្រកបដោយប្រសិទ្ធភាព និងសង្គតិភាព។

ថ្លែងក្នុងពិធីបើកសិក្ខាសាលានេះ លោកបណ្ឌិត **ឈន ឡឿន** បានលើកឡើងថា **អគរ** គឺជាអង្គភាពស្ថិតិផ្លូវការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវក្នុងការប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយដល់សាធារណជននូវស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិផ្លូវការ រៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ។ ស្ថិតិផ្លូវការនេះ រួមចំណែកយ៉ាងសំខាន់ក្នុងការរៀបចំគោលនយោបាយនានាជាពិសេសគោលនយោបាយសេដ្ឋកិច្ចជាតិ ដោយវាផ្តល់នូវសូចនាករច្បាស់លាស់សម្រាប់គាំទ្រដល់ការសម្រេចចិត្តបានត្រឹមត្រូវ។ ស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ ត្រូវបានរៀបចំ និងផលិតទៅតាមដំណាក់កាលសំខាន់ៗ ជាច្រើន ស្របតាមមគ្គុទេសក៍របស់អង្គការសហប្រជាជាតិ និងឧត្តមានុវត្តជាអន្តរជាតិមួយចំនួនទៀត ដើម្បីធានាឱ្យបាននូវសង្គតិភាព និងគុណភាពដែលអាចជឿជាក់បាន។

តាមរយៈសិក្ខាសាលានេះ លោកនាយកសាលាជាតិគយក៏បានលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ ចូលរួមឱ្យបានផុលផុសស្វែងយល់ ពិភាក្សា និងចែករំលែកបទពិសោធន៍ល្អៗ ដើម្បីជួយកែលម្អការរៀបចំ និងផលិតស្ថិតិនេះ ឱ្យកាន់តែមានគុណភាពខ្ពស់ស្របតាមតម្រូវការប្រើប្រាស់របស់ក្រសួង-ស្ថាប័ននីមួយៗ និងជឿជាក់ថាសិក្ខាសាលានេះនឹងក្លាយជាវេទិកាដើម្បីផ្សារភ្ជាប់ទំនាក់ទំនងកាន់តែស្អិតរមួតរវាងមន្ត្រីជំនាញពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបន្តការគាំទ្រគ្នាទៅវិញទៅមក លើការផលិត និងប្រើប្រាស់ទិន្នន័យស្ថិតិនេះ។
















# ផ្នែកទី៣

## លទ្ធផលការងារសម្រេចបានមួយចំនួន
## របស់បណ្ដានាយកដ្ឋាន និងអង្គភាពមូលដ្ឋាន

# ការងារគ្រប់គ្រងហិរញ្ញវត្ថុនិងបុគ្គលិក

នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារហិរញ្ញវត្ថុនិងបុគ្គលិក ដែលគ្រប់គ្រងលើការងារផ្នែករដ្ឋបាល បុគ្គលិក គណនេយ្យ ហិរញ្ញវត្ថុ និង ការអភិវឌ្ឍស្ថាប័នរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ក្រោមការដឹកនាំរបស់លោក **ខ៊ូ វណ្ណា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានអនុវត្តការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

នាព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥ នៅសាលប្រជុំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាន់ទី៩ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានប្រារព្ធពិធីប្រកាសតែងតាំងនិងផ្ទេរភារកិច្ចមន្ត្រីរាជការគយនិងរដ្ឋាករ ចំនួន ១៩ នាក់ ក្រោមអធិបតីភាពរបស់ លោក **ខ៊ូ វណ្ណា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអមដោយលោកអនុប្រធាននាយកដ្ឋាន ជំនួយការនាយកដ្ឋាន ប្រធានការិយាល័យ និងក្រុមការងាររបស់នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក។ ក្នុងពិធីខាងលើ លោកប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិកបានមានមតិណែនាំដល់មន្ត្រីទើបទទួលភារកិច្ចថ្មី ត្រូវខិតខំបំពេញការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ជាពិសេសលើការងារប្រមូលចំណូលចូលថវិកាជាតិ។



នាព្រឹក ថ្ងៃចន្ទ ទី១ ខែកញ្ញា ឆ្នាំ២០២៥ នៅបន្ទប់ប្រជុំជាន់ទី១៨ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អមដោយលោក លោកស្រីអគ្គនាយករង ប្រធាននាយកដ្ឋាន នាយកសាលាជាតិគយ ប្រធានសាខា និងមន្ត្រីជំនាញ បានអញ្ជើញចូលរួមកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធវីឌេអូ Zoom Meeting ដើម្បីពិនិត្យលើលទ្ធផលនៃការបូកសរុបការងារនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កន្លងមកនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានសហការជាមួយអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងអនុលោមតាមសេចក្តីណែនាំលេខ ០១ សណនចុះថ្ងៃទី២១ខែឧសភាឆ្នាំ២០២៤ស្តីពីការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធនៃក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល។









ដើម្បីឱ្យស្របតាមច្បាប់ បទប្បញ្ញត្តិ និងឧត្តមានុវត្ត អន្តរជាតិនាពេលបច្ចុប្បន្ន ជាពិសេសប្រកាសលេខ ២១០ សហវ.ប្រក.អល ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ ស្តីពី ក្រមសីលធម៌វិជ្ជាជីវៈបុគ្គលិក-មន្ត្រីរាជការ នៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានធ្វើបច្ចុប្បន្នភាពក្រមសីលធម៌ និងកិរិយាមាយាទ មន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា (ឆ្នាំ២០០៦) ដោយបាន ផ្លាស់ប្តូរឈ្មោះមកជា "ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការ គយនិងរដ្ឋាករកម្ពុជា" និងខ្លឹមសារសំខាន់ៗមួយចំនួន។ សេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករ កម្ពុជា (ឆ្នាំ២០២៥) នេះ ត្រូវបានពិនិត្យ និងកែសម្រួល ចុងក្រោយ ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអមដោយ មន្ត្រី

នាពេលព្រឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៥ នៅ បន្ទប់ប្រជុំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាន់ទី១៨ ដោយមានការចូលរួមពីលោក លោកស្រីអគ្គ-នាយករង លោកប្រធាននាយកដ្ឋាន លោកនាយកសាលាជាតិគយ លោក លោកស្រីអនុប្រធាននាយកដ្ឋាន លោក លោកស្រី ប្រធានការិយាល័យ និងមន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធ។

បច្ចុប្បន្ន ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករ កម្ពុជា បានទទួលការឯកភាពពី ឯកឧត្តមអគ្គបណ្ឌិតចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសភាក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដាក់ឱ្យមន្ត្រីគយនិងរដ្ឋាករ គ្រប់ជាន់ថ្នាក់ អនុវត្តជាផ្លូវការគិតចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ នេះតទៅ។













អនុវត្តតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លោក **សុខ ទ្រី** និងលោក **ជា សំអុន** បានដឹកនាំក្រុមការងារនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក ចុះពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងារសាងសង់អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ របស់អង្គភាពគយនិងរដ្ឋាករដូចខាងក្រោម៖







១. នាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការធានាគុណភាពនៃការងារសាងសង់អគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្រាប់សាខាគយនិងរដ្ឋាករខេត្តកំពង់ធំ។

២. នាថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការធានាគុណភាព នៃការងារសាងសង់អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្រាប់សាខាគយនិងរដ្ឋាករខេត្តមណ្ឌលគិរី និងត្រួតពិនិត្យ វាយតម្លៃលទ្ធផលនៃការងារសាងសង់ដើម្បីធ្វើការប្រគល់-ទទួលអគាររដ្ឋបាលអគារស្នាក់នៅនិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់សាខាគយនិងរដ្ឋាករខេត្តក្រចេះ។

៣. នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការធានាគុណភាពនៃការងារសាងសង់អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្រាប់ការិយាល័យ

គយនិងរដ្ឋាករបុសមន ព្រមទាំងត្រួតពិនិត្យវាយតម្លៃលទ្ធផលនៃការងារសាងសង់ដើម្បីធ្វើការប្រគល់ទទួលអគាររដ្ឋបាលអគារស្នាក់នៅនិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករដូងខេត្តស្វាយរៀង។

៤. នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យនិងវាយតម្លៃបញ្ចប់លទ្ធផលនៃការងារសាងសង់អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដើម្បីធ្វើការប្រគល់ទទួលសម្រាប់ការិយាល័យគយនិង រដ្ឋាករព្រៃវល្លិ៍ ព្រមទាំងបានត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់លទ្ធផលនៃការងារសាងសង់ អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិង រដ្ឋាករកោះរកា។

៥. នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យនិងវាយតម្លៃបញ្ចប់លទ្ធផលនៃការងារសាងសង់អគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដើម្បីធ្វើការប្រគល់-ទទួលសម្រាប់ការិយាល័យគយនិងរដ្ឋាករដូងខេត្តបាត់ដំបង ព្រមទាំងបានត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការធានាគុណភាពនៃការងារសាងសង់អគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករអូររំដួល។

៦. នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគារស្នាក់នៅកម្ពស់១៤ជាន់ ក្នុងក្រុងព្រះសីហនុ ដែលការងារសាងសង់សម្រេចបានប្រមាណ ៨៥% នៃការងារទាំងមូល។

៧. នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគាររដ្ឋបាលកម្ពស់ ៣ជាន់ សម្រាប់សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ដែលជារួមការងារ សម្រេចបានប្រមាណ ៤០% នៃការងារទាំងមូល។

៨.នាថ្ងៃទី២៥ខែសីហាឆ្នាំ២០២៥៖បានចុះត្រួតពិនិត្យនិងវាយតម្លៃបញ្ចប់លទ្ធផលនៃការងារសាងសង់អគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនា សម្ព័ន្ធផ្សេងៗដើម្បីធ្វើការប្រគល់-ទទួលសម្រាប់សាខា គយនិងរដ្ឋាករខេត្តកណ្តាល។

៩. នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៥៖ មានការ បើកការដ្ឋានសាងសង់អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធ











ផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករតន់ហាន់។

១០. នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៥៖ មានការបើកការដ្ឋានសាងសង់អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករអូរយ៉ាដាវ។

១១. នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៥៖ មានការបើកការដ្ឋានសាងសង់អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករត្រពាំងក្រៀល។

១២. នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៥៖ មានការបើកការដ្ឋានសាងសង់អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករស្រែអំបិល។

១៣. នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥៖ មានការ បើកការដ្ឋានសាងសង់អគាររដ្ឋបាលថ្មី អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់សាខាគយនិងរដ្ឋាករខេត្តកំពត។

ក្នុងអំឡុងពេលចុះត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងារសាងសង់ខាងលើ ក្រុមការងារ បានពិនិត្យឃើញកន្លែងខ្វះខាតមួយចំនួនក្នុងការសាងសង់ និងបានណែនាំឱ្យក្រុមហ៊ុនសាងសង់កែលម្អបន្ថែម និងត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការបន្តសាងសង់ឱ្យស្របតាមបទដ្ឋានបច្ចេកទេស និងតាមផែនការដែលបានគ្រោងទុក។











# ការងារផែនការនិងបច្ចេកទេស

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៥ នេះ នាយកដ្ឋានផែនការ និងបច្ចេកទេស បានរៀបចំវគ្គបណ្តុះបណ្តាល វគ្គផ្សព្វផ្សាយ ដូចមានរៀបរាប់ខាងក្រោម៖

១. វគ្គបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណផលិតផល ជូនមន្ត្រីគយនិងរដ្ឋាករជាប់ព្រំដែនផ្លូវគោកជាមួយប្រទេសថៃ ចំនួន ២០រូប នាថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ នៅខេត្តសៀមរាប។ សិក្ខាសាលានេះ មានគោលបំណងបង្កើនចំណេះដឹងអំពីការកំណត់អត្តសញ្ញាណផលិតផល ដែលជាប់កម្មសិទ្ធិបញ្ញា និងស្វែងយល់ពីការបែងចែកភាពខុសគ្នារវាងផលិតផលពិត និងផលិតផលក្លែងក្លាយ។





២. ផ្សព្វផ្សាយសេចក្តីណែនាំពីនីតិវិធីនៃការស្នើសុំអនុវត្តអត្រាពន្ធ 0% ចំពោះទំនិញផលិតនៅអាមេរិក នាំចូលមកកម្ពុជា ពីអាមេរិក នៅបន្ទប់ប្រជុំ **អគរ** ជាន់ទី ៩ ដោយមានការចូលរួមដោយផ្ទាល់ពីវិស័យឯកជន រួមមានធុរជនជាអ្នកនាំចូល ជើងសាគយ និងបុគ្គលពាក់ព័ន្ធ ចំនួន ១៣៦នាក់ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធ តាមប្រព័ន្ធអនឡាញ Zoom នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥។










៣. ផ្សព្វផ្សាយតាមប្រព័ន្ធវីដេអូ ស្ដីពីការដាក់ឱ្យអនុវត្តជាផ្លូវការមុខងារប្រតិវេទន៍តម្លៃគិតពន្ធគយសង្ខេប ក្នុង CVDS ដោយមានការចូលរួមពីមន្ត្រីគយនិងរដ្ឋាករនៃនាយកដ្ឋានផែនការនិងបច្ចេកទេស លេខាធិការដ្ឋាន នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន មន្ត្រីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយក្រោមក្របខ័ណ្ឌវិម្សការ ពីបណ្ដានាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករទូទាំងប្រទេសសរុបប្រមាណ ១១០រូបនាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥។






៤. ផ្សព្វផ្សាយសេចក្ដីណែនាំអំពីការពង្រឹងការគ្រប់គ្រងមុខទំនិញដែលតម្រូវឱ្យមានបញ្ជាក់លេខ Serial Number នៅពេលនាំចូល នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៥ ជូនដល់មន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធ ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងការនាំចូលមុខទំនិញគ្រឿងអេឡិចត្រូនិក និងគ្រឿងម៉ាស៊ីនមួយចំនួន។







# ការងាររបបគយ

នាយកដ្ឋានរបបគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការងាររបបគយ និងមានការិយាល័យក្រោមឱវាទចំនួនបួនដូចខាងក្រោម៖

- ការិយាល័យត្រួតពិនិត្យ
- ការិយាល័យគ្រប់គ្រងវិនិយោគកាត់ដេរ
- ការិយាល័យគ្រប់គ្រងវិនិយោគមិនមែនកាត់ដេរ
- ការិយាល័យរដ្ឋបាលនិងគ្រប់គ្រង។

ក្រោមការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងមុតមាំរបស់ លោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបបគយ និងមានការចូលរួមយ៉ាងសកម្មពីមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ នាយកដ្ឋានរបបគយបាន លទ្ធផលការងារ និងសកម្មភាពសំខាន់ៗមួយចំនួនដូចជា៖

### ១. ការងារជំនាញ

- នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ នាយកដ្ឋានរបបគយ បានទទួលចំណូលពីការបង់ពន្ធនិងអាករលើមុខទំនិញជាប្រភេទយានយន្តដែលបាននាំចូលបណ្ដោះអាសន្នក្រោមរបបប្រវេសន៍កាលិកបង្វែរជាការនាំចូលស្ថាពរប្រើប្រាស់ក្នុងស្រុក ដែលមានទឹកប្រាក់ពន្ធនិងអាករ និងកម្រៃសរុបចំនួន ៤៤៥,២៧៩,៦០០ រៀល។
- ការពិនិត្យ និងផ្ដល់យោបល់ចំពោះឯកសារគម្រោងវិនិយោគ (បញ្ជីមេ) បានចូលរួមពិនិត្យសំណើសុំនាំចូលរបស់ គលក នូវសម្ភារៈសំណង់ គ្រឿងម៉ាស៊ីន វត្ថុធាតុដើម សារធាតុគីមី និងសម្ភារៈផ្សេងៗ សរុបចំនួន ៤០៤ សំណើ ស្មើនឹងទឹកប្រាក់ ៩,០០១,៩៤៩,៥៧៤.២០ USD។

### ២. សកម្មភាពចូលរួមប្រជុំរបស់លោក ម៉ុន ជីវ ប្រធាននាយកដ្ឋានរបបគយ

- ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥ លោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបបគយ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋាន ដោយមានការចូលរួមពីលោកអនុប្រធាននាយកដ្ឋាន លោកប្រធានការិយាល័យ លោកស្រីជំនួយការនាយកដ្ឋាន និងមន្ត្រីក្រោមឱវាទ ដើម្បីណែនាំលើការពង្រឹងប្រសិទ្ធភាពនិងពន្លឿនការពិនិត្យមើលសេចក្ដីព្រាងបញ្ជីមេ និងការចេញលិខិតអនុញ្ញាតគយតាមប្រព័ន្ធបញ្ជរតែមួយជាតិ និងការងារផ្សេងៗមួយចំនួនទៀត ។





- ថ្ងៃទី២៧ខែសីហាឆ្នាំ២០២៥នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) លោកអគ្គនាយករង **ផា អេងម៉េង** អមដោយលោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបបគយ និងមន្ត្រីនាយកដ្ឋានពាក់ព័ន្ធ បានចូលរួមកិច្ចប្រជុំពិភាក្សាលើ៖ (១) សំណើសុំនាំចូលរថយន្ត ២,៥០០ គ្រឿង ដោយបន្ថយ អត្រាពន្ធអាករ ៨០% តាមក្របខណ្ឌ FTA របស់ក្រុមហ៊ុន RMA Automotive (Cambodia) Co., Ltd.

និង (២) សំណើសុំពន្យារគោលការណ៍ IKD1 រហូតដល់ឆ្នាំ២០២៩ របស់ក្រុមហ៊ុន Toyota Tsusho Manufacturing (Cambodia) Co., Ltd។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ កសហវ ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានពន្ធដារ។





- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម លោក **ម៉ុន ឌីទ** ប្រធាននាយកដ្ឋានរបបគអមដោយមន្ត្រីនាយកដ្ឋានរបបគយ បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ របស់ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់ការនាំចេញនិងកិច្ចសម្រួលពាណិជ្ជកម្ម ក្រុម "ធ" នៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន ក្រោមអធិបតីភាព លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧកញ៉ា **គួច ផេង** ជាសហប្រធាននៃក្រុមការងារ "ធ" ដោយមានការចូលរួមពីតំណាងអន្តរក្រសួងស្ថាប័នពាក់ព័ន្ធ។






- ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក **ម៉ុន ឌីទ** ប្រធាននាយកដ្ឋានរបបគយ អមដោយមន្ត្រីនាយកដ្ឋានរបបគយ បានចូលរួមកិច្ចប្រជុំលើកទី១០ នៃគណៈកម្មការអន្តរក្រសួងចរចាកិច្ចព្រមព្រៀងសម្បទានផ្លូវដែក ដើម្បីពិនិត្យលើសេចក្តីព្រាងក្របខណ្ឌស្តីពីការជ្រើសរើសដៃគូយុទ្ធសាស្រ្តសម្រាប់គម្រោងផ្លូវដែកជាតិនិងពិភាក្សាលើចំណុចពាក់ព័ន្ធមួយចំនួនទៀត។ កិច្ចប្រជុំនេះ ដឹកនាំដោយឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលោកជំទាវ **ភុយ សុដានី** រដ្ឋលេខាធិការប្រចាំការក្រសួងសាធារណការនិងដឹកជញ្ជូន ដោយមានការចូលរួមពីតំណាងស្ថាប័នពាក់ព័ន្ធ។





- ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) លោកអគ្គនាយករង **ផា អេងម៉េង** អមដោយលោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបបគយ និងមន្ត្រីនាយកដ្ឋានពាក់ព័ន្ធបានចូលរួមកិច្ចប្រជុំពិភាក្សាលើៈ (១) សំណើសុំនាំចូលរថយន្ត ២,៥០០ គ្រឿង ដោយបន្ថយអត្រាពន្ធអាករ ៨០% តាមក្របខណ្ឌ FTA របស់ក្រុមហ៊ុន RMA Automotive (Cambodia) Co.,Ltd. និង (២) សំណើសុំពន្យារគោលការណ៍ IKD1 រហូតដល់ឆ្នាំ២០២៩ របស់ក្រុមហ៊ុន Toyota Tsusho Manufacturing (Cambodia) Co., Ltd។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ កសហវ ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានពន្ធដារ។





- ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) លោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបបគយ អមដោយមន្ត្រីនាយកដ្ឋានរបបគយ បានចូលរួមកិច្ចប្រជុំលើកទី១ ក្រុមការងារ កសហវ សម្រាប់តាមដាននិងត្រួតពិនិត្យកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន នៃគម្រោងព្រែកជីកហ្វូណនតេជោ។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម **មាស សុខសេនសាន** រដ្ឋលេខាធិការ កសហវ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃ កសហវ រួមជាមួយតំណាងពីអគ្គនាយកដ្ឋាននៃ កសហវ។





## ៣. សកម្មភាពរបស់មន្ត្រីនៃនាយកដ្ឋានរបបគយ បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងចូលរួមការចុះត្រួតពិនិត្យអនុលោមភាពការប្រើប្រាស់ទំនិញនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ

- ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( កអក ) មន្ត្រីនាយកដ្ឋានរបបគយ ២រូប បានចូលរួមកិច្ចប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃ កអក/គវក ដែលដឹកនាំដោយឯកឧត្តម **ជា ឧុទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ដោយមានការចូលរួមពីតំណាងអន្តរក្រសួង ស្ថាប័ន និងតំណាងរដ្ឋបាលខេត្តពាក់ព័ន្ធ។




- ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៥ មន្ត្រីនាយកដ្ឋានរបបគយ២រូប បានចូលរួមជាមួយគណៈកម្មការអន្តរក្រសួង ស្ថាប័ន ដឹកនាំដោយ តំណាងពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គណៈកម្មាធិការវិនិយោគកម្ពុជា) ចុះពិនិត្យជាក់ស្តែងលើសំណើសុំលក់ចេញនូវគ្រឿងម៉ាស៊ីនចាស់ៗ ដែលពុំអាចប្រើការបានចំនួន ១២៦ គ្រឿង របស់ក្រុមហ៊ុន MOHA GARMENTS CO., LTD នៅទីតាំងរោងចក្ររបស់ក្រុមហ៊ុន ស្ថិតនៅផ្លូវជាតិលេខ៣ ភូមិព្រៃសំព័រ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។




- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ មន្ត្រីនាយកដ្ឋានរបបគយ២រូប បានចូលជាមួយក្រុមការងារ **អគរ** ដឹកនាំដោយ លោកអនុប្រធានលេខាធិការដ្ឋានសហការជាមួយតំណាងក្រសួងពាណិជ្ជកម្ម និងតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចុះត្រួតពិនិត្យអនុលោមភាពលើក្រុមហ៊ុន Grand Production Co., Ltd ដើម្បីវាយតម្លៃខ្សែច្រវាក់ផលិតកម្មផលិតតង់ ចង្ក្រានអាំសាច់ និងទំនិញផ្សេងទៀត។




# ការងារគ្រប់គ្រងតំបន់រួចពន្ធ

នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារគ្រប់គ្រងតំបន់រួចពន្ធ មានការិយាល័យក្រោមឱវាទមួយចំនួនដូចជា ការិយាល័យគោលនយោបាយនិងគ្រប់គ្រងតំបន់រួចពន្ធ និងបណ្តាការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេសនានា។ ក្រៅពីការអនុវត្តការងារស្នូលប្រចាំថ្ងៃ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ មានព្រឹត្តិការណ៍សំខាន់ៗមួយចំនួន ដូចខាងក្រោម៖

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ក្នុងនាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចូលរួមជាមួយគណៈកម្មការអន្តរក្រសួង ដឹកនាំដោយឯកឧត្តម **ហេង សុខណាង** អគ្គលេខាធិការរងនៃគណៈកម្មាធិការវិនិយោគកម្ពុជា ចុះពិនិត្យទីតាំងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស របស់ក្រុមហ៊ុន FUJIAN SPECIAL ECONOMIC ZONE CO., LTD. ដែលមានទីតាំងស្ថិតនៅភូមិមនោរម្យ និងភូមិឈើទាល ឃុំជំពូវន្ត ស្រុកជុំគិរី ខេត្តកំពត លើទំហំផ្ទៃដីប្រមាណ ៣១០ហិកតា និងមានទុនវិនិយោគ ១២០លានដុល្លារអាមេរិក។





២. ការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស នៃនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស ជូនដល់តំណាងអ្នកអភិវឌ្ឍន៍តំបន់, វិនិយោគិនក្នុងតំបន់ និងជើងសាគយពាក់ព័ន្ធ ចំនួន ២លើក រួមមាន៖ ៖ នៅតំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត ចំនួន ១លើក នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ និងនៅតំបន់សេដ្ឋកិច្ចពិសេស ខេមបូឌាន-ស៊ីណូ មេធលលីក មេធៀវៀល ចំនួន ១លើក នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥។





# ការងាររដ្ឋាករ

ក្នុងនាមជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារគ្រប់គ្រង និងប្រមូលពន្ធអាករពីការនាំចេញនាំចូល ចែកចាយ ចរាចរដឹកជញ្ជូន និងសន្និធិផលិតផលតេលសិលានិងថាមពល ព្រមទាំងគ្រប់គ្រងកិច្ចដំណើរការអេគារលក់ទំនិញរួចពន្ធ និងស្រាវជ្រាវបង្ក្រាបបទល្មើសគយពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មទាំងនេះ, នាយកដ្ឋានរដ្ឋាករនៅក្រោមការដឹកនាំរបស់លោក **អន ស៊ីនួន** ប្រធាននាយកដ្ឋាន រួមនឹងមន្ត្រីក្រោមឱវាទទាំងអស់ បានបន្តប្រឹងប្រែងអនុវត្តតួនាទីនិងភារកិច្ចប្រកបស្មារតីយកចិត្តទុកដាក់ខ្ពស់ និងអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយសម្រេចបាននូវលទ្ធផលការងារសំខាន់ៗនៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ ដូចខាងក្រោម៖

**១- ការកៀរគរចំណូល**

ការអនុវត្តការប្រមូលចំណូលសម្រេចបានចំនួន ៦៩០ ៦៩៨ លានរៀល ឬ ៩៩,៩% នៃផែនការ និងកើនជាងត្រីមាសទី២ឆ្នាំ២០២៥ប្រមាណ ១១៦៩៩លានរៀលឬ១,៧%។ លទ្ធផលនេះ អាចសម្រេចបានដោយសារកត្តាស្ថិរភាពតម្លៃប្រេងឥន្ធនៈនៅទីផ្សារអន្តរជាតិ, ការនាំចូលប្រេងនិងឧស្ម័នឥន្ធនៈបានពេញលេញពីប្រភពផ្សេងៗក្រៅពីប្រទេសថៃ និងជាពិសេសប្រសិទ្ធភាពនៃការងារគ្រប់គ្រង និងប្រមូលចំណូលរបស់ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់រូប។

ជាមួយនឹងការប្រមូលចំណូលពីសកម្មភាពនាំចូល ការិយាល័យបង្ការបង្ក្រាបបទល្មើសនិងគ្រប់គ្រងផលិតកម្មនៃនាយកដ្ឋានរដ្ឋាករ ក៏បានជំរុញការត្រួតពិនិត្យអនុលោមភាពលើឃ្លាំងស្តុក អាជីវកម្មដ្ឋាន និងមធ្យោបាយដឹកជញ្ជូនផលិតផលតេលសិលានៅទូទាំងប្រទេស ដើម្បីចូលរួមលើកកម្ពស់កម្រិតអនុលោមភាពនៃការនាំចូល ចែកចាយ ចរាចរដឹកជញ្ជូន និងសន្និធិផលិតផលតេលសិលា។ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ ឃ្លាំងស្តុក ៧ទីតាំង និងរថយន្ត ៦២គ្រឿង ត្រូវបានធ្វើការត្រួតពិនិត្យអនុលោមភាព និងរកឃើញបទល្មើសគយ ១២ករណី ហើយប្រមូលបានប្រាក់ពន្ធអាករនិងពិន័យសរុប ១ ៤៧២ លានរៀល។












## ២- ព្រឹត្តិការណ៍សំខាន់ៗ

- ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានដឹកនាំកិច្ចប្រជុំស្តីពីការនាំចូលនិងផ្គត់ផ្គង់ប្រេង និងឧស្ម័នឥន្ធនៈនៅកម្ពុជា ដោយមានការចូលរួមពីលោកអគ្គនាយករង ថ្នាក់ដឹកនាំនិងមន្ត្រីនាយកដ្ឋានរដ្ឋាករ ព្រមទាំងអគ្គនាយក/អគ្គនាយិកា ឬតំណាងក្រុមហ៊ុននាំចូលប្រេងនិងឧស្ម័នឥន្ធនៈ។






- ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥ លោក **អន ស៊ីនួន** ប្រធាននាយកដ្ឋានរដ្ឋាករ និងមន្ត្រីក្រោមឱវាទ បានសហការជាមួយមន្ត្រីនាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ចុះត្រួតពិនិត្យការរៀបចំអគារលក់ទំនិញរួចពន្ធរបស់ក្រុមហ៊ុន Lagardere Travel Retail ( Cambodia ) Co., Ltd ដែលមានទីតាំងស្ថិតនៅក្នុងអាកាសយានដ្ឋានអន្តរជាតិតេជោ ផ្នែកអ្នកដំណើរចេញ និងផ្នែកអ្នកដំណើរមកដល់។






- នៅថ្ងៃទី២៦ខែសីហា ឆ្នាំ២០២៥លោក **អន ស៊ីនួន** ប្រធាននាយកដ្ឋានរដ្ឋាករ និងមន្ត្រីជំនាញ បានអមលោកអគ្គនាយករង **សែ សុឃន** ចូលរួមកិច្ចប្រជុំពិភាក្សាលើសំណើសុំជ្រើសរើសក្រុមហ៊ុនដើម្បីធ្វើការវិនិយោគគម្រោងប្រេងកាតប្លុកAក្រោមការដឹកនាំរបស់ឯកឧត្តម **ឌី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។






- នៅថ្ងៃទី២៧ខែសីហា ឆ្នាំ២០២៥លោក **អន ស៊ីនួន** ប្រធាននាយកដ្ឋានរដ្ឋាករ និងមន្ត្រីជំនាញ បានអមលោកអគ្គនាយករង **សែ សុឃន** ចូលរួមកិច្ចប្រជុំពិភាក្សាលើសំណើសុំអន្តរាគមន៍លើកិច្ចការអាជីវកម្មវិស័យប្រេងនិងឧស្ម័នឥន្ធនៈ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។





# ការិយាល័យនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ

នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា លើការងារប្រមូលចំណូលពន្ធ អាករ និងកម្រៃគ្រប់ប្រភេទ, គ្រប់គ្រង និងត្រួតពិនិត្យបែបបទគយលើទំនិញនាំចេញ នាំចូល និងទំនិញឆ្លងកាត់គ្រប់ប្រភេទ, ត្រួតពិនិត្យបែបបទគយលើអាកាសយាននិងអ្នកដំណើរចេញ-ចូល,បង្ការនិងបង្ក្រាបបទល្មើសគយ,ផ្តល់កិច្ចសម្រួលពាណិជ្ជកម្មនិងបំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ក្រោមការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងមុតមាំរបស់ លោក **ហ៊ីច ពុទ្ធិរិទ្ធ** ប្រធាននាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ និងមានការចូលរួមយ៉ាងសកម្មពីមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទ, នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ប្រមូលចំណូលបានប្រមាណ ៦៣,០១ ប៊ីលានរៀល។

ទន្ទឹមនឹងនេះ នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិក៏សម្រេចបាននូវលទ្ធផលការងារសំខាន់ៗមួយចំនួនផ្សេងទៀត ដូចខាងក្រោម៖

## I. ការងារបង្ការ និងបង្ក្រាបបទល្មើស

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ មន្ត្រីគយនិងរដ្ឋាករនៃនាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន ៨ករណី ដោយក្នុងនោះប្រភេទហេរ៉ូអ៊ីនចំនួន ៣ករណី (នៅស្ថានីយអ្នកដំណើរចេញ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ) មានទម្ងន់សរុប ៥ ៨៦៧ក្រាម, ប្រភេទកញ្ឆាក្រៀមចំនួន ៣ករណី (នៅស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ) មានទម្ងន់សរុប ៩៤ ៨០៤ក្រាម, ប្រភេទកេតាមីនចំនួន ១ករណី (នៅស្ថានីយអ្នកដំណើរចេញ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ) មានទម្ងន់សរុប ១ ៩៨៣ក្រាម និងប្រភេទមេតំហ្វេតាមីនចំនួន ១ករណី (នៅស្ថានីយអ្នកដំណើរចេញ នៃអាកាសយានដ្ឋានអន្តរជាតិតេជោ) មានទម្ងន់សរុប ៧៨៧ក្រាម។














## II. ការទទួលដំណើរទស្សនកិច្ចរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងលោកជំទាវ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ

នាព្រឹកថ្ងៃអង្គារ ៣កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងលោកជំទាវព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីគយនិងរដ្ឋាករនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានមកធ្វើទស្សនកិច្ចនៅអាកាសយានដ្ឋានអន្តរជាតិតេជោដោយបានពិនិត្យទិដ្ឋភាពជារួមនៃអាកាសយានដ្ឋានអន្តរជាតិ លំដាប់ថ្នាក់ 4F និងបានធ្វើការត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធរបស់អង្គភាពគយនិងរដ្ឋាករនៅស្ថានីយអ្នកដំណើរចេញ ស្ថានីយអ្នកដំណើរមកដល់ ស្ថានីយឃ្លាំងទំនិញ និងអគាររដ្ឋបាលនៃនាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ដោយមានការអមដំណើរ និងផ្តល់កិច្ចសម្របសម្រួលពីឧកញ៉ា **ទ៉ាន់ ឆារស័ដ្ឋន** នាយកប្រតិបត្តិក្រុមហ៊ុន ខេមបូឌា អ៊ែរផត អ៊ិនវេសមិន ឯ.ក។













## III. ការផ្លាស់ប្តូរអគាររដ្ឋបាល នៃនាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មកអាកាសយានដ្ឋានអន្តរជាតិតេជោ

នាថ្ងៃអង្គារ ២រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ ដំណាលគ្នានឹងការដាក់ឱ្យប្រតិបត្តិការអាកាសយានដ្ឋានអន្តរជាតិតេជោ, នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ និងការិយាល័យត្រួតពិនិត្យគយអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានផ្លាស់ប្តូរទីតាំងពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមកអាកាសយានដ្ឋានអន្តរជាតិតេជោ ដែលមានអាសយដ្ឋាននៅភូមិតាព្រហ្ម ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ជាមួយគ្នានេះយោងតាមប្រកាសលេខ ៦៨៧ សហវ.ប្រក.អគរ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការិយាល័យត្រួតពិនិត្យគយអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានប្តូរឈ្មោះទៅជា ការិយាល័យត្រួតពិនិត្យគយអាកាសយានដ្ឋានអន្តរជាតិតេជោ ចំណុះនាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។



## IV. ការទទួលដំណើរទស្សនកិច្ចរបស់កងកម្លាំងការពារព្រំដែនប្រទេសអូស្ត្រាលី (Australia Border Force-ABF)

នាព្រឹកថ្ងៃពុធ ៣រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៥ នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ បានទទួលដំណើរទស្សនកិច្ចការងាររបស់កងកម្លាំងការពារព្រំដែនប្រទេសអូស្ត្រាលី (Australia Border Force ABF) ដែលមានលោកJames Ryan, Head of Agency for the Mekong Region និង លោក Paul Schembri, The ABF First Secretary។ គោលបំណងនៃទស្សនកិច្ចការងារនេះ គឺដើម្បីស្វែងយល់ពីការបំពេញភារកិច្ចជាក់ស្តែងរបស់មន្ត្រីគយនិងរដ្ឋាករនៃនាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងបានប្រគល់ឧបករណ៍ត្រួតពិនិត្យរូបិយប័ណ្ណ និងឯកសារក្លែងក្លាយ ជូនដល់មន្ត្រីគយនិងរដ្ឋាករសម្រាប់ប្រើប្រាស់ផងដែរ។





# ការងារគយនិងរដ្ឋាករផែស្ងួត

### ១. ការពង្រឹងអនុលោមភាពតាមបណ្ដាការិយាល័យគយនិងរដ្ឋាករផែស្ងួតក្រោមឱវាទ

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួតបានយកចិត្តទុកដាក់ខ្ពស់នៅក្នុងការងារកៀរគរចំណូលពន្ធអាករ ឱ្យសម្រេចបានតាមផែនការផ្ទៃក្នុងសម្រាប់អនុវត្តចំណូលពន្ធនិងអាករផ្សេងៗ ដែលប្រមូលដោយ **អគរ** ប្រចាំខែ និងស្របតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងកិច្ចប្រជុំបូកសរុបការងារគយនិងរដ្ឋាករប្រចាំខែនាពេលកន្លងដែល និងបានក្លាយជាអង្គភាពគយនិងរដ្ឋាករដែលប្រមូលចំណូលច្រើនជាងលំដាប់ទី១ នៅទូទាំងប្រទេសក្នុងរយៈពេលបីខែចុងក្រោយ ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

- ប្រាក់ពន្ធ ១,០១៥,៤០៣,៩៨៥,៧០០៛ ស្មើនឹង ៩៨.៧៣% នៃផែនការត្រីមាសទី៣ ឆ្នាំ២០២៥ សរុប ១,០៥៧,៨០០,០០,០០០៛
- ប្រៀបធៀបនឹងចំណូលត្រីមាសទី២ ឆ្នាំ២០២៥ មានការកើនឡើងប្រមាណ ១១៤,០០៣,០៣០,៥០០៛ ស្មើនឹង ១២.៦៥%
- ប្រៀបធៀបនឹងចំណូលត្រីមាសទី៣ ឆ្នាំ២០២៤ មានការកើនឡើងប្រមាណ ៤៧៤,៥៧៨,៤៥៣,១០០៛ ស្មើនឹង ៨៧.៧៥%

ក្នុងន័យបង្កើនការទប់ស្កាត់និងបង្រ្កាបអំពើរត់គេចពន្ធ និងបន្លំពន្ធតាមគ្រប់រូបភាព ជាពិសេសលើមុខទំនិញយានយន្ត និងមុខទំនិញផ្សេងទៀតដែលជាប្រភពចំណូលដ៏សំខាន់ នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួតបានរៀបចំចាត់តាំងកម្លាំងក្រុមការងារពង្រឹងអនុលោមភាព ដើម្បីប្រចាំការចុះសហការត្រួតពិនិត្យ រូបវន្តលើទំនិញយានយន្ត និងមុខទំនិញផ្សេងទៀតដែលមានវេយិតភាពខ្ពស់លើការកំណត់តម្លៃគិតពន្ធគយ និងការធ្វើចំណាត់ថ្នាក់តាមតារាងពន្ធគយជាធរមាន នៅបណ្តាការិយាល័យគយនិងរដ្ឋាករផែស្ងួតក្រោមឱវាទ តាមការចង្អុលបង្ហាញរបស់ **អគរ** និងលោកប្រធាននាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត។ ជាលទ្ធផលក្នុងត្រីមាស ទី៣ ឆ្នាំ២០២៥ នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួតបានចាត់តាំងឱ្យក្រុមការងារពង្រឹងអនុលោមភាពឱ្យសហការ ចុះត្រួតពិនិត្យទំនិញជាមួយក្រុមចម្រុះ **អគរ** និងមន្ត្រីគយនិងរដ្ឋាករនៃការិយាល័យគយនិងរដ្ឋាករផែស្ងួតក្រោមឱវាទ ដោយបានរកឃើញការប្រកាសនាំចូលមិនត្រឹមត្រូវ និងបានកសាងកំណត់ហេតុល្មើសច្បាប់គយចំនួន ៦ករណី ប្រមូលប្រាក់ពន្ធអាករនិងពិន័យបន្ថែមចំនួន ៣៤,៦២៨,៧០០៛។ ខាងក្រោមជាសកម្មភាពចុះ ត្រួតពិនិត្យអនុលោមភាព របស់ក្រុមការងារពង្រឹងអនុលោមភាពលើមុខទំនិញរថយន្តរបស់នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត សហការជាមួយមន្ត្រីគយនិងរដ្ឋាករតាមបណ្តាការិយាល័យគយនិងរដ្ឋាករផែស្ងួតក្រោមឱវាទ និង អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ៖










សកម្មភាពចុះត្រួតពិនិត្យអនុលោមភាពទំនិញនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត ហុងឡេងហួរ និងអូលែរ





សកម្មភាពចុះត្រួតពិនិត្យអនុលោមភាពទំនិញនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត អ៊ុយញ៉ុង និងបុកសេង

## ២. កិច្ចប្រជុំផ្សព្វផ្សាយអំពីនីតិវិធីឆ្លងកាត់គយជូនប្រតិវេទករនិងជើងសាគយនៅតាមបណ្តាផែស្ងួត

នៅរសៀលថ្ងៃអង្គារ ៨កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ វេលាម៉ោង ០៣:០០នាទីរសៀល នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត សម្របសម្រួលជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីនីតិវិធីឆ្លងកាត់ ជូនតំណាងក្រុមហ៊ុន ផែស្ងួត ធុរជន ជើងសាគយ និងប្រតិវេទករ សរុបចំនួន ៦០នាក់ តាមប្រព័ន្ធអនឡាញ ZOOM។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនតំណាងក្រុមហ៊ុន ផែស្ងួត ធុរជន ជើងសាគយ និងប្រតិវេទករបានយល់កាន់តែច្បាស់នូវនីតិវិធីឆ្លងកាត់គយ អនុលោមតាមខ្លឹមសារនៃសេចក្តីណែនាំលេខ ៣១៣៣/២៥ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការអនុវត្តនីតិវិធីនៃការឆ្លងកាត់គយដែលមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។ កិច្ចប្រជុំផ្សព្វផ្សាយនេះប្រព្រឹត្តទៅក្រោមការដឹកនាំ និងសម្របសម្រួលរបស់លោក **ម៉ូរ ខេមសំណាង** ប្រធាន ការិយាល័យរដ្ឋបាលនិងគ្រប់គ្រងនៃនាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត តំណាងដ៏ខ្ពង់ខ្ពស់ លោក **ភួង ណុច** ប្រធាននាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត និងមានការចូលរួមពីលោកប្រធានការិយាល័យគយនិងរដ្ឋាករបណ្តា ផែស្ងួត និងលោក-លោកស្រីមន្ត្រីគយនិងរដ្ឋាករនៃនាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងសិក្ខាកាមជាតំណាងក្រុមហ៊ុនផែស្ងួត ធុរជន ជើងសាគយ និងប្រតិវេទករ។

ថ្លែងក្នុងមតិស្វាគមន៍ លោកប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រងបានគូសបញ្ជាក់អំពីសារៈសំខាន់ នៃនីតិវិធីឆ្លងកាត់គយ ជាផ្នែកមួយនៃការបំពេញបែបបទបញ្ចេញទំនិញពីគយនៅតាមបណ្តាផែស្ងួត ដែលជើងសាគយនិងប្រតិវេទករ ត្រូវស្វែងយល់ឱ្យបានច្បាស់លាស់ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវស្របតាមសេចក្តីណែនាំជាធរមាន។ បន្ទាប់មក លោក **ណាយ សុផាន់ណារិទ្ធិ** អនុប្រធានការិយាល័យនៃនាយកដ្ឋាន បច្ចេកវិទ្យាព័ត៌មាន បានធ្វើបទបង្ហាញអំពីនីតិវិធីឆ្លងកាត់គយជាធរមានជូនតំណាងក្រុមហ៊ុនផែស្ងួត ធុរជន ជើងសាគយ និងប្រតិវេទករបានជ្រាបនិងស្វែងយល់។ បន្ទាប់ពីបញ្ចប់បង្ហាញ សិក្ខាកាមបានចូលធ្វើការពិភាក្សាយ៉ាងសកម្មភាពតាមរយៈសំណួរចម្លើយជាច្រើនពាក់ព័ន្ធនឹងនីតិវិធីនៃការឆ្លងកាត់គយ។ ជាទីបញ្ចប់ លោកប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រងបានផ្តល់នូវចំណាប់អារម្មណ៍បិទកម្មវិធី និងបានថ្លែង

អំណរគុណនូវថ្នាក់ដឹកនាំ មន្ត្រីគយនិងរដ្ឋាករ និងសិក្ខាកាម ទាំងអស់ដែលបានចំណាយដ៏មានតម្លៃចូលរួមកិច្ចប្រជុំ ផ្សព្វផ្សាយដ៏មានសារៈសំខាន់នារសៀលនេះ។







កិច្ចប្រជុំផ្សព្វផ្សាយអំពីនីតិវិធីឆ្លងកាត់គយជូនប្រតិវេទករ និងជើងសាគយនៅតាមបណ្តាផែស្ងួត នៅរសៀលថ្ងៃទី៣០ ខែកញ្ញាឆ្នាំ២០២៥ តាមប្រព័ន្ធអនឡាញ ZOOM

# ការងារបង្ការនិងបង្ក្រាបបទល្មើស

ក្នុងនាមជាសេនាធិការរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាលើការងាររៀបចំគោលនយោបាយ រៀបចំផែនការសកម្មភាពជាយុទ្ធសាស្ត្រនានាសំដៅពង្រឹងអនុលោមភាពនិងការអនុវត្តច្បាប់ នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស (**ន.បប**) ក្រោមការដឹកនាំរបស់លោក **នូ ស៊ីថា** បានបន្តខិតខំយ៉ាងសកម្មអនុវត្តការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការប្រមូលចំណូលថវិការដ្ឋ ការពារសុខុមាលភាពសាធារណៈ និងសន្តិសុខសង្គមតាមរយៈការដាក់ចេញនូវផែនការទប់ស្កាត់ បង្ការនិងបង្ក្រាបបទល្មើសគយបានច្បាស់លាស់ដោយបានយកចិត្តទុកដាក់ជាពិសេសពង្រឹងប្រសិទ្ធភាពលើការងារស្រាវជ្រាវ និងស៊ើបអង្កេតបទល្មើសរត់គេចពន្ធ បទល្មើសបន្លំពន្ធ និងបទល្មើសឆ្លងដែនពាក់ព័ន្ធផ្សេងទៀត។ ជាក់ស្តែង ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ **ន.បប** បានណែនាំដល់មន្ត្រីក្រោមឱវាទឱ្យបន្តចុះធ្វើអនុលោមភាពជាប្រចាំហើយសម្រេចបាននូវលទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១) **ន.បប** បានចុះធ្វើអនុលោមភាពជាប្រចាំលើមធ្យោបាយដឹកជញ្ជូនទំនិញ យានយន្ត អាជីវកម្មដ្ឋាន និងឃ្លាំងស្តុកទំនិញនៅក្នុងភូមិសាស្ត្ររាជធានី-ខេត្តជាប្រចាំ និងបានបង្ក្រាបអំពើរត់គេចពន្ធសរុបចំនួន១,៨០៩ ករណី ក្នុងនោះ បានកសាងកំណត់ហេតុតូច១,៦៥៦ករណី និងកំណត់ហេតុធំចំនួន ១៥៣ ករណី ដែលជារួមមាន៖

- យានយន្ត (រថយន្ត និងម៉ូតូ)
- ប្រេងម៉ាស៊ូត ប្រេងរំអិល និងផលិតផលតេលសិលាផ្សេងទៀត
- ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង ទូរទស្សន៍ ទូរស័ព្ទ និងគ្រឿងអេឡិចត្រូនិចផ្សេងទៀត
- គ្រឿងឧបភោគ បរិភោគ ភេសជ្ជៈប៉ូវកម្លាំង និងភេសជ្ជៈផ្សេងទៀត
- បារី ស្រា ស្រាបៀរ
- កញ្ចាក្រៀម កាំភ្លើងបាញ់គ្រាប់ជ័រ និងមុខទំនិញផ្សេងៗទៀត

លទ្ធផលបង្ក្រាបបទល្មើសខាងលើ បាននាំឱ្យ **ន.បប** ប្រមូលចំណូលពន្ធអាករ និងប្រាក់ពិន័យ ចំនួនសរុបជាង ១៤ពាន់លានរៀលស្មើនឹង១៧៦.០២%នៃផែនការប្រចាំត្រីមាសទី៣ ឆ្នាំ២០២៥។




សកម្មភាពចុះបង្ក្រាបបទល្មើសគយនៅសមុទ្រ




សកម្មភាពចុះត្រួតពិនិត្យអនុលោមភាពនិងបង្ក្រាបសាច់បង្កកនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ




សកម្មភាពចុះត្រួតពិនិត្យអនុលោមភាពនិងបង្ក្រាបគ្រឿងអេឡិចត្រូនិកក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ




សកម្មភាពចុះបង្ក្រាបបារីខុសច្បាប់នៅក្នុងភូមិសាស្ត្រខេត្តក្រចេះ



សកម្មភាពចុះបង្ក្រាបទំនិញរត់គេចពន្ធ (កង់អាគុយ) ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

២) **ន.បប** បានចាត់មន្ត្រីចូលរួមកិច្ចប្រជុំលើកទី៣៨ របស់ ASEAN Customs Enforcement and Compliance Working Group (38th CECWG Meeting) នៅថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៥ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។

៣) **ន.បប** បានបញ្ចូលព័ត៌មានស្តីពីការបង្ក្រាបគ្រឿងញៀនខុសច្បាប់ចំនួន ១២ ករណី ចូលទៅក្នុងប្រព័ន្ធ CENComm3 នៃប្រតិបត្តិការ Pacific Shied II និង Mekong Dragon VII។

៤) **ន.បប** បានចាត់មន្ត្រីចូលរួមសិក្ខាសាលា និងកិច្ចប្រជុំស្តីពី Briefing on Operation THUNDER 2025 ដើម្បីប្រយុទ្ធប្រឆាំងអំពើរត់ពន្ធសត្វព្រៃនិងបំណែករបស់វា និងពាណិជ្ជកម្មឈើខុសច្បាប់ ដែលរៀបចំដោយអង្គការគយពិភពលោក ដោយសហកាជាមួយស្ថាប័ននគរបាលអន្តរជាតិ (INTERPOL) ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ នៅប្រទេសសឹង្ហបុរី និងកិច្ចប្រជុំ Briefing Meeting នៃប្រតិបត្តិការ DEMETER XI នៅថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥ តាមប្រព័ន្ធវីដេអូ។

៥) **ន.បប** បានទទួលឯកសារព័ត៌មានបង្ក្រាបបទល្មើសគយពី RILO AP ចំនួន៥ ពាក់ព័ន្ធនឹងការបង្ក្រាបបទល្មើសគយ ដូចជា ការរត់ពន្ធគ្រឿងញៀន ការរត់ពន្ធមាស និងការបង្ក្រាបទំនិញក្លែងក្លាយ និងបានផ្សព្វផ្សាយជូនដល់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធទាំងអស់។

៦) **ន.បប** បានផ្សព្វផ្សាយ និងចូលរួមអនុវត្តប្រតិបត្តិការគយរួមគ្នាប្រចាំតំបន់និងអន្តរជាតិ ដោយបានសហការជាមួយនឹងអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធមានដូចខាងក្រោម៖

- ប្រតិបត្តិការ THUNDER 2025 ដើម្បីប្រយុទ្ធប្រឆាំងអំពើរត់ពន្ធសត្វព្រៃនិងបំណែករបស់វា និងការធ្វើពាណិជ្ជកម្មឈើខុសច្បាប់ ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី១៥ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥
- ប្រតិបត្តិការ DEMETER XI ដើម្បីប្រយុទ្ធប្រឆាំងការនាំចូល ការនាំចេញ និងការឆ្លងកាត់ខុសច្បាប់នូវសំណល់គ្រោះថ្នាក់ និងសារធាតុបំផ្លាញស្រទាប់អូហ្សូន រួមទាំងសារធាតុ Hydro-fluorocarbons (HFCs) ដែលត្រូវអនុវត្តដំណាក់កាលទី១ ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥និងដំណាក់កាលទី២ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥
- GLOBAL GATEWAY ដើម្បីប្រយុទ្ធប្រឆាំងអំពើរត់ពន្ធខុសច្បាប់នូវសារធាតុគីមីផ្សំសម្រាប់ផលិតគ្រឿងផ្ទុះ និងDroneដែលអាចបំពាក់គ្រឿងផ្ទុះបានដែលត្រូវអនុវត្តចាប់ពីថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៥

# សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ក្រោមការដឹកនាំដោយលោក **នង សុខុម** បានខិតខំអស់ពីកម្លាំងកាយចិត្តដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត និងមានការចូលរួមយ៉ាងសកម្មពីមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទក្នុងការបំពេញតួនាទីនិងភារកិច្ច ជំរុញការអនុវត្តការងារសំខាន់ៗស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការប្រមូលចំណូលពន្ធនិងអាករ,។ ជាលទ្ធផលសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុប្រមូលចំណូលបាន ៨៥៧,៦៧៨,៨៦៩,៣០០ រៀល ស្មើនឹង ៩១.៤៩% នៃផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឲ្យអនុវត្ត។

ទន្ទឹមនឹងនេះ សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ក៏សម្រេចបាននូវលទ្ធផលការងារសំខាន់ៗមួយចំនួនផ្សេងទៀតដូចខាងក្រោម៖

១. បានចូលរួមទស្សនកិច្ចសិក្សាស្តីពី "Study Visit Under Hazardous Waste Project"

ចាប់ពីថ្ងៃទី០១ ដល់ ០៣ ខែកក្កដា ឆ្នាំ២០២៥ មន្ត្រីគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ បានចូលរួមទស្សនកិច្ចសិក្សា ស្តីពី "Study Visit Under Hazardous Waste Project" ក្រោមគម្រោង UNODC-WCO INTERPOL Passenger and Cargo Control Programme ( PCCP ) ដោយមានការចូលរួមពីមន្ត្រីក្រសួងបរិស្ថាននិងសិក្ខាកាមមក ពីប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍។ កម្មវិធីនេះបានប្រព្រឹត្តទៅនៅទីក្រុង Paris និងទីក្រុង Le Havre ប្រទេសបារាំង។







២. វគ្គបណ្តុះបណ្តាលស្តីពី "Strategic Trade and Export Control"។

ពីថ្ងៃទី១១ ដល់ ១៥ ខែសីហា ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ បានចាត់មន្ត្រីគយចូលរួមជាគ្រូបង្គោលជំនាញ ( Recognized Expert Trainer ) ក្នុងវគ្គបណ្តុះបណ្តាលស្តីពី "Strategic Trade and Export Control" ដែលប្រព្រឹត្តទៅនៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំដោយអង្គការ UNODC ក្រោមគម្រោង UNODC-WCO-INTERPOL Passenger and Cargo Control Pro-

gramme (PCCP) និងឧបត្ថម្ភដោយកម្មវិធី EXBS របស់សហរដ្ឋអាមេរិច ក្នុងគោលបំណងជួយពង្រឹងសមត្ថភាពសមាជិកអង្គភាពត្រួតពិនិត្យកុងតឺន័រ (CCU) នៃរដ្ឋបាលគយឡាវ ក្នុងការគ្រប់គ្រងពាណិជ្ជកម្មទំនិញយុទ្ធសាស្ត្រ។






៣. បានទទួលដំណើរទេស្សនកិច្ចនិងជួបប្រជុំជាមួយគណៈប្រតិភូស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ នៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ដោយមានការសម្របសម្រួលពីនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ លោក **នខ សុខុម** ប្រធានសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ និងសហការី ព្រមទាំងលោកប្រធានការិយាល័យនាវាចរគយ និងលោកប្រធានការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បានទទួលដំណើរទេស្សនកិច្ចនិងជួបប្រជុំជាមួយគណៈប្រតិភូសហរដ្ឋអាមេរិកសរុបចំនួន ១៩ រូប ដឹកនាំដោយលោក James Podboy សេនានុព័ន្ធប្រចាំប្រទេស (Country Attaché) នៃសេនានុព័ន្ធស៊ើបអង្កេតសន្តិសុខមាតុភូមិ (Homeland Security Investigations) ស្ថានទូតសហរដ្ឋអាមេរិកនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីមកជួបសម្តែងការគួរសម និងស្វែងយល់អំពីការអនុវត្តនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយនៅកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ។





៤. បានទទួលដំណើរទេស្សនកិច្ចរបស់តំណាង US DoE

នាព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៥ នៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ លោក **នខ សុខុម** ប្រធានសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ និងសហការី ដោយមានការសម្របសម្រួលពី តំណាងនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ បានទទួលដំណើរទេស្សនកិច្ចរបស់លោក **Jason Brock Carter** ប្រធានគ្រប់គ្រងនិរន្តរភាព និងលោក **Benjamin Lee** តំណាង US DoE ដើម្បីពិភាក្សាអំពីនិរន្តរភាព ការថែទាំ និងការគ្រប់គ្រង Spare Parts របស់ប្រព័ន្ធរាវរកសារធាតុវិទ្យុសកម្ម។






# សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង

សាខាគយនិងរដ្ឋាករខេត្តស្វាយរៀងក្រោមការដឹកនាំរបស់លោក **សំ សុវណ្ណារិទ្ធិ** មានការិយាល័យក្រោមឱវាទចំនួន ៦ រួមមាន ការិយាល័យរដ្ឋបាលនិងគ្រប់គ្រង ការិយាល័យគយនិងរដ្ឋាករបាវិត ការិយាល័យគយនិងរដ្ឋាករព្រៃវល្លិ៍ ការិយាល័យគយនិងរដ្ឋាករបុសមន ការិយាល័យគយនិងរដ្ឋាករសំរោង និងការិយាល័យគយនិងរដ្ឋាកររដូង។ លោកប្រធានសាខា ក្នុងនាមថ្នាក់ដឹកនាំអង្គភាព បានបន្តណែនាំមន្ត្រីគយនិងរដ្ឋាករគ្រប់រូបត្រូវខិតខំប្រមូលចំណូលពន្ធនិងអាករ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈនិងផ្ដល់សេវាដល់ធុរជនឱ្យបានឆាប់រហ័ស។ទន្ទឹមនឹងនេះផងដែរ នាព្រឹកថ្ងៃពុធ ៤កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ លោកប្រធានសាខា បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារប្រជុំនៅ**អគរ** និងមតិណែនាំរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង។

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តស្វាយរៀងប្រមូលចំណូលពន្ធនិងអាករ សម្រេចបានចំនួន ១៦៣,០៣៥,៣៨៦,៣០០ រៀល ស្មើ ៩៨.៧៥% នៃផែនការប្រចាំត្រីមាសទី៣។បើប្រៀបធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៥ ឃើញថាមានការកើនឡើង ចំនួន ៤៤,០៧១,៩៥១,៤០រៀលស្មើនឹងប្រមាណ៣៧.០៥% និងមានការកើនឡើងចំនួន ៦១,៦០៣,៦៦០,៣០០ រៀល ស្មើនឹង ៦០.៧៣% ប្រៀបធៀបការប្រមូលចំណូលជាមួយត្រីមាសទី៣ឆ្នាំ២០២៤។ជាមួយគ្នានេះដែរលោកប្រធានសាខាក៏បានយកចិត្តទុកដាក់ពង្រឹងការងារស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយនៅក្នុងភូមិសាស្ត្រខេត្តស្វាយរៀង មានដូចជាការបែងចែកកម្លាំងឱ្យចុះទៅឃ្លាំមើលជាប្រចាំនៅតាមតំបន់ភូមិសាស្ត្រ មានហានិភ័យខ្ពស់ក្នុងការរត់គេចពន្ធទំនិញជាពិសេសតាមច្រករបៀងដែលជាលទ្ធផលបង្ក្រាបទំនិញល្មើសច្បាប់គយ បានចំនួន 01 ករណី។ បន្ថែមពីនេះផងដែរ លោកប្រធានសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង បានដឹកនាំមន្ត្រីការិយាល័យគយនិងរដ្ឋាករបាវិតជួបប្រជុំជាមួយនឹងសមត្ថកិច្ចព្រំដែនវៀតណាម ដែលដឹកនាំដោយលោក CAO THIEN MINH ប្រធានគយ មាត់ច្រកម៉ុកបាយ ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយការកកស្ទះទំនិញចេញពីកម្ពុជា តាមរយៈការប្រើប្រាស់ទីលានចំណតរបស់ក្រុមហ៊ុន TAN CANG TAY NINH។ ទន្ទឹមនឹងនេះផងដែរ ដោយទទួលបានការអនុញ្ញាតពី លោក **សំ សុវណ្ណារិទ្ធិ** ប្រធានសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង លោក **ឡាំ សេង** អនុប្រធានសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង បានទទួលប្រតិភូនៃនាយកដ្ឋានបុគ្គលិក អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន៦រូប មកធ្វើការពិនិត្យផ្ទៀងផ្ទាត់រចនាសម្ព័ន្ធមុខងារភារកិច្ចមន្ត្រីរាជការ ការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យានិងពិនិត្យយន្តការវាយតម្លៃសមិទ្ធកម្មមន្ត្រីដែលទទួលបានប្រាក់លើកទឹកចិត្តនិងផ្សព្វផ្សាយណែនាំអនុវត្តលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធការគ្រប់គ្រងបុគ្គលិក។




សកម្មភាពជួបប្រជុំផ្សព្វផ្សាយខ្លឹមសារប្រជុំនៅអគរ



សកម្មភាពជួបប្រជុំជាមួយសមត្ថកិច្ចព្រំដែនវៀតណាម




សកម្មភាពជួបប្រជុំជាមួយប្រតិភូនៃនាយកដ្ឋានបុគ្គលិក

# សាខាគយនិងរដ្ឋាករខេត្តកណ្ដាល

សាខាគយនិងរដ្ឋាករខេត្តកណ្ដាលជាអង្គភាពប្រតិបត្តិពាក់កណ្តាលប្រដាប់អាវុធស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានការិយាល័យគយនិងរដ្ឋាករក្រោមឱវាទចំនួនបី៖ (១)ការិយាល័យរដ្ឋបាលនិងគ្រប់គ្រង (២)ការិយាល័យគយនិងរដ្ឋាករ ក្អមសំណ (៣) ការិយាល័យគយនិងរដ្ឋាករជ្រៃធំ។

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៥ នេះ ចំណូលពន្ធនិងអាករប្រមូលបានមានចំនួន៖១៤២,៤៦៩,៣៨០,៤០០ រៀល ប្រៀបធៀបនឹងផែនការប្រចាំត្រីមាស ១៤៩,៩០០,០០០,០០០រៀល ស្មើនឹង ៩៥.០៤%។បើប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៤កើនឡើង៤៥,០៤៨,៥២១,៨០០រៀល ស្មើនឹង ៤៦.២៤% , បើប្រៀបធៀប នឹងត្រីមាសទី២ ឆ្នាំ២០២៥ កើនឡើង ២,៤៤៤,៤៩៧,៥០០ រៀល ស្មើនឹង ១.៧៥% ។

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ សាខាគយនិងរដ្ឋាករខេត្តកណ្ដាលបង្ក្រាបបទល្មើសគយចំនួន ៤០៣ករណី រួមមាន ករណីតូចចំនួន ៣៩៦ករណី (ម៉ូតូ ៣៩៥គ្រឿង និងស្រកាស្វាយជ័រថ្មី) និងករណីធំចំនួន ០៧ករណី (រថយន្ត, នាឡិកាដៃ(ថ្មី) ម៉ាក Rolex,បារី Marlboro,បារី Kent, សរសៃថ្នាំជក់ និងផលិតផលគ្រឿងសម្អាងចម្រុះផ្សេងៗ)។ ជាមួយគ្នានេះដែរ លទ្ធផលដែលទទួលបានពីការបង្ក្រាប គឺបានសម្រេចវិនិច្ឆ័យបទល្មើសគយចំនួន ៤០០ករណី (ករណីតូច ៣៩៧ និងករណីធំ ០៣) បានប្រាក់ពន្ធអាករ និងពិន័យសរុបចំនួន ២,០១៣,៤៤០,០០រៀល។

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ សាខាបានអនុវត្តនូវសកម្មភាពការងារសំខាន់ៗផ្សេងទៀត ដូចជា បន្តពង្រឹងប្រសិទ្ធភាពប្រមូលចំណូលនៅតាមបណ្ដាការិយាល័យគយនិងរដ្ឋាករមាត់ច្រក លោកប្រធានសាខាគយនិងរដ្ឋាករខេត្តកណ្ដាល បានដឹកនាំកិច្ចប្រជុំនៅការិយាល័យគយនិងរដ្ឋាករជ្រៃធំ ដើម្បីណែនាំដល់មន្ត្រីក្រោមឱវាទត្រូវគោរពវិន័យ និងបំពេញការងារដោយមានសាមគ្គីភាពនិងទទួលខុសត្រូវខ្ពស់ ហើយខិតខំប្រមូលចំណូលពន្ធ និងអាករអោយបានគ្រប់និងលើសផែនការ។ ទន្ទឹមនេះ លើការងារសាងសង់អគាររដ្ឋបាលនិងហេដ្ឋារចនាសម្ព័ន្ធនានាសាខាបានចុះត្រួតពិនិត្យការងារសាងសង់អគាររដ្ឋបាល អគារស្នាក់នៅនិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតរបស់សាខាគយនិងរដ្ឋាករខេត្តកណ្ដាលថ្មី ដែលមានដែលមានទីតាំងស្ថិតនៅភូមិព្រែកស្វាយ២ ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដោយបានសំណូមពរ និងណែនាំដល់ក្រុមហ៊ុនសាងសង់ឱ្យយកចិត្តទុកដាក់សាងសង់ ធ្វើយ៉ាងណាឱ្យសំណង់មានលក្ខណៈត្រឹមត្រូវសមស្របទៅតាមលក្ខណៈបច្ចេកទេសទំនើប ប្រកបដោយគុណភាពខ្ពស់ ប្រើប្រាស់បានរយៈពេលយូរអង្វែង និងសោភណភាពល្អប្រសើរ។







សាខាគយ និងរដ្ឋាករខេត្តកណ្ដាល
KANDAL CUSTOMS AND EXCISE BRANCH
ការិយាល័យគយ និងរដ្ឋាករជ្រៃធំ
CHREY THOM CUSTOMS AND EXCISE OFFICE


សាខាគយ និងរដ្ឋាករខេត្តកណ្ដាល
KANDAL CUSTOMS AND EXCISE BRANCH
ការិយាល័យគយ និងរដ្ឋាករជ្រៃធំ
CHREY THOM CUSTOMS AND EXCISE OFFICE





# សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង

ក្រោមការដឹកនាំដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់លោក **ឃួ ហេង** ជាប្រធានសាខាគយនិងរដ្ឋាករខេត្តបាត់ដំបង ព្រមទាំងមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទនៃសាខាគយនិងរដ្ឋាករខេត្ត បាត់ដំបង បានរួមគ្នាខិតខំប្រឹងប្រែងអនុវត្តការងារគ្រប់គ្រងប្រមូលពន្ធអាករនិងកម្រៃផ្សេងៗបង់ចូលថវិការជាតិដែលជាភារកិច្ចរបស់អង្គភាព។ទន្ទឹមនឹងនេះសាខាគយនិង រដ្ឋាករខេត្តបាត់ដំបង បាននឹងកំពុងចូលរួមចំណែកយ៉ាងសកម្មបំផុតដោយស្មារតីប្រុងប្រយ័ត្ននិងមានការទទួលខុសត្រូវខ្ពស់តាមជំនាញបច្ចេកទេសគយ។ ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ សាខាដែលជានិច្ចកាលតែងតែបានចុះជាប់តាមបណ្តាការិយាល័យគយនិងរដ្ឋាករក្រោមឱវាទ ដើម្បីជម្រុញ និងពង្រឹងការងារកៀរគរចំណូល។ ជាក់ស្តែងក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង ប្រមូលចំណូលបានចំនួន ១,៧៥០,៨៧៩,៧០០ រៀល គិតជាភាគរយប្រមាណ ១២៩.២២% នៃផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឲ្យអនុវត្ត។ បើប្រៀបធៀបចំណូលត្រីមាសទី៣ ឆ្នាំ២០២៤ មានការថយចុះចំនួន ៣៩,៣១៨,៩៤៨,៧០០ រៀល គិតជាភាគរយ ៩៥.៧៤% និងប្រៀបធៀបចំណូលត្រីមាសទី២ ឆ្នាំ២០២៥ មានការថយចុះចំនួន ៥៤,១២៤,៨៨៣,៨០០រៀល គិតជាភាគរយប្រមាណ ៩៦.៨៧%។ ទន្ទឹមនេះ សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង បានបង្ក្រាបបទល្មើសគយ បានចំនួន ៧ ករណីតូច បានប្រាក់ពន្ធអាករ និងប្រាក់ពិន័យសរុបចំនួន ៣០,៥៥១,២០០ រៀល។

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ លោកប្រធានសាខាតែងតែបន្តការយកចិត្តទុកដាក់ខ្ពស់ក្នុងពង្រឹងការងារប្រមូលចំណូលពន្ធគយដល់ការិយាល័យគយនិងរដ្ឋាករក្រោមឱវាទ និងការអនុវត្តនីតិវិធីគយជាធរមានប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈ បន្តពង្រឹងការត្រួតពិនិត្យឯកសារនិងទំនិញរូបវន្តប្រកបដោយអប្បមាទខ្ពស់ អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្មក្នុងការទប់ស្កាត់រាល់បាតុភាពអសកម្មផ្សេងៗ ជាពិសេសអនុវត្តតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ។

ដោយឡែក ក្នុងកំឡុងខែមិថុនា ឆ្នាំ២០២៥ ច្រកទ្វារព្រំដែនក្នុងភូមិសាស្ត្រខេត្តបាត់ដំបងតាមបណ្តោយព្រំដែនកម្ពុជា-ថៃបានបិទទាំងស្រុងដោយភាគីថៃប្រកាសបិទដោយឯកតោភាគី ដូច្នេះធ្វើអោយប៉ុន្មានខែកន្លងទៅនេះ សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង ក៏ដូចជាបណ្តាការិយាល័យតាមបណ្តោយព្រំដែនពុំមានចំណូលពន្ធគយឡើយ ។








សកម្មភាពថ្នាក់ដឹកនាំ និងមន្ត្រីតាមបណ្តាសាខា ការិយាល័យចូលរួមជាមួយអាជ្ញាធរដែនដី ចុះជួយសម្របសម្រួលពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃចូលប្រទេសកម្ពុជាវិញ




សកម្មភាពចូលរួមកិច្ចប្រជុំ ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ








សកម្មភាពចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តតាមអាជីវកម្មដ្ឋានក្នុងភូមិសាស្ត្រខេត្តបាត់ដំបង

# សាខាគយនិងរដ្ឋាករខេត្តក្រចេះ

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តក្រចេះ ដែលដឹកនាំដោយ លោក **ចាន់ សំបូរ** បានជម្រុញការអនុវត្តការងារសំខាន់ៗ ស្របតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពឆ្នាំ២០២៥ ផែនការយុទ្ធសាស្ត្រគយស្តីពីអនុលោមភាព និងការអនុវត្តច្បាប់ ២០២៤-២០២៨ និងលិខិតបទដ្ឋានជាធរមាននានារបស់ **អគរ** បានខិតខំប្រមូលពន្ធអាករសរុបបានចំនួន ៤៦,០៦៤,៨៦៨,៩០០រៀល គិតជាភាគរយប្រមាណ ៩២.១៣ % នៃផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឱ្យអនុវត្ត ៥០,០០០លានរៀលក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ។ បើប្រៀបធៀបចំណូលត្រីមាសទី៣ ឆ្នាំ២០២៤ មានការកើនឡើង ១១,២៦១,៩៧២,០០០រៀល គិតជាភាគរយប្រមាណ ៣២.៣៦% (ចំណូលត្រីមាសទី៣ ឆ្នាំ២០២៤ មានចំនួន ៣៤,៨០២,៨៩៦,៩០០រៀល)។ ប្រៀបធៀបចំណូលត្រីមាសទី២ ឆ្នាំ២០២៥ មានការកើនឡើង ១១,០១៥,១៩៥,០០០រៀល គិតជាភាគរយប្រមាណ ៣១.៤៣% (ចំណូលត្រីមាស២ ឆ្នាំ២០២៥ មានចំនួន ៣៥,០៤៩,៦៧៣,៩០០រៀល)។ បន្ថែមពីលើការងារប្រមូលចំណូល ដោយអនុលោមតាមលិខិតលេខ៖ ៣៦៦៥/២៥ អគរ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការចុះប្រមូលព័ត៌មានសូចនាករហានិភ័យមួយចំនួនពីប្រតិបត្តិករនាំចេញ-នាំចូល នៅរាជធានីនិងតាមបណ្តាខេត្តនានា មន្ត្រីនៃសាខាគយនិងរដ្ឋាករខេត្តក្រចេះ បានចុះអង្កេតក្រុមហ៊ុនតាមការចង្អុលបង្ហាញរបស់ **អគរ** និងធ្វើរបាយការណ៍ដើម្បីបញ្ជូនទៅនាយកដ្ឋានសវនកម្មគយ បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS) លើក្រុមហ៊ុនប្រតិបត្តិការនាំចេញ-នាំចូល ទំនិញ មានចំនួន ២៤ក្រុមហ៊ុន។ បំពោះការសាងសង់អគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធ របស់សាខាគយនិងរដ្ឋាករខេត្តក្រចេះ បានសម្រេចជាស្ថាពរ ហើយលោកប្រធាន **ចាន់ សំបូរ** រួមទាំងមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទ បានប្រារព្ធពិធីកិច្ចសាសនា សូត្រមន្តសុំសេចក្តីសុខ តាមប្រពៃណីទំនៀមទំលាប់ខ្មែរ កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៥ ផងដែរ




សកម្មភាពចុះអង្កេតប្រមូលសូចនាករហានិភ័យតាមបណ្តាក្រុមហ៊ុននាំចេញនាំចូលក្នុងខេត្តក្រចេះ




ការប្រារព្ធពិធីសូត្រមន្តសុំសេចក្តីសុខនៅសាខាគយនិងរដ្ឋាករខេត្តក្រចេះថ្មី

# សាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ

ក្រោមការដឹកនាំដោយលោក **ហេង សំបូរ** ប្រធានសាខាគយនិងរដ្ឋាករខេត្តខេត្តព្រះសីហនុ បាន ខិតខំអស់ពីកម្លាំងកាយចិត្តដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុតក្នុងការបំពេញតួនាទី និងភារកិច្ចក្នុងការប្រមូលចំណូលពន្ធ និងអាករ ឱ្យបានគ្រប់និងលើសផែនការ ដែល **អគរ** បានដាក់ចេញ។

**លទ្ធផលប្រមូលចំណូល៖**

ជាលទ្ធផល ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ សាខាប្រមូលចំណូលបាន ១៦,៦០១,៩៤៩,៥០០ រៀល ស្មើនឹង ៧៧.២២% នៃផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឲ្យអនុវត្ត ២១,៥០០ លានរៀល។ បើប្រៀបធៀបត្រីមាសទី៣ ឆ្នាំ២០២៤ មានការកើនឡើងចំនួន ១,៦១៣,៥៣៣,១០០ រៀល ស្មើនឹង ១០.៧៧% ។ បើប្រៀបធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៥ គឺមានការថយចុះចំនួន ៥,០៩៧,៨៣០,៤០០ រៀល ស្មើនឹង ៣០.៧១% ។

**លទ្ធផលបង្ការ និងបង្ក្រាបបទល្មើស៖**

-ចំនួនបទល្មើសគយ (តូច) ០០ ករណី

-ចំនួនបទល្មើសគយ (ធំ) ០០ ករណី

-ប្រាក់ពន្ធអាករនិងពិន័យសរុបចំនួន២៦,៦៦៨,៧០០ រៀល (ជលយានចំនួន ០១ គ្រឿង)។

**ការងារគ្រប់គ្រងមន្ត្រីរាជការ**

មន្ត្រីរាជការគយដែលកំពុងបំពេញការងារសរុបក្នុងសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុសរុប មានចំនួន ០៨រូប ក្នុងនោះ ប្រុស មានចំនួន ០៦រូប និង ស្ត្រីមានចំនួន ០២រូប៖

| | |
|---|---|
| -ប្រធានសាខា | ០១រូប |
| -អនុប្រធានសាខា | ០៤រូប |
| -ប្រធានការិយាល័យ | ០១រូប |
| -ភ្នាក់ងារ | ០២រូប |




សកម្មភាពទទួលថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃនាយកដ្ឋានបុគ្គលិក នៃគសហរ ចុះមកពិនិត្យផ្ទៀងផ្ទាត់រចនាសម្ព័ន្ធមុខងារភារកិច្ចមន្ត្រីរាជការ, ការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា






សកម្មភាពចូលរួមអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោមប្រធានបទ
( រួមគ្នាបង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ឫសគល់ នៃបញ្ហាគ្រឿងញៀននៅកម្ពុជា )






សកម្មភាពចុះត្រួតពិនិត្យទីតាំងគម្រោងវិនិយោគ និងធុរកិច្ចដែលស្នើការលើកទឹកចិត្ត








សកម្មភាពមន្ត្រីរាជការគយនៃសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ
បានចុះប្រមូលព័ត៌មានសូចនាករហានិភ័យមួយចំនួនពីប្រតិបត្តិករនាំចេញ-នាំចូលក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ

# សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ

ក្រោមការដឹកនាំរបស់លោក **លី ម៉ុនសុខ** ប្រធានសាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ ដែលមានការិយាល័យរដ្ឋបាលនិងគ្រប់គ្រងចំនួន០១ និងការិយាល័យក្រោមឱវាទចំនួន០៦ រួមមាន ការិយាល័យគយនិងរដ្ឋាករត្រពាំងផ្លុង ការិយាល័យគយនិងរដ្ឋាករដា ការិយាល័យគយនិងរដ្ឋាករមេមត់ ការិយាល័យគយនិងរដ្ឋាករត្នោត ការិយាល័យគយនិងរដ្ឋាករទន្លេចាម និងការិយាល័យគយនិងរដ្ឋាករទន្លូង។ លោកប្រធានសាខា ក្នុងនាមថ្នាក់ដឹកនាំអង្គភាព បានបន្តណែនាំមន្ត្រីគយនិងរដ្ឋាករគ្រប់រូបត្រូវខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធនិងអាករ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់សេវាដល់ធុរជនឱ្យបានឆាប់រហ័ស និងបន្តខិតខំប្រឹងប្រែងអនុវត្តការងារស្រាវជ្រាវ បង្ការ ទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់រូបភាព នៅតាមបណ្តាចក្ររបៀងជាប់ព្រំដែន និងចូលរួមអនុវត្តត្រួតពិនិត្យកម្រិតអនុលោមភាពមធ្យោបាយដឹកជញ្ជូន។ ជាក់ស្តែងក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំប្រមូលចំណូលពន្ធនិងអាករនិងកម្រៃផ្សេងៗ សម្រេចបានចំនួន ១២,៣៩៩,៩៩២,៥០០ រៀល ស្មើ ១០៨.១៧% នៃផែនការប្រចាំត្រីមាសទី៣។ ទន្ទឹមនឹងនេះផងដែរ សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំក៏បានចូលរួមការងារមនុស្សធម៌ដោយបានឧបត្ថម្ភគ្រឿងឧបភោគបរិភោគមួយចំនួនទៅកាន់ស្ថាប័នផ្សេងៗដើម្បីយកទៅបំរើជាប្រយោជន៍។





សកម្មភាពកិច្ចប្រជុំនិងការត្រួតពិនិត្យទំនិញ





សកម្មភាពកិច្ចការងារសប្បុរសធម៌

# សាខាគយនិងរដ្ឋាករខេត្តព្រៃវែង

សាខាគយ និងរដ្ឋាករខេត្តព្រៃវែង និងបណ្ដាការិយាល័យគយនិងរដ្ឋាករក្រោមឱវាទ បាននអនុវត្តការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១. នាថ្ងៃពុធ ៧កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ លោក **មួច ដារ៉ា** ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង បានដឹកនាំសហការីទទួលស្វាគមន៍ការអញ្ជើញមកដល់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញចុះពិនិត្យស្ថានភាពទូទៅនៅច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ និងសំណេះសំណាលជាមួយមន្ត្រីក្រុមការងារច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ និងអមដំណើរឯកឧត្តម**សួនសុម៉ាលីន**អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងដែលបានទទួលស្វាគមន៍ដោយ ឯកឧត្តម Nguyen Minh Vu ឯកអគ្គរដ្ឋទូត វៀតណាមប្រចាំកម្ពុជាដើម្បីពិភាក្សាការងារ។ ក្នុងកិច្ចពិភាក្សានោះដែរ ក៏បានលើកឡើងពីការត្រៀមដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនូវច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ (កម្ពុជា)-តឺនណាម(វៀតណាម)ដែលគ្រោងនឹងប្រារព្ធធ្វើក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ នាអំឡុងខែតុលា ឆ្នាំ២០២៥។

២. នាថ្ងៃចន្ទ១២កើតខែអាសាឍឆ្នាំម្សាញ់សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥ ការិយាល័យគយ និងរដ្ឋាករម៉ឺនជ័យបានសហការជាមួយសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប"ខេត្តព្រៃវែង បានធ្វើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពបន្លែ និងផ្លែឈើដែលនាំពីប្រទេសវៀតណាមចូលមកព្រះរាជាណាចក្រកម្ពុជា។ ជាលទ្ធផលក្នុងការធ្វើពិសោធន៍លើបន្លែ និងផ្លែឈើ សាខា ក.ប.ប ខេត្តបង្ហាញថាមានសុវត្ថិភាពក្នុងការទទួលទាន។

៣. នាថ្ងៃចន្ទ ៩កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ នៅការិយាល័យគយនិងរដ្ឋាករបន្ទាយចក្រី បានរៀបចំពិធីប្រកាសតែងតាំងនិងផ្ទេរភារកិច្ចជូនលោក **កែវ ផាន** ជាប្រធានការិយាល័យគយនិងរដ្ឋាករបន្ទាយចក្រី ជំនួសលោក **ហាក់ វណ្ណា** ដែលត្រូវបំពេញភារកិច្ចនៅកន្លែងថ្មី ក្រោមអធិបតីភាពលោក **មួច ដារ៉ា** ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីគយនៃសាខាគយនិងរដ្ឋាករខេត្តព្រៃវែង។

៤. នាថ្ងៃអង្គារ ១០កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ត្រូវនឹងថ្ងៃទី២ខែកញ្ញាឆ្នាំ២០២៥ នៅការិយាល័យគយនិងរដ្ឋាករម៉ឺនជ័យ បានរៀបចំពិធីប្រកាសតែងតាំង និងផ្ទេរភារកិច្ចជូនលោក **ញឹក ម៉ុនលេខ** ជាប្រធានការិយាល័យគយនិងរដ្ឋាករម៉ឺនជ័យ ជំនួស លោក **ប៉ក់ សុធា** ដែលត្រូវបំពេញភារកិច្ចនៅកន្លែងថ្មីក្រោមអធិបតីភាពលោក **មួច ដារ៉ា** ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

៦. បានបង្ក្រាបទំនិញគេចវេះពន្ធនិងកសាងកំណត់ហេតុល្មើសច្បាប់គយចំនួន ១៧ ករណី និងប្រមូលបានប្រាក់ពន្ធអាករ និងពិន័យ សរុបចំនួន ១៣៧ ២១២ ៣០០ រៀល

៦. ប្រមូលចំណូលបានប្រមាណ៨២០៩៤៨១៥០០រៀល ប្រៀបធៀបនឹងផែនការសម្រេចបាន ៩៧,៣៨% ។





សកម្មភាព លោក មួង ដារ៉ា ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង ដឹកនាំសហការីទទួលស្វាគមន៍ការអញ្ជើញមកដល់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញចុះពិនិត្យស្ថានភាពទូទៅនៅច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ





សកម្មភាពការិយាល័យគយនិងរដ្ឋាករម៉ឺនជ័យ សហការជាមួយសាខាការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំ "ក.ប.ប"ខេត្តព្រៃវែង ដើម្បីធ្វើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពបន្លែ និងផ្លែឈើដែលនាំពីប្រទេសវៀតណាម









ពិធីប្រកាសតែងតាំងនិងផ្ទេរភារកិច្ចប្រធានការិយាល័យគយនិងរដ្ឋាករបន្ទាយចក្រី និងប្រធានការិយាល័យគយនិងរដ្ឋាករម៉ឺនជ័យ ថ្មី ក្រោមអធិបតីភាព លោក មួង ដារ៉ា ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង

# សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម

ក្នុងនាមជាថ្នាក់ដឹកនាំរបស់សាខា លោក **ប្រាក់ ចាន់ធី** ប្រធានសាខាគយនិងរដ្ឋាករខេត្តកំពង់ចាម ព្រមទាំងមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទបានរួមគ្នាខិតខំប្រឹងប្រែងអនុវត្តការងារគ្រប់គ្រង ប្រមូលពន្ធអាករ និងកម្រៃផ្សេងៗ បង់ចូលថវិការជាតិដែលជាភារកិច្ចគោលរបស់អង្គភាព។ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម ប្រមូលចំណូលពន្ធអាករ សម្រេចបាន ១,០៥១,១៤៨,២០០ រៀល ស្មើនឹង ១០៥.១១% នៃផែនការរបស់ **អគរ** ។ បន្ថែមពីនេះ សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម បានចុះត្រួតពិនិត្យអនុឡោមភាពលើការប្រកាសនាំចូលទំនិញរបស់ក្រុមហ៊ុន SKUON SHOES MANUFACTURING CO.,LTD ដែលមានទីតាំងស្ថិតនៅក្នុងភូមិរៀង ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ទន្ទឹមនឹងនេះ សាខាគយនិងរដ្ឋាករខេត្តកំពង់ចាមបាននឹងកំពុងបន្តចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីគយនិងរដ្ឋាករ ដោយមានការទទួលខុសត្រូវខ្ពស់ទៅតាមជំនាញបច្ចេកទេសគយផងដែរ។ ក្នុងត្រីមាសទី៣នេះ មន្ត្រីនៃសាខាគយនិងរដ្ឋាករខេត្តកំពង់ចាម បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន៣ រួមមាន ១. វគ្គបណ្តុះបណ្តាលស្តីពី "សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ (PCA)" ២. វគ្គបណ្តុះបណ្តាលស្តីពី "ការពិនិត្យ និងការគ្រប់គ្រងការផ្តល់ការលើកទឹកចិត្ត ក្រោមយន្តការអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (អ.គ.វ.រ.ខ.)" រៀបចំឡើងដោយក្រុមការងារអភិវឌ្ឍវិស័យឯកជននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលព្រឹត្តទៅនៅខេត្តត្បូងឃ្មុំ និង ៣. វគ្គបណ្តុះបណ្តាលស្តីពី "ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ " នៅសាលាជាតិគយ។




សកម្មភាពចុះត្រួតពិនិត្យអនុឡោមភាពលើការប្រកាសនាំចូលទំនិញរបស់ក្រុមហ៊ុន SKUON SHOES MANUFACTURING CO.,LTD

# សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ

ក្រោមការដឹកនាំរបស់លោក **ឈួន ហៃ** ប្រធានសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ លោកបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តមានស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទ បានរួមគ្នាប្រឹងប្រែងអនុវត្តការងារគ្រប់គ្រង ប្រមូលពន្ធអាករ និងកម្រៃផ្សេងៗបង់ចូលថវិកាជាតិដែលជាភារកិច្ចចាំបាច់របស់អង្គភាពចូលរួមយ៉ាងសកម្មបំផុតនៅក្នុងការអនុវត្តជំនាញបច្ចេកទេសគយ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈពង្រឹងការត្រួតពិនិត្យអនុលោមភាពកណ្តាលទីដើម្បីបង្ការ និងបង្ក្រាបអំពើរត់ពន្ធគ្រប់ប្រភេទ ព្រមទាំងទប់ស្កាត់រាល់បាតុភាព អសកម្មផ្សេងៗ ជាពិសេសការអនុវត្តតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

នៅត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺបានប្រមូលចំណូលចំនួន៧៤៨,១២០,៣០០រៀល បានមកពីការបង់ពន្ធ អាករ ពិន័យផ្សេងៗ ការបង្ក្រាបទៅលើពន្ធទំនិញគេចវេះពន្ធផលពីការលក់ទំនិញរឹបអូសគ្មានការទាមទារ និងការបង់ពន្ធអាករលើសីមីរ៉ុម៉ក ដែលមានការកើនឡើងប្រមាណ ២៥.៦៣% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៥ ។ បើប្រៀបធៀបនឹងផែនការចំណូលសម្រេចបានប្រមាណ ១២៤.៦៩% ។

នៅក្នុងត្រីមាសទី៣នេះ មន្ត្រីសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ បានចុះប្រមូលព័ត៌មានសូចនាករហានិភ័យមួយចំនួនពីប្រតិបត្តិករនាំចេញ-នាំចូលប្រចាំឆ្នាំ២០២៥ នៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ។ ស្របគ្នានេះដែរនៅទី១៣ ខែកញ្ញា ឆ្នាំ២០២៥ មន្ត្រីគយនិងរដ្ឋាករខេត្តកំពង់ស្ពឺបានសហការ ជាមួយមន្ត្រីជំនាញក.ប.ប នៃសាខាក.ប.ប. ខេត្តកំពង់ស្ពឺ សមត្ថកិច្ចចម្រុះ អាជ្ញាធរមូលដ្ឋាន និងតំណាងម្ចាស់ ក្នុងការចូលរួមពិនិត្យ និងដុតកម្ទេចចោលនូវទំនិញខូចគុណភាពចំនួន០៨មុខរួមមាន៖១).ជើងទាបង្កក ចំនួន 18កេស ២).ស្លាបមាន់បង្កក ចំនួន 100កេស ៣).ជើងមាន់បង្កក ចំនួន 400កេស ៤).ត្រចៀកជ្រូកបង្កក ចំនួន ៤កេស ៥).ក្រពះជ្រូកបង្កក ១៥កេស ៦).ខួរជ្រូកបង្កក ចំនួន ៣កេស ៧).ត្រីបង្កក ចំនួន ៨កេស និង៨).នំគាវបង្កក ចំនួន៧កេសសរុបទាំងអស់មានចំនួន៥៥៥កេសស្មើនឹង ៦,៤០១.៦០គីឡូក្រាម ដែលមានទីតាំងដុតកម្ទេចនៅភូមិសំបួរ ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។



សកម្មភាពមន្ត្រីនៃសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ ចុះប្រមូលព័ត៌មានសូចនាករហានិភ័យមួយចំនួនពីប្រតិបត្តិករនាំចេញ-នាំចូលប្រចាំឆ្នាំ២០២៥ នៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ



សកម្មភាពមន្ត្រីនៃសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ ចូលរួមដុតកម្ទេចចោលនូវទំនិញខូចគុណភាពចំនួន ០៨មុខ



សកកម្មភាពមន្ត្រីគយនិងរដ្ឋាករខេត្តកំពង់ស្ពឺត្រួតពិនិត្យអនុលោមភាពកណ្តាលទី

# សាខាគយនិងរដ្ឋាករខេត្តកំពង់ធំ

ក្រោមការដឹកនាំរបស់លោក **ជាប សៅ** ប្រធានសាខាគយនិងរដ្ឋាករខេត្តកំពង់ធំ បានខិតខំយកចិត្តទុកដាក់ខ្ពស់លើការងារគ្រប់គ្រងអង្គភាព ជាពិសេសលើការប្រមូលចំណូលចូលថវិកាជាតិ តាមផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករបានដាក់ចេញអោយអនុវត្ត និងខិតខំអនុវត្តការងារបង្ការនិងបង្ក្រាបបទល្មើសគយក្នុងភូមិសាស្រ្តខេត្តកំពង់ធំដូចភ្លៀងរលឹម និងចុះពង្រឹងអនុលោមភាពតាមអាជីវកម្មដ្ឋាន និងឃ្លាំងទំនិញមួយចំនួនផងដែរ។ ជាលទ្ធផលក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តកំពង់ធំប្រមូលពន្ធ និងអាករ បានចំនួន ១,៥៦២,៩៣៥,៨០០ រៀលស្មើនឹង១៩៥.៣៦ %នៃផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានដាក់ឲ្យអនុវត្តចំនួន ៨០០,០០០,០០០ រៀល ក្នុងត្រីមាសទី៣ ។ បើប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៤ មានការកើនឡើងចំនួន ១,៣៨៥,៨៥៩,១៩០ រៀល ស្មើនឹង ៧៨២.៦៣%។ បើប្រៀបធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៥ គឺមានការកើនឡើងចំនួន ១,៣៥៥,២០៨,០៦០ រៀល ស្មើនឹង៦៥២.៣៩%។ ក្រៅពីការងារប្រមូលចំណូល មន្រ្តីនៃសាខាគយនិងរដ្ឋាករខេត្តកំពង់ធំ បានចូលរួម៖

- សិក្ខាសាលាស្តីពី "ការកំណត់អត្តសញ្ញាណផលិតផល"ដែលប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៥ នៅសាលអង្គរវត្ត នៃសណ្ឋាគារសោមាទេវី អង្គររីស៊ត & ស្ប៉ា ( Hotel Somadevi Angkor Resort & Spa ) ខេត្តសៀមរាប។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ ប្រចាំឆ្នាំ២០២៥ សម្រាប់មន្ត្រីគយនិងរដ្ឋាករ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ នៅសាលាជាតិគយ។
- វគ្គបណ្តុះបណ្តាលស្តីពី "ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ (PCA)" នៅសាលាជាតិគយ នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៥
- សិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ការពិនិត្យនិងការគ្រប់គ្រងការផ្តល់ការលើកទឹកចិត្ត ក្រោមយន្តការអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (អ.គ.វ.រ.ខ.)លើកទី៣"ដែលប្រព្រឹត្តទៅនាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៥ នៅសាលាខេត្តសៀមរាប។
- ចូលរួមពិធីប្រកាសចូលកាន់មុខតំណែងអភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ
- ចូលរួមកិច្ចប្រជុំជាមួយគណៈប្រតិភូអាជ្ញាធរសវនកម្មជាតិដើម្បីពិនិត្យលទ្ធផលសវនកម្មបណ្តោះអាសន្ននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ការិយបរិច្ឆេទ២០២៤ តាមប្រព័ន្ធវីដេអូZOOM
- បាននាំយកអំណោយ សួរសុខទុក្ខក្នុងរដូវបុណ្យភ្ជុំបិណ្ឌដល់អតីតយុទ្ធជន រស់នៅដីសម្បទានសង្គមកិច្ច ចំនួន ០៦គ្រួសារ នៅឃុំក្រយ៉ា ខេត្តកំពង់ធំ
- ចូលរួមកិច្ចប្រជុំក្រុមការងារត្រួតពិនិត្យអនុលោមភាពទំនិញដឹកជញ្ជូនចេញ-ចូលការដ្ឋានសំណង់និងអគារពាណិជ្ជកម្មតាមបណ្តោយព្រំដែន






# សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់ ដែលដឹកនាំដោយ លោក **លី សារឿន** បានជំរុញការអនុវត្តការងារសំខាន់ៗ ស្របតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏ដូចជាការអនុវត្តតាមផែនការសកម្មភាពឆ្នាំ២០២៥ និងលិខិតបទដ្ឋានជាធរមាននានារបស់ **អគរ** ទទួលបានលទ្ធផលដូចខាងក្រោម៖

**១. ការងារប្រមូលចំណូល**

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់ប្រមូលចំណូលសរុបបានចំនួន៥,៧៦២,៥៣៦,៥០០រៀល ស្មើនឹង ១៤០.៥៤% នៃផែនការចំណូលក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ នេះ។

**២. អនុលោមភាព និងការអនុវត្តច្បាប់**

- ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបទំនិញល្មើសកម្មសិទ្ធិបញ្ញា និងទំនិញខូចគុណភាព ដោយបានបង្ក្រាបទោចក្រយានយន្តល្មើសកម្មសិទ្ធិបញ្ញាចំនួន ១,៣១៦ ករណី
- ស្រាវជ្រាវនិងបង្ក្រាបអំពើរត់គេចពន្ធអំពើបន្លំពន្ធ បទល្មើសគយផ្សេងទៀត និងការគេចវេះទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ ដោយបានបង្ក្រាបទំនិញចម្រុះ ចំនួន ០១ករណី។

**៣. ការអនុវត្តការងារផ្សេងៗ**

- បានចូលរួមប្រជុំបូកសរុបការងារគយនិងរដ្ឋាករប្រចាំខែនៅ **អគរ**
- បានចូលរួមប្រជុំផ្សព្វផ្សាយលិខិតនានារបស់ **អគរ**
- បានចូលរួមប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តនិងក្រុមប្រឹក្សាខេត្តនៅសាលាខេត្តរៀងរាល់ខែ
- បានចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិនានាក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់
- បានចូលរួមសហការល្អ ជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់។




ប្រជុំផ្សព្វផ្សាយការងារផ្ទៃក្នុងសាខា



សកម្មភាពទទួលប្រតិភូនាយកដ្ឋានបុគ្គលិក អគ្គលេខាធិការដ្ឋាន កសហវ





សកម្មភាពត្រួតពិនិត្យអនុលោមភាពរថយន្តដឹកទំនិញ






សកម្មភាពចូលរួមប្រជុំការងារផ្សេងៗនៅសាលាខេត្តពោធិ៍សាត់





សកម្មភាពចូលរួមប្រជុំផ្សព្វផ្សាយលិខិតនានារបស់ អគរ

# ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ១

ក្រោមការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់លោក **អ៊ួន សុវណ្ណារ៉ា** ប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់១ ដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការណែនាំផ្ទាល់របស់លោក **នូ ស៊ីថា** ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស រួមទាំងកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់មន្ត្រីក្រោមឱវាទការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់១ បានអនុវត្តភារកិច្ច និងសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរនៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ ដោយបានបង្ក្រាបទំនិញល្មើសបានចំនួន ២៣ករណីធំ និង ១៤៦ករណីតូច ដែលមានមុខទំនិញសំខាន់ៗដូចជារថយន្តទេសចរណ៍ម៉ាស៊ីនត្រជាក់សាច់បង្កកគ្រឿងបន្លាស់ម៉ូតូភេសជ្ជៈចម្រុះគ្រឿងអេឡិចត្រូនិក ម៉ូតូ ម៉ូតូអគ្គិសនី រថយន្តអគ្គិសនី និងទំនិញចម្រុះផ្សេងទៀត ដែលសរុបចំណូលពន្ធនិងអាករ ព្រមទាំងពិន័យបានចំនួនសរុបប្រមាណ ១,៨៦៨ លានរៀល។ ក្នុងនោះដែរ លោកប្រធានការិយាល័យ បានចុះដឹកនាំដោយផ្ទាល់រួមទាំងបែងចែកកម្លាំងចុះស្រាវជ្រាវទប់ស្កាត់បង្ការ និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់ប្រភេទតាមឃ្លាំងស្តុកទំនិញ អាជីវកម្មដ្ឋាន និងរថយន្តដឹកទំនិញនានា ដោយបានចុះអនុលោមភាពឃ្លាំងស្តុកទំនិញបានចំនួន ២៣ឃ្លាំង (បានផ្ទៀងផ្ទាត់ឃើញចំនួន ៧ទីតាំង មានអនុលោមភាពសមស្រប និង ១៦ទីតាំង មានអនុលោមភាពទាប) និងធ្វើអនុលោមភាពរថយន្តដឹកទំនិញ-យានយន្តបានចំនួន ២១ករណី (បានផ្ទៀងផ្ទាត់ឃើញចំនួន ១៤ករណី មានអនុលោមភាពសមស្រប និងចំនួន ៧ករណី មានអនុលោមភាពទាប)។ បន្ថែមពីលើនោះ មន្ត្រីការិយាល័យ បានសហការជាមួយ "ក្រុមការងារចម្រុះ ដើម្បីត្រួតពិនិត្យកាតព្វកិច្ចបិទតែមប្រើអាករប្រភេទថ្មីសម្រាប់បារី" ដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ រួមជាមួយអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចុះបង្ក្រាបមុខសញ្ញាល្មើសចំនួន ២ទីតាំង នៅចំណុចភូមិសាស្ត្រខណ្ឌពោធិ៍សែនជ័យ និងខណ្ឌកំបូល និងបានចុះណែនាំដល់អាជីវកម្មដ្ឋានដ្រូនក្នុងរាជធានីភ្នំពេញសរុប ៥ទីតាំង ដើម្បីពង្រឹង និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងគោលបំណងនៃការយកដ្រូនទៅប្រើប្រាស់របស់អតិថិជននីមួយៗ ស្របតាមលិខិតលេខ ៣៦៥៨/២៥អគរ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ ស្តីពីការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងការនាំចូលយន្តហោះគ្មានមនុស្សបើក(ដ្រូន) មកកាន់ព្រះរាជាណាចក្រកម្ពុជា។







សកម្មភាពការងាររបស់ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់១



សកម្មភាពចូលរួមកិច្ចសហការ និងការងារផ្សេងៗ

# ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់៤

ក្នុងនាមជាថ្នាក់ដឹកនាំការិយាល័យ លោក **យឹម វណ្ណា:** ប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់៤ លោកប្រធានការិយាល័យ បានបង្ហាញភាពជាអ្នកដឹកនាំ តាមរយៈ ១).ការអនុវត្តច្បាប់ស្តីពីគយ និងបទបញ្ជា របស់ លោកប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស ត្រូវប្រឹងប្រែងស្រាវជ្រាវបង្ក្រាប បទល្មើសរត់គេចពន្ធ គ្រប់ប្រភេទជាពិសេសទំនិញរសើប ដូចជារថយន្ត ម៉ូតូ គ្រឿងអេឡិចត្រូនិក ប្រេងម៉ាស៊ីន គ្រឿងបន្លាស់រថយន្ត-ម៉ូតូ គ្រឿងក្រអូប ស្រា បារី។ល។ ដែលជាមុខទំនិញជាប់កម្រិតកំណត់ ២).ការចាត់តាំងមន្ត្រីក្រោមឱវាទ ចុះធ្វើអនុលោមភាពលើ ឃ្លាំងស្តុកទំនិញ អាជីវកម្មដ្ឋាន ទំនិញឆ្លងកាត់ និងទំនិញមកពីរាជធានីភ្នំពេញ និងពង្រឹងការត្រួតពិនិត្យ ឃ្លាំមើល ប្រភពដើមទំនិញមកពីប្រទេសថៃ ដែលជាប់បម្រាម នាំចូលមកកម្ពុជា មានបន្លែ ផ្លែឈើ ប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ នៅតាមបណ្តាមាត់ច្រក នៅការិយាល័យគយនិងរដ្ឋាករដូង ការិយាល័យគយនិងរដ្ឋាករអូររំដួល ការិយាល័យគយនិងរដ្ឋាករភ្នំដី ការិយាល័យគយនិងរដ្ឋាករព្រំនិងមាត់ច្រករបៀងផ្សេងៗទៀតក្រោយ យោធាថៃបិទច្រកព្រំដែនផ្លូវគោកជាឯកតោភាគី ៣).បង្កើន ការយកចិត្តទុកដាក់ តាមដានប្រភពទំនិញដែលហូរចូល ឬមានលក់ក្នុងទីផ្សារក្នុងការកំណត់មុខសញ្ញាឈានទៅដល់ការបង្ក្រាបបទល្មើសរត់គេចពន្ធគ្រប់ប្រភេទ និងសហការជាមួយអាជ្ញាធរដែនដី ឬសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ ៤).ការដោះស្រាយរាល់បញ្ហាប្រឈមដែលកើតមាន ការបង្កើនស្មារតី ធ្វើការសាមគ្គីភាពផ្ទៃក្នុង និងលើកទឹកចិត្តមន្ត្រីធ្វើការងារជាក្រុមក្នុងអង្គភាពគយ ៥).ការបង្ហាញធម៌សន្តោស និង ការណែនាំតម្រង់ទិស កែលម្អចំណុចខ្វះខាត ដល់មន្ត្រីគ្រប់ជាន់ថ្នាក់ ៦).ការប្តេជ្ញាចិត្តខ្ពស់ក្នុងការអភិវឌ្ឍចំណេះដឹង និងជំនាញដល់មន្ត្រីក្រោមឱវាទ។

លោកប្រធានតែងតែក្រើនរំលឹកដល់មន្ត្រីក្រោមឱវាទ ត្រូវអនុវត្តនីតិវិធីគយជាធរមានដោយទន់ភ្លន់តែហ្មត់ចត់ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ បន្តពង្រឹងការត្រួតពិនិត្យឯកសារនិងទំនិញរូបវន្តប្រកបដោយអប្បមាទខ្ពស់ ជាពិសេស អនុវត្តតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

## លទ្ធផលចំណូល ដែលបានពីការបង្ក្រាប៖

ជាក់ស្តែងក្នុងត្រីមាសទី៣ ឆ្នាំ២០២៥នេះ ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់៤ បង្ក្រាបបានទំនិញល្មើសសរុបចំនួន៦៥ករណីធំនិង១០៧ករណីតូច (មានទំនិញល្មើសដូចជា រថយន្ត ម៉ូតូ ប្រេងម៉ាស៊ីន ត្រង់ស្វូ បារី និងទំនិញចម្រុះ) ដែលមានប្រាក់ពន្ធនិងពិន័យសរុប ១,១៤៥,២៩៤,៩០០ រៀល ឬប្រមាណ ១២៧.២៥ % ធៀបនឹងផែនការចំណូលសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៥ របស់ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់៤។






សកម្មភាពសហការជាមួយកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងកងកម្លាំងរាជអាវុធហត្ថខេត្ត ចុះធ្វើអនុលោមភាពលើរថយន្តដឹកទំនិញ

# ផ្នែកទី៤

# ការងារសង្គម កីឡា និងសិល្បៈ

# សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ក្រៅពីការងារស្នូលរបស់អង្គភាព ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏បានយកចិត្តទុកដាក់លើកិច្ចដំណើរការរបស់សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា **"ស.ស.ម.អ.គ.រ"** ។ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវបានបង្កើតឡើងក្នុងខែមេសា ឆ្នាំ២០១៥ និងបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ៩៤៦សជណ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥ បើគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ មានសមាជិកសកម្មជាមន្ត្រីរាជការគយនិងរដ្ឋាករ៖ មានចំនួន ១,២៦៨នាក់ ក្នុងនោះសមាជិកាចំនួន ១៩៩នាក់ និងសមាជិកជាប់កិច្ចសន្យា៖ មានចំនួន ១០៨នាក់ ក្នុងនោះសមាជិកាចំនួន ៤៦នាក់។ សមាគមនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកយកចិត្តទុកដាក់និងសម្រាលការលំបាកជូនមន្ត្រីគយនិងរដ្ឋាកររួមមានការសម្រាលមាតុភាព មរណភាព គ្រោះថ្នាក់ពេលបំពេញការងារ និងជំងឺតម្កាត់ផ្សេងៗ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករចូលនិវត្តន៍ផងដែរ។ ជាមួយគ្នានេះ សមាគមបានបង្កើតមូលនិធិសប្បុរសធម៌ និងបានបន្តរួមចំណែកផ្តល់ជំនួយគាំទ្រដែលរួមមានគ្រឿងឧបភោគបរិភោគ សម្ភារប្រើប្រាស់ និងថវិកា សម្រាប់សម្រាលការលំបាកចំពោះ មណ្ឌលកុមារកំព្រា អង្គការចាស់ជរា សមាគម ក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនងាយរងគ្រោះមួយចំនួនទៀតផងដែរ។





សកម្មភាពប្រគល់ថវិកាជូនសមាជិក និងគ្រួសាររបស់សមាជិក នៃ "ស.ស.ម.អ.គ.រ"

# ការចុះសួរសុខទុក្ខ និងនាំយកអំណោយជូនដល់វីរកងទ័ព និងប្រជាពលរដ្ឋភៀសសឹក ដោយសារការឈ្លានពាន របស់កងទ័ពថៃ នៅខេត្តឧត្តរមានជ័យ

កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ នៅខេត្តឧត្តរមានជ័យ, ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួនបាននាំអំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់មកប្រគល់ជូនវីរកងទ័ពដែលកំពុងឈរជើងនៅសមរភូមិមុខ និងប្រជាពលរដ្ឋភៀសសឹកជម្លៀសមកកាន់ទីតាំងសុវត្ថិភាព ដោយសារការឈ្លានពានរបស់កងទ័ពថៃ ។

ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានពាំនាំការផ្តាំសួរសុខទុក្ខ និងកោតសរសើរពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ជូនថ្នាក់ដឹកនាំ និងវីរកងទ័ពទាំងអស់ដែលកំពុងបំពេញភារកិច្ចយ៉ាងអង់អាចក្លាហានមោះមុតការពារបូរណភាពទឹកដីប្រឆាំងសត្រូវឈ្លានពានមកលើដែនអធិបតេយ្យភាពកម្ពុជា ។ ការបំពេញភារកិច្ចដ៏ឧដុង្គឧត្តមរបស់វីរកងទ័ពប្រកបដោយឧត្តមគតិ, ស្មារតីស្នេហាជាតិ និងការលះបង់ខ្ពស់បំផុត ដើម្បីបុព្វហេតុការពារជាតិ និងសេចក្តីសុខសាន្តរបស់ប្រជាជននឹងត្រូវបានកត់ត្រាជាប្រវត្តិសាស្ត្រ និងចងចាំជារៀងរហូត ។ ចំពោះប្រជាពលរដ្ឋភៀសសឹក រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ និងយ៉ាងមមោញឹក ដើម្បីឧបត្ថម្ភគាំទ្រទាំងស្មារតី និងសម្ភារៈសំដៅដោះស្រាយ និងសម្រាលការលំបាករបស់ប្រជាពលរដ្ឋភៀសសឹក ។ តបតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល និងក្នុងស្មារតីសាមគ្គីជាតិ យន្តការការផ្សារភ្ជាប់រវាងសមរភូមិក្រោយជាមួយសមរភូមិមុខ និងទឹកចិត្តមនុស្សធម៌សប្បុរសធម៌, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានរៀបចំការចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនវីរកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹកនាពេលនេះ ។

អំណោយដ៏ថ្លៃថ្លារបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលឯកឧត្តមបណ្ឌិត **គុណ ញឹម** និងគណប្រតិភូនាំយកមកប្រគល់ជូនវីរកងទ័ព និងប្រជាពលរដ្ឋភៀសសឹក នាពេលនេះ មានគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន សរុបចំនួន ៥០០០ កញ្ចប់ (Kits) ដើម្បីចែកជូនដូចខាងក្រោម៖

- សម្រាប់វីរកងទ័ពមានចំនួន១០០០កញ្ចប់សរុបរួមមាន៖ អំបុកលីង ចំនួន ៥០០ គីឡូក្រាម, នំកងទ័ព ចំនួន ៣០០០ដុំ, ស្ករគ្រាប់កាហ្វេ ចំនួន១០០០កញ្ចប់, ស្ករសចំនួន៤០០គីឡូក្រាម, បារី ចំនួន ២០០០ កញ្ចប់, កាហ្វេ ចំនួន ១០០០០កញ្ចប់, ផ្លែប៉ូវចំនួន១០០០គីឡូក្រាម, បាយក្តាំង ចំនួន ២០០០ កញ្ចប់, ក្រមា ចំនួន ១០០០, ម៉ាស់ ចំនួន ៣០០០០ បន្ទះ និងខ្ទឹមស ចំនួន ១០០០ កញ្ចប់
- ប្រជាពលរដ្ឋភៀសសឹកមានចំនួន៤០០០កញ្ចប់ (១កញ្ចប់សម្រាប់១គ្រួសារ) សរុបរួមមាន៖ គ្រឿងឧបភោគបរិភោគមានអង្ករ២០តោន, ត្រីខចំនួន ៨០០០កំប៉ុង, ទឹកក្រូច ចំនួន ៥២០០កំប៉ុង, សាច់ក្រកចំនួន២ តោន, ត្រីងៀតចំនួន២ តោន, ទឹកស៊ីអ៊ីវ ៤០០០ ដប, ទឹកដោះគោខាប់ ចំនួន ៨៤កេស (ស្មើនឹង៤០៣២កំប៉ុង), ទឹកដោះស្រស់ Angkor Milk ចំនួន ៦៧០ កេស និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរួមមានសាប៊ូដុំដុសខ្លួន, សាប៊ូបោកខោអាវ, ប្រេងកូឡា, ថ្នាំដុសធ្មេញ-ច្រាសដុសធ្មេញ, សំឡីអនាម័យ, ភួយ, ខ្នើយ, មុងនិងក្រមា ដែលក្នុងមួយមុខៗ មានចំនួន ៤០០០ ។






ទីស្នាក់ការ






# កម្មវិធីប្រគល់អំណោយជូនដល់កងពលធំអន្តរាគមន៍លេខ ២

កាលពីព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥, ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួនបានប្រគល់អំណោយរបស់សម្តេចមហាបវរធិបតី និងលោកជំទាវបណ្ឌិត ជាសម្ភារៈ/បរិក្ខារគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ប្រគល់ជូនកងពលធំអន្តរាគមន៍លេខ ២ ដែលជាអង្គភាពសម្ព័ន្ធមេត្រីភាពជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានពាំនាំផ្តាំផ្ញើការសួរសុខទុក្ខនិងកោតសរសើរពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ជូនថ្នាក់ដឹកនាំ និងវីរកងទ័ពទាំងអស់ដែល កំពុងបំពេញភារកិច្ចយ៉ាងអង់អាចក្លាហានមោះមុតការពារបូរណភាពទឹកដី ប្រឆាំងសត្រូវឈ្លានពានមកលើដែនអធិបតេយ្យភាពកម្ពុជា ប្រកបដោយឧត្តមគតិស្នេហាជាតិដ៏ឧដុង្គឧត្តម និងការលះបង់ខ្ពស់បំផុត ។

អំណោយនិងថវិកាដ៏ថ្លៃថ្លារបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ជូនដល់កងពលធំអន្តរាគមន៍លេខ ២ រួមមាន ម៉ូតូ Honda Wave ឆ្នាំ២០២៥ ចំនួន ៦គ្រឿង, Mobile Power Stations 315000mAh (600W) ចំនួន ២៥ គ្រឿង, មី ២០០កេស, នំទាហាន ១៦១កេស (សរុប ៦,០០០ដុំ), កាហ្វេ 3 in 1 ៨៤កេស(សរុប ២,០០០កញ្ចប់), ទឹកដោះគោខាប់ ៨៤កេស (សរុប ៤,០៣២កំប៉ុង), ត្រីខ ៦០កេស (សរុប ៦,០០០កំប៉ុង), បាយក្តាំង ៦០កេស (សរុប ៦,០០០កញ្ចប់), អំបុក ៣៣០គីឡូក្រាម, ស្ករស ១១៣គីឡូក្រាម, បារី ១៥កេស (សរុប ៧៥០សុង), ថ្នាំ Advil ២៥កំប៉ុង (១កំប៉ុង ៣៦០គ្រាប់) និងថវិកាមួយចំនួន ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២៥ ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបាននាំយកអំណោយជាគ្រឿងឧបភោគ-បរិភោគ ចំនួន ៥០០០ កញ្ចប់ (kits) និងថវិកាមួយចំនួនជូនវីរៈកងទ័ពជួរមុខដែលកំពុងត្រៀមប្រយុទ្ធនឹងទាហានថៃដែលឈ្លានពានមកលើអធិបតេយ្យភាពកម្ពុជា និងជូនប្រជាជនភៀសសឹកដែលគេចចេញមកទីសុវត្ថិភាពនៅស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។












# កម្មវិធីចុះសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌របស់ សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចែកជូនវិទ្យាល័យអប់រំពិសេសច្បារអំពៅ

នាព្រឹកថ្ងៃសៅរ៍ ៧កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៥ នៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (Cambodian Women's Crisis Center) ក្នុងសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ, លោកបណ្ឌិត **សន់ ស៊ីណាវិទ្យ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមជាមួយក្រុមការងារ បានជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌របស់សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចែកជូនអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ។

អំណោយសប្បុរសធម៌ដែលបានផ្តល់ជូនអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ទាំង៣ មណ្ឌល (រាជធានីភ្នំពេញ, ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ) នាឱកាសនេះ រួមមាន អង្ករចំនួន ៦០០ គីឡូក្រាម, ស្ករស ១០០ គីឡូក្រាម, មីជាតិចំនួន ៤៨ កេសតូច, ប្រេងឆា ៤ដបធំ, ត្រីខ ៥កេសធំ, ទឹកត្រី១២ យួរ, ទឹកស៊ីអ៊ីវចំនួន ១២យួរ, ទឹកដោះគោខាប់ ២កេស, ឧបត្ថម្ភថវិកាជូនអង្គការ ព្រមទាំងចែកជូនថវិកាមួយចំនួនដល់បុគ្គលិក ស្ត្រី និងកុមាររងគ្រោះកំពុងស្នាក់នៅផងដែរ។

នាឱកាសនោះ ក្រុមការងារសប្បុរសធម៌ បានសម្តែងសេចក្តីសោមនស្សរីករាយដែលបានមកជួបសំណេះសំណាល និងនាំយកនូវអំណោយសប្បុរសធម៌ចូលរួមចំណែកជួយឧបត្ថម្ភសម្រាលការខ្វះខាតនិងតម្រូវការជាមូលដ្ឋានរបស់អង្គការនេះ។ក្រុមការងារសប្បុរសធម៌ក៏បានលើកឡើងពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការជួយជ្រោមជ្រែងដល់អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ដែលអង្គការនេះបានចូលរួមជួយអប់រំប្រែកបដោយគុណភាពខ្ពស់ បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងគាំទ្របីបាច់ថែរក្សាដល់ស្ត្រីនិងកុមាររងគ្រោះ ដែលមានជីវភាពខ្វះខាត ដើម្បីជួយពួកគាត់ទាំងនោះមានអនាគតល្អប្រសើរ។ ទន្ទឹមនេះ លោកប្រធានបានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ គ្រប់ជាន់ថ្នាក់ ដែលបានលះបង់កម្លាំងកាយចិត្ត ធនធាន និងពេលវេលា ប្រកបដោយចិត្តសប្បុរសធម៌ ដែលបានជួយដល់ស្ត្រីនិងកុមាររងគ្រោះជាច្រើននាក់។

តំណាងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង លោកជំទាវ ព្រមទាំងសហការីទាំងអស់មានចិត្តសប្បុរស ដែលបានចំណាយធនធានថវិកានិងសម្ភារជួយអង្គការនាពេលនេះ។










# កម្មវិធីចែកអំណោយដល់សមាគមតន្ត្រីសំនៀងជនពិការ

នាព្រឹកថ្ងៃសៅរ៍ ៧កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៥ លោកបណ្ឌិត **ឈន ឌឿន** នាយកសាលាជាតិគយ ទទួលបន្ទុកនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមជាមួយសហការី បានចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកនូវអំណោយសប្បុរសធម៌របស់សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ផ្តល់ជូនសមាគមតន្ត្រីសំនៀងជនពិការ ដែលមានទីតាំងស្ថិតនៅអគារលេខ ២៩៨D ផ្លូវលំ ក្រុម២ ភូមិជំរៅ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

ជំនួយឧបត្ថម្ភដែលបានផ្តល់ជូនសមាគមតន្ត្រីសំនៀងជនពិការ នាឱកាសនោះរួមមាន៖ អង្ករ ១ តោន, មីជាតិ ៣០ កេស, ត្រីខ ៣ កេស, ទឹកត្រី ១០ យួរ, ទឹកស៊ីអ៊ីវ ១០ យួរ, ស្ករស ២ បាវ, អំបិល ២០ យួរ, សាប៊ូលាងដៃ ២ កេស, សាប៊ូម្សៅ ៤ កេស, អាកុល ២កាន, និងថវិកាមួយចំនួនសម្រាប់ឧបត្ថម្ភជូនបុគ្គលិកនិងបងប្អូនដែលមានពិការភាព ព្រមទាំងឧបត្ថម្ភថវិកាចំនួន ១០ លានរៀល សម្រាប់ចូលរួមចំណែកទិញឧបករណ៍តន្ត្រីសម័យប្រើប្រាស់ជាប្រយោជដល់សមាគមតន្ត្រីសំនៀងជនពិការផងដែរ។

ក្នុងនាមក្រុមការងារសប្បុរសធម៌ លោកបណ្ឌិត **ឈន ឌឿន** បានសម្តែងនូវសេចក្តីសោមនស្សរីករាយ ព្រមទាំងបានពាំនាំនូវសេចក្តីនឹករលឹកនិងការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** និងលោកជំទាវ ជូនចំពោះបងប្អូនដែលមានពិការភាពទាំងអស់ដែលកំពុងស្នាក់នៅក្នុងសមាគមតន្ត្រីសំនៀងជនពិការ។ក្នុងឱកាសនោះដែរ លោកនាយកសាលាជាតិគយក៏បានធ្វើការវាយតម្លៃនិងកោតសរសើរដល់ថ្នាក់ដឹកនាំរបស់សមាគមគ្រប់ជាន់ថ្នាក់ដែលបានបំពេញតួនាទីបានយ៉ាងល្អក្នុងការថែទាំ ទំនុកបម្រុង ផ្តល់ភាពកក់ក្តៅ និងមានសាមគ្គីភាពគ្នាល្អប្រសើរ ប្រកបដោយទឹកចិត្តសប្បុរស ក្នុងការជួយសង្គ្រោះដល់បងប្អូនដែលមានពិការភាព ជាពិសេសគឺបានជួយផ្តល់នូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលអាចជួយឱ្យបងប្អូនជនពិការមួយចំនួនធំមានសមត្ថភាពនិងទំនុកចិត្តខ្លួនឯង និងអាចចេញទៅប្រកបរបរចិញ្ចឹមជីវិតបានទៀតផង។

ជាការឆ្លើយតបចំពោះកាយវិការដ៏សប្បុរសនេះ លោកជំទាវ **ញៀម មរកត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានកិត្តិយសរបស់សមាគមតន្ត្រីសំនៀងជនពិការ និង ឯកឧត្តម **ចាប ត្នូ** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងជាប្រធានសមាគមតន្ត្រីសំនៀងជនពិការ បានសម្តែងនូវសេចក្តីរីករាយ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងលោកជំទាវ ថ្នាក់ដឹកនាំ និងមន្ត្រីគយនិងរដ្ឋាករទាំងអស់ដែលមានទឹកចិត្តសប្បុរសថ្លៃថ្លានិងតែងតែយកចិត្តទុកដាក់ចុះសួរសុខទុក្ខដល់បងប្អូនដែលមានពិការភាព ព្រមទាំងបាននាំយកនូវអំណោយជា សម្ភារប្រើប្រាស់ គ្រឿងឧបភោគបរិភោគ និងថវិកា ជូនដល់សមាគម តន្ត្រីសំនៀងជនពិការជារៀងរាល់ឆ្នាំ។

សូមបញ្ជាក់ផងដែរថា មូលនិធិសប្បុរសធម៌ក្រោមក្របខណ្ឌសមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០២០ ក្នុងស្មារតីចូលរួមចំណែកផ្តល់ជំនួយគាំទ្រសម្រាប់ជួយសម្រាលដល់ការលំបាកចំពោះ អង្គការ សមាគម មណ្ឌលកុមារកំព្រា និងជនងាយរងគ្រោះនានា។





















# ការជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌ របស់សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ផ្តល់ជូនអង្គការផ្ទះបាយកុមារ

នាព្រឹកថ្ងៃអាទិត្យ ១៥កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៥ នៅអង្គការផ្ទះបាយកុមារ ស្ថិតនៅផ្លូវលេខ ១៣៥ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ, លោកបណ្ឌិត **សង់ ស៊ីណាវិទ្យ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមជាមួយក្រុមការងារ បានជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌របស់សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ផ្តល់ជូន អង្គការផ្ទះបាយកុមារ។

អំណោយសប្បុរសធម៌ដែលបានផ្តល់ជូន អង្គការផ្ទះបាយកុមារ រួមមាន៖ អង្ករចំនួន ៦០០ គីឡូក្រាម, ស្ករស ១០០ គីឡូក្រាម, មីជាតិចំនួន ៤៨ កេសតូច, ប្រេងឆា ៤ដបធំ, ត្រីខ ៥កេសធំ, ទឹកត្រី១២ យួរ, ទឹកស៊ីអ៊ីវចំនួន ១២យួរ, ទឹកដោះគោខាប់ ២កេស, ឧបត្ថម្ភថវិកាជូនអង្គការមួយចំនួន ព្រមទាំងជូនថវិកាដល់បុគ្គលិកបម្រើការ និងរៀបចំអាហារសម្រន់ ចែកជូនដល់កុមារនិងអ្នកចូលរួមទាំងអស់គ្នា។

ក្នុងនាមក្រុមការងារសប្បុរសធម៌លោកបណ្ឌិត**សង់ស៊ីណាវិទ្យ**បានសម្តែងសេចក្តីសោមនស្សរីករាយព្រមទាំងបានពាំនាំនូវសេចក្តីនឹករលឹក និងការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** និងលោកជំទាវ ជូនដល់ក្មួយៗកុមារទាំងអស់ដែលកំពុងស្នាក់នៅក្នុងអង្គការផ្ទះបាយកុមារ។ ក្នុងឱកាសនោះដែរ លោកបណ្ឌិតបានថ្លែងនូវអំណរគុណចំពោះអង្គការនេះដែលបានចូលរួមជួយគាំពារនិងលើកកម្ពស់សុខុមាលភាពដល់កុមារ ដែលស្ថិតក្នុងជីវភាពគ្រួសារខ្វះខាត និងងាយរងគ្រោះក្នុងសង្គម ព្រមទាំងបានការកោតសរសើរខ្ពស់ដល់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់របស់អង្គការ ដែលបានលះបង់កម្លាំងកាយចិត្ត ធនធាន និងពេលវេលាប្រកបដោយទឹកចិត្តសប្បុរស ក្នុងការជួយសង្គ្រោះដល់ក្មួយៗកុមារ ឱ្យមានសុខភាពល្អរឹងមាំ ដើម្បីរៀនសូត្របានពូកែ និងក្លាយជាធនធានមនុស្សប្រកបដោយគុណភាព សម្រាប់ការអភិវឌ្ឍន៍សង្គមជាតិក្នុងពេលអនាគត។

តំណាងអង្គការផ្ទះបាយកុមារ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះក្រុមការងារ ជាពិសេស ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងលោកជំទាវ ព្រមទាំងសហការីទាំងអស់ ដែលមានទឹកចិត្តសប្បុរសធម៌ ចំណាយធនធានថវិកានិងសម្ភារជួយដល់អង្គការនាពេលនេះដើម្បីចូលរួមចំណែកជួយឧបត្ថម្ភសម្រាលការខ្វះខាត និងតម្រូវការជាមូលដ្ឋានរបស់អង្គការ។




Les Restaurants des Enfants
CAMBODIA
C.P Cambodia CO., Ltd.


Golden
CHARITY
Legacy
miracles
WORLDWIDE
L.R.D.E
Les Restaurants des Enfants
WALTZ'ING
AROUND
CAMBODIA
D'Luxe
CPF
CP
WAKODO
C.P Cambodia CO., Ltd.


Golden
CHARITY
Cambodia
Legacy
miracles
WORLDWIDE
ផ្ទះបាយកុមារ
L.R.D.E
Les Restaurants des Enfants
WALTZ'ING
AROUND
CAMBODIA
D'Luxe
CPF
CP
WAKODO
C.P Cambodia CO., Ltd.









# កម្មវិធីនាំយកអំណោយសប្បុរសធម៌ជូនដល់ កុមារ លោកគ្រូ អ្នកគ្រូ និងបុគ្គលិក នៅបុរីទារកនិងកុមារជាតិ

នារសៀល ថ្ងៃសុក្រ ៦រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៥ លោក **ទូច លីដែល** ប្រធាននាយកដ្ឋានផែនការនិងបច្ចេកទេសតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានដឹកនាំក្រុមការងារសប្បុរសធម៌នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចុះជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌ជូនដល់កុមារចំនួន ២០០នាក់ លោកគ្រូអ្នកគ្រូ និងបុគ្គលិក ចំនួន ៨០នាក់ នៅបុរីទារកនិងកុមារជាតិ ស្ថិតក្នុងភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ជំនួយឧបត្ថម្ភដែលបានផ្តល់ជូន បុរីទារកនិងកុមារជាតិ មានដូចជា អង្ករ ១តោន, នំចម្រុះ ៤៣កេស,នំប៉័ងក្រៀម ៩កេស, ស្ករសូកូឡា ៩កេស, ទឹកដោះគោស្រស់ ១០កេស, ទឹកដោះគោខាប់ ៣កេស, ទឹកក្រូច ៦កេស, ត្រីខ ១កេស, ទឹកស៊ីអ៊ីវ ៣០យួរ, ខ្ទឹមស ១បាវ, សាប៊ូដុំ ៤ឡូ, ម្សៅទឹកដោះគោ ១២កំប៉ុង, សំឡីអនាម័យស្ត្រី ៦យួរ, ខោទឹកនោម ២៥យួរ, ព្រមទាំងថវិកាឧបត្ថម្ភមួយចំនួន។ ជាកិច្ចឆ្លើយតបនឹងអំណោយឧបត្ថម្ភខាងលើនេះ លោកស្រី **ថោ ពៅ** ប្រធានបុរីទារកនិងកុមារជាតិ បានសម្តែងនូវសេចក្តីរីករាយ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងលោកជំទាវ ថ្នាក់ដឹកនាំ និងមន្ត្រីគយនិងរដ្ឋាករទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ ចុះសួរសុខទុក្ខដល់កុមារមានពិការភាព និងកុមារកំព្រា ព្រមទាំងបាននាំយកអំណោយជាសម្ភារៈប្រើប្រាស់ គ្រឿងឧបភោគបរិភោគ និងថវិកា ជូនដល់បុរីទារកនិងកុមារជាតិជារៀងរាល់ឆ្នាំ។

ឆ្លៀតក្នុងឱកាសនោះដែរ ក្រុមការងារសប្បុរសធម៌នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានថ្លែងកោតសរសើរដល់គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ បុគ្គលិកទាំងអស់នៃបុរីទារកនិងកុមារជាតិ ដែលបានបំពេញតួនាទីបានយ៉ាងល្អ ក្នុងការថែទាំ ទំនុកបម្រុង ផ្តល់ភាពកក់ក្តៅ និងបង្ហាត់បង្រៀនកុមារកំព្រា និងមានពិការភាពទាំងអស់ប្រកបដោយការអត់ធ្មត់ ទឹកចិត្តអាណិតអាសូរ និងសណ្តោសប្រណី។

គួរបញ្ជាក់ផងដែរថា មូលនិធិសប្បុរសធម៌ក្រោមក្របខណ្ឌសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានបង្កើតឡើងកាលពីឆ្នាំ២០២០ កន្លងមក ក្នុងស្មារតីចូលរួមចំណែកផ្តល់ជំនួយគាំទ្រសម្រាប់សម្រាលដល់ការលំបាកចំពោះ អង្គការ សមាគម មណ្ឌលកុមារកំព្រា និងជនងាយរងគ្រោះនានា។










UniDry
SUPREME




KOPIKO
HLST
A-1000 ML


HLST
A-1000 ML



# ការប្រកួតកីឡាពានរង្វាន់លើកទី២ ឆ្នាំ២០២៥
# អបអរសាទរខួបអនុស្សាវរីយ៍លើកទី៧៤ ថ្ងៃបង្កើតរដ្ឋបាលគយកម្ពុជា

នាថ្ងៃអាទិត្យ ១១កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៥ លោកអគ្គនាយករង **ផា អេងឆ័ង** តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទការប្រកួតកីឡា "អបអរសាទរខួបអនុស្សាវរីយ៍លើកទី៧៤ ថ្ងៃបង្កើតរដ្ឋបាលគយកម្ពុជា ២៩ មិថុនា ១៩៥១-២០២៥" នៅសាលកីឡានៃសាលាជាតិគយ ក្រោមទិសស្លោក "កីឡារស់ក្នុងសន្តិភាព កីឡាដើម្បីសុខភាព និងមិត្តភាព" ដោយមានការចូលរួមពីកីឡាករជាមន្ត្រីគយនិងរដ្ឋាករមកពីបណ្តាអង្គភាពគយនិងរដ្ឋាករទូទាំងប្រទេសសរុបចំនួន ១៧០ រូប និងតំណាងវិស័យឯកជនមួយចំនួនផងដែរ។

ក្នុងឱកាសនោះ លោកអគ្គនាយករង **ផា អេងឆ័ង** បានសម្តែងនូវការអបអរសាទរ បំពាក់មេដាយ និងប្រគល់ពានរង្វាន់ដល់កីឡាករ ដែលបានទទួលជ័យលាភីក្នុងការប្រកួតកីឡា ចំនួន ៣ វិញ្ញាសា រួមមាន៖ វាយប៊ូល (ប៉េតង់) កីឡាវាយកូនឃ្លីលើតុ និងកីឡាអុកចត្រង្គ ព្រមទាំងបំពាក់មេដាយកិត្តិយសនិងប្រគល់ប័ណ្ណថ្លែងអំណរគុណដល់មន្ត្រីគយនិងរដ្ឋាករ, ក្រុមការងាររៀបចំការប្រកួត, សប្បុរសជនដែលបានឧបត្ថម្ភដល់កម្មវិធីប្រកួតកីឡានាពេលនោះផងដែរ។ ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡានេះឡើង ក្នុងគោលបំណងលើកស្ទួយស្មារតីកីឡា សុខភាព មិត្តភាព បង្កើនចំណងសាមគ្គីភាព ភាពស្និទ្ធស្នាលក្នុងស្ថាប័នគយ និងលើកកម្ពស់ ការកសាងកាយសម្បទា សុខភាពរាងកាយនិងបញ្ញាស្មារតី រឹតបន្តឹងចំណងសាមគ្គីភាពក្នុងនិងក្រៅរង្វង់គ្រួសារគយបន្ថែមទៀត។




























# ការប្រកួតកីឡាវាយសីពានរង្វាន់លើកទី១ ឆ្នាំ២០២៥
# អបអរសាទរខួបអនុស្សាវរីយ៍លើកទី៧៤ ថ្ងៃបង្កើតរដ្ឋបាលគយកម្ពុជា

នាថ្ងៃសៅរ៍ ២រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥ ក្លឹបវាយសីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានរៀបចំការប្រកួតកីឡាវាយសីពានរង្វាន់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើកទី១ ឆ្នាំ២០២៥ អបអរសាទរ "ខួបអនុស្សាវរីយ៍លើកទី៧៤ ថ្ងៃបង្កើតរដ្ឋបាលគយកម្ពុជា ២៩ មិថុនា ១៩៥១-២០២៥" នៅទីលានក្លឹបកីឡាសាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងទីលានក្លឹបកីឡាការិយាល័យគយនិងរដ្ឋាករបន្ទាយចក្រីក្រោមទិសស្លោក "កីឡារស់ក្នុងសន្តិភាពកីឡាដើម្បីសុខភាពនិងមិត្តភាព" ដោយមានការចូលរួមពីកីឡាករជាមន្ត្រីគយនិងរដ្ឋាករមកពីបណ្ដាអង្គភាព គយនិងរដ្ឋាករទូទាំងប្រទេសសរុបចំនួន ៦២រូប។

ក្នុងឱកាសនោះ លោក **ជា សំណាង** បានសម្ដែងនូវការអបអរសាទរ បំពាក់មេដាយ និងប្រគល់ពានរង្វាន់ដល់កីឡាករ-កីឡាការី ដែលបានទទួលជ័យលាភីក្នុងការប្រកួតវិញ្ញាសាចម្រុះជ័យលាភី និងវិញ្ញាសាជម្រើសជ័យលាភី ព្រមទាំងបំពាក់មេដាយកិត្តិយសនិងប្រគល់ប័ណ្ណថ្លែងអំណរគុណដល់មន្ត្រីគយនិងរដ្ឋាករ,ក្រុមការងាររៀបចំការប្រកួត, ដែលបានឧបត្ថម្ភ និងសម្របសម្រួលដល់កម្មវិធីប្រកួតកីឡានាពេលនោះផងដែរ។ ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡានេះឡើង ក្នុងគោលបំណងលើកស្ទួយស្មារតីកីឡា សុខភាព មិត្តភាព បង្កើនចំណងសាមគ្គីភាព ភាពស្និទ្ធស្នាលក្នុងស្ថាប័នគយ និងលើកកម្ពស់ការកសាងកាយសម្បទា សុខភាពរាងកាយនិងបញ្ញាស្មារតីរឹតបន្តឹងចំណងសាមគ្គីភាពក្នុង និងក្រៅរង្វង់គ្រួសារគយបន្ថែមទៀត។








កីឡានាំមកនូវសុខភាព មិត្តភាព និងសាមគ្គីភាព



កីឡានាំមកនូវសុខភាព មិត្តភាព និងសាមគ្គីភាព


កីឡានាំមកនូវសុខភាព មិត្តភាព និងសាមគ្គីភាព


# សិល្បៈ

ក្រោមការជ្រោមជ្រែងនិងយកចិត្តទុកដាក់ដ៏ខ្ពស់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានគណៈកម្មការគ្រប់គ្រងកីឡានិងសិល្បៈនិងការឧបត្ថម្ភគាំទ្រពីសំណាក់ថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករទូទាំងប្រទេសបានជំរុញសកម្មភាពសិល្បៈក្នុង **អគរ** បន្តសកម្មភាពយ៉ាងសកម្មនិងភាតរភាព។ ជាមួយគ្នានេះដែរ អនុគណៈកម្មការគ្រប់គ្រងសិល្បៈបានបន្តធ្វើការហ្វឹកហាត់ជារឿយៗក្រោយការសម្រាកពីការងារស្នូលរបស់អង្គភាព។កាលពីថ្ងៃទី៦ខែកក្កដាឆ្នាំ២០២៥ក្រុមការងារសិល្បៈតូរ្យតន្ត្រី **អគរ** បានចូលរួមប្រគំសម្តែងក្នុងពិធីពិសាអាហារសាមគ្គីអបអរសាទរការប្រកួតកីឡាពានរង្វាន់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើកទី២ ឆ្នាំ២០២៥ កីឡាវាយប៊ូល(ប៉េតង់) វាយកូនឃ្លីលើតុ និង អុកចត្រង្គ អបអរសាទរខួបអនុស្សាវរីយ៍លើកទី៧៤ ថ្ងៃបង្កើតរដ្ឋបាលគយកម្ពុជា។ ក្រោយពីបញ្ចប់ការប្រគំសម្តែងប្រកបដោយភាពជោគជ័យរួចមក ក្រុមការងារសិល្បៈតូរ្យតន្ត្រី **អគរ** ក៏បានបន្តការហ្វឹកហាត់ដើម្បីត្រៀមសម្រាប់ការសម្តែងផ្សេងៗផងដែរ។









ប្រវត្តិរដ្ឋបាលគយកម្ពុជាវីដេអូ

គេហទំព័ររដ្ឋបាលគយកម្ពុជា


អាសយដ្ឋាន : លេខ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥)២៣ ២១៤ ០៦៥

អ៊ីម៉ែល : info-pru@customs.gov.kh

គេហទំព័រ : www.customs.gov.kh

Facebook : អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា